សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

UNIVERSITÉ ROYAL DE DROIT ET DES SCIENCES ÉCONOMIQUES

ROYAL UNIVERSITY OF LAW AND ECONOMICE

## សារណាបញ្ចប់ការសិក្សា

# ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ

ស្រាវជ្រាវចាប់ពីថ្ងៃ ០៣ ខែ មេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ កញ្ញា **ហៀត លីហ្សា**

កញ្ញា **សឿន មូផាន់**

ណែនាំដោយ៖

លោកស្រី **ទី សុឃីតា**

បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរឈ្មោះ **ហៀត លីហ្វា** និង **សឿន មុនាន់** ជានិស្សិតថ្នាក់បរិញ្ញាបត្រជំនាន់ទី២៣ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅក្នុងឆ្នាំសិក្សា ២០២២ និង ២០២៣។ យើងខ្ញុំទាំងពីរនាក់បានសរសេរសារណាដើម្បីបញ្ចប់ការសិក្សា ដោយជ្រើសរើសនូវប្រធានបទនិយាយអំពី "**ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ**"។

សូមគោរពលំឱនកាយ សម្តែងនូវមហាកត្តញ្ញូធម៌ដឹងគុណយ៉ាងជ្រាលជ្រៅបំផុតទៅចំពោះ**លោកឪពុកនិងអ្នកម្តាយ**ដែលបានផ្តល់កំណើតឱ្យកូន អប់រំ ទូន្មាន ប្រៀនប្រដៅ និងផ្តល់ដំបូន្មានល្អៗ ផ្គត់ផ្គង់គ្រប់សព្វបែបយ៉ាងទាំងកម្លាំងកាយកម្លាំងចិត្ត មិនខ្លាចនឿយហត់ ដែលលោកបានខិតខំប្រឹងប្រែងដើម្បីឱ្យកូនបានសិក្សារៀនសូត្រតាំងពីបឋមសិក្សារហូតមកដល់សព្វថ្ងៃ។ សេចក្តីដឹងគុណទាំងនេះ ពិតជាធំធេងមិនអាចកាត់ថ្លៃបានសម្រាប់យើងខ្ញុំទាំងពីរនាក់។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់លោកបណ្ឌិត **លុយ ចណ្ណា** សាកលវិទ្យាធិការ សាកលវិទ្យាសធិការរង ព្រឹទបុរស ព្រឹទបុរសរង ព្រមទាំងលោក លោកស្រី សាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្ររសេដ្ឋកិច្ច ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ជាមួយនឹងកម្លាំងកាយចិត្តក្នុងការផ្តល់ចំណេះដឹង អប់រំ និងផ្តល់ដំបូន្មានល្អៗ ជម្រុញលើកទឹកចិត្តដល់យើងខ្ញុំទាំងពីរ និងនិស្សិត ផ្សេងៗ អស់រយៈពេល៤ឆ្នាំមកនេះ។

សូមថ្លែងអំណរគុណលោកស្រី **ទី សុឃីតា** ដែលជាសាស្ត្រាចារ្យណែនាំ និងដឹកនាំការសរសេរសារណារបស់យើងខ្ញុំទាំងពីរនាក់ ដោយលោកស្រីសាស្ត្រាចារ្យបានចំណាយទាំងពេលវេលានិងកម្លាំងកាយចិត្ត និងចំណេះដឹង យោបល់ ការលើកទឹកចិត្ត និងការបង្ហាញផ្លូវដល់យើងខ្ញុំរហូតបានការបញ្ចប់នូវកិច្ចការស្រាវជ្រាវមួយនេះ។

សូមថ្លែងអំណរគុណដល់**រៀមច្បង និងមិត្តរួមជំនាន់**ទាំងអស់ដែលបានលើកទឹកចិត្ត គាំទ្រ និងចែករំលែកនូវបទពិសោធន៍ល្អៗ និងជម្រុញឱ្យយើងខ្ញុំទាំងពីរមានចិត្តមុះមុតសម្រេចបាននូវសមិទ្ធផល មួយនេះ ដើម្បីទុកជាឯកសារក្នុងការស្រាវជ្រាវផ្សេងៗ ជូនដល់មិត្តនិស្សិត និងប្អូនៗជំនាន់ក្រោយ សិក្សាឱ្យកាន់តែស៊ីជម្រៅនូវប្រធានបទមួយនេះ។

ជាចុងក្រោយយើងខ្ញុំទាំងពីរ សូមធ្វើការអនុញ្ញាតលំឱនកាយគោរព ទៅចំពោះលោកមានគុណទាំងពីរ និងសូមគោរពប្រសិទ្ធពរជ័យដល់ លោក លោកស្រីសាស្ត្រាចារ្យ សូមឱ្យជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើន សុខភាពមាំមួន និងប្រកបដោយជោគជ័យគ្រប់ភារកិច្ចនិងសម្រេចបាននូវពុទ្ធពរទាំង៤ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាត ឡើយ។

# អារម្ភកថា

បន្ទាប់ពីយើងខ្ញុំ បាននឹងកំពុងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ យើងបានសិក្សានូវមុខជំនាញជាច្រើននៃនីតិឯកជន និងនីតិសាធារណៈ យើងខ្ញុំទាំងពីរបានទទួលនូវចំណេះដឹងជាច្រើន ដោយមានការយកចិត្តទុកដាក់ខ្ពស់ពីលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ ក្នុងការបង្ហាត់បង្រៀន ប្រៀនប្រដៅ ចែករំលែកនូវបទពិសោធន៍ការងារ និងចំណេះដឹងទូទៅ ដែលជាការជំរុញយើងខ្ញុំទាំងពីរនាក់ឱ្យឈានមកដល់ការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ។

ក្រោយពីរមានការបង្ហាត់បង្រៀនពីសំណាក់លោកស្រី សាស្ត្រាចារ្យ រួចមក យើងខ្ញុំទាំងពីរនាក់ មានការចាប់អារម្មណ៍ និងមានចំណូលចិត្តទៅលើផ្នែកខាងនីតិឯកជនយ៉ាងខ្លាំង ទើបយើងខ្ញុំទាំងពីរនាក់សម្រេចចិត្តជ្រើសរើសប្រធានបទ" **ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ** " ក្នុងការសសរសេរសារណាឡើង។ មូលហេតុដែលយើងខ្ញុំទាំងពីរនាក់ជ្រើសរើសយកប្រធានបទនេះព្រោះចង់ឱ្យបុគ្គលគ្រប់រូប ដែលបានអាន សិក្សាស្រាវជ្រាវ ឱ្យយល់ដឹងអំពីអ្វីទៅជាលំហូរនៃនីតិវិធីប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ។ ព្រោះអ្វីដែលច្បាប់ចែងជាភាសារបច្ចេកទេសមានតែបុគ្គលដែលគាត់មានចំណេះដឹងខាងច្បាប់ដែរ ទើបគាត់អានហើយយល់នូវខ្លឹមសារ ចំណែកឯបុគ្គលមួយចំនួនគាត់អាច នឹងមិនសូវយល់ព្រោះតែមានពាក្យបច្ចេកទេសក្នុងច្បាប់នីមួយៗ។ ម្យ៉ាងវិញទៀត នាពេលបច្ចុប្បន្ននៅតែមានប្រជាជនយើងភាគច្រើនមិនសូវយល់ដឹងអំពីការចែងចែកទ្រព្យសម្បត្តិ និងនីតិវិធីនៃការបែងចែកទ្រព្យសម្បត្តិ ទាល់តែមានបញ្ហាប្រឈមទើបរត់រកមេធាវី ឬអ្នកដែលធ្វើការទាក់ទងនិងរឿងនេះហើយវាអាចមានផលអវិជ្ជមានណាមួយកើតឡើងប្រសិនបើភាគីណាមួយចង់កេងចំណេញយកទ្រព្យសម្បត្តិច្រើនជាងភាគីម្ខាងទៀត។

យើងខ្ញុំទាំងពីរនាក់សង្ឃឹមថា សារណាដែលបានចងក្រងនេះអាចឱ្យមិត្តអ្នកអានទទួលបាននូវចំណេះដឹងថ្មីៗបន្ថែម ក៏ដូចជាជួយដល់ការសិក្សាស្រាវជ្រាវរបស់សិស្សប្អូនជំនាន់ក្រោយនិងប្រជាពលរដ្ឋខ្មែរ គ្រប់រូបដែលមានបំណងចង់ដឹងអំពីប្រភេទ និងនីតិវិធីនៃការបែងចែកប្រពន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ ដែលមានកំណត់នៅក្នុងសេចក្តីប្រកាសលេខ៨១នៃនីតិវិធីកិច្ចសន្យាប្តីប្រពន្ធ ក៏ដូចជាក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ ចំពោះឯកសារនេះដែរ នឹងត្រូវបានរក្សាទុកជាស្នាដៃដល់អ្នកសិក្សាជំនាន់ក្រោយ ដែលមានបំណងចង់សិក្សាស្វែងយល់យ៉ាងស៊ីជម្រៅ ដើម្បីជាគន្លឹះក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទមួយនេះ។

ជាចុងក្រោយយើងខ្ញុំក៏សូមខន្តីអភ័យទោសផងដែរ នៅរាល់ចំណុចខ្វះខាតមួយចំនួនដែលទាក់ទៅនឹងពាក្យពេចន៍មួយចំនួន ខ្លឹមសារអត្ថន័យដែលកើតមាននៅក្នុងឯកសារចងក្រងនេះ ដោយអចេតនា ហើយយើងខ្ញុំសូមស្វាគមន៍ជានិច្ចចំពោះការរិះគន់ផ្សេងៗ ដើម្បីយកមកកែលំអរឱ្យកាន់តែប្រសើរឡើង។

# មាតិកា


សេចក្តីផ្តើម ........................................................................................................... ១

ជំពូកទី១
ប្រព័ន្ធទ្រព្យសម្បត្តិរបស់សហព័ទ្ធដែលកំណត់ដោយច្បាប់

ផ្នែកទី១ ខ្លឹមសារនៃប្រព័ន្ធទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ................................................. ៥

១.១. ទ្រព្យសម្បត្តិដោយឡែករបស់ប្តីប្រពន្ធ ........................................................................ ៥

១.១.១. ទ្រព្យសម្បត្តិដែលទទួលបានមុនពេលរៀបអាពាហ៍ពិពាហ៍.............................................៥

១.១.២. ទ្រព្យសម្បត្តិដែលទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍.........................................៧

១.១.៣. ទ្រព្យសម្បត្តិដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដោយឡែក..............................៨

១.២. ទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ..................................................................................... ៩

១.២.១. ទ្រព្យសម្បត្តិទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍................................................ ៩

១.៣. ចំណែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍ .................................................................. ១០

១.៣.១. ការទទួលខុសត្រូវចំណាយក្នុងពេលអាពាហ៍ពិពាហ៍ ..................................................១២

ផ្នែកទី២ សិទ្ធិ និងការទទួលខុសត្រូវរបស់សហព័ទ្ធ.....................................................១៣

២.១. សិទ្ធិ ក្នុងការគ្រប់គ្រង និងចាត់ចែងលើទ្រព្យសម្បត្តិប្តីប្រពន្ធ............................................. ១៥

២.១.១. ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិដោយឡែក.....................១៥

២.១.២. សិទ្ធិលើចំណូលបានមកពីទ្រព្យសម្បត្តិដោយឡែក....................................................១៦

២.១.៣. ការស្នាក់អាស្រ័យនៅរបស់ប្តីឬប្រពន្ធលើទ្រព្យសម្បត្តិដោយឡែក ................................១៧

២.១.៤. កម្មសិទ្ធិលើកំណើនទ្រព្យសម្បត្តិរួម ឬទ្រព្យសម្បត្តិដោយឡែក ..................................... ១៩

២.១.៥. សិទ្ធិគ្រប់គ្រងលើទ្រព្យសម្បត្តិក្នុងពេលមានអាពាហ៍ពិពាហ៍ ........................................២០

២.១.៦. ការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ ..............................................................២១

២.២. ការទទួលខុសត្រូវលើបំណុល និងកាតព្វកិច្ចផ្សេងៗទៀត...............................................២២

២.២.១. ការទទួលខុសត្រូវដោយសាមគ្គីភាព ចំពោះកាតព្វកិច្ច........................................... ២៣

# ជំពូកទី២

# ប្រព័ន្ធទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមកិច្ចសន្យា

**ផ្នែកទី១ សញ្ញាណទូទៅនៃប្រព័ន្ធទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធតាមកិច្ចសន្យា...... ២៦**

១.១. ការវិវត្តនៃប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា........ ២៦

១.១.១. ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធនៅមុនការអនុវត្តក្រមរដ្ឋប្បវេណី........ ២៧

១.១.២. ប្រព័ន្ធទ្រពសម្បត្តិប្តីប្រពន្ធ ក្រោយការអនុវត្តក្រមរដ្ឋប្បវេណី ........ ២៨

១.២. គោលគំនិតនៃការបង្កើតប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា ........២៩

១.២.១. ការពារផលប្រយោជន៍របស់សហព័ទ្ធ........២៩

១.២.២. កំណត់លើទំនាក់ទំនងកាតព្វកិច្ច និងសិទ្ធិលើបំណុល ........២៩

១.២.៣. កំណត់ពីសិទ្ធិគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិ........ ៣០

១.២.៤. សម្រួលនីតិវិធីដោះស្រាយរបស់តុលាការ........ ៣០

**ផ្នែកទី២ លក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ........៣១**

២.១. លក្ខខណ្ឌគ្រឹះនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ........ ៣២

២.១.១. ការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ........ ៣៥

២.១.២. ការព្រមព្រៀងក្នុងការបង្ហាញឆន្ទៈ ........ ៣៥

២.១.៣. សមត្ថភាពរបស់ភាគី(សហព័ទ្ធ)........ ៣៥

២.១.៤. កម្មវត្ថុ........៣៦

២.២. លក្ខខណ្ឌទម្រង់នៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ........ ៣៧

២.២.១. ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ........ ៣៧

២.២.២. នីតិវិធីនៃការចេញលិខិតបញ្ជាក់ ........៤៩

២.៣. អនុភាពនៃប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា........៥០

២.៣.១. អនុភាពនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ........៥០

# ជំពូកទី៣
# ការបែងចែកទ្រព្យសម្បត្តិ និងកាតព្វកិច្ចរបស់សហព័ទ្ធ


**ផ្នែកទី១ ការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះ**........................................៥៤

១.១. ការបែងចែកទៅតាមការចែងនៅក្នុងកិច្ចសន្យា........................................៥៥

១.២. ការបែងចែកទ្រព្យសម្បត្តិដោយការព្រមព្រៀងគ្នា........................................៥៥

១.៣. ការបែងចែកទ្រព្យសម្បត្តិដោយតុលាការ........................................៥៧

១.៣.១. តួនាទីនៅក្នុងបណ្តឹងសុំលែងលះ........................................៥៧

១.៣.២. គោលការណ៍សមាមាត្រនៃចំណែក និង ករណីពិសេស........................................៥៧

១.៣.៣. នីតិវិធីសម្រាប់ដំណើរការបែងចែកទ្រព្យសម្បត្តិដោយតុលាការ........................................៥៩

១.៣.៤. អានុភាពនៃការលែងលះចំពោះទ្រព្យសម្បត្តិ........................................៦៧

**ផ្នែកទី២ ការបែងចែកកាតព្វកិច្ចបំណុលក្រោយពេលលែងលះគ្នា**........................................៧១

២.១. ការសម្គាល់បំណុល........................................៧១

២.២. ការចាត់ប្រភេទបំណុល........................................៧២

២.៣. ការសងបំណុលមុនសម្រេចបែងចែកទ្រព្យសម្បត្តិ........................................៧៣

២.៤. ការចែករំលែកកាតព្វកិច្ចលើបំណុល........................................៧៣

**សេចក្តីសន្និដ្ឋាន**........................................៧៤

**អនុសាសន៍**........................................៧៤

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ជាទូទៅនៅក្នុងទំនាក់ទំនងការរស់នៅប្រចាំថ្ងៃរបស់ប្តីប្រពន្ធ ការប្រាស្រ័យទាក់ទងគ្នា គឺជាការសំខាន់ និងជាកត្តាចាំបាច់បំផុតដែលមនុស្សម្នាក់ៗជៀសមិនផុតអំពីទំនាក់ទំនងនេះឡើយ។ ម្យ៉ាងវិញទៀតនៅក្នុងការប្រាស្រ័យទាក់ទងគ្នាក្នុងគ្រួសារ សហព័ទ្ធម្នាក់ៗរមែងតែងតែប្រព្រឹត្តនៅកំហុសដែលជាមូលហេតុចម្បង ធ្វើឱ្យមានជម្លោះកើតឡើង។ បើយើងសង្កេតមើលទៅលើការដោះស្រាយបញ្ហាជម្លោះ ឬវិវាទក្នុងគ្រួសារវិញ ក្រៅពីការចរចារ សម្រុះសម្រួលគ្នា បទដ្ឋានគតិយុត្តិ និងបទបញ្ញត្តិផ្សេងៗទៀត ត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ អាស្រ័យទៅលើតម្រូវការ និងបរិបទនៃសង្គម ដើម្បីស្វែងរកនូវដំណោះស្រាយដ៏សមស្រប និងប្រកបទៅដោយប្រសិទ្ធភាពណាមួយ។

កាលពីសម័យមុន ការគ្រប់គ្រងទ្រព្យសម្បត្តិប្តីប្រពន្ធ មានលក្ខខណៈជាទំនៀមទម្លាប់ដែលចាស់ៗពីដើមមានផ្នត់គំនិតថា បន្ទាប់ពីរៀបអាពាហ៍ពិពាហ៍រួច ប្រពន្ធជាអ្នករៀបចំទុកដាក់ធ្វើកិច្ចការផ្ទះ មានភារៈកិច្ចមើលថែទាំកូននៅផ្ទះ។ រីឯប្តីជាមេគ្រួសារជាអ្នករកចំណូលដើម្បីផ្គត់ផ្គង់នៅក្នុងគ្រួសារ។ ប្រពន្ធគ្មានសិទ្ធិសម្រេចចិត្ត បញ្ចេញមតិយោបល់ទៅលើរឿងអ្វីមួយដោយគ្មានការអនុញ្ញាតពីប្តីនោះទេ។ ប៉ុន្តែនាពេលបច្ចុប្បន្នផ្នត់គំនិតបែបនេះមានតិចតួចណាស់ គឺចំពោះមនុស្សមួយចំនួនតូចដែលនៅប្រកាន់ខ្ជាប់នូវទំនៀមទម្លាប់ពីដើម។ ការគ្រប់គ្រងបែបនេះ អាចមានបញ្ហានៅពេលមានជម្លោះ ភាគច្រើនលើករឿងលុយកាក់ ប្តីតែងតែថា ប្រពន្ធនៅតែផ្ទះមិនបានធ្វើការរកលុយ ប្តីចង់ធ្វើអ្វីក៏បានព្រោះវាជាលុយដែលប្តីខំរកបានមិនមែនលុយប្រពន្ធអ្នករក។ ម្យ៉ាងវិញទៀតធ្វើបែបនេះវាផ្ទុយពីខ្លឹមសាររដ្ឋធម្មនុញ្ញចែងថាប្រពន្ធមានសិទ្ធិទទួលបានប្រាក់ចំណូពាក់កណ្តាលរបស់ប្តីដែលជាអ្នករកប្រាក់ចំណូលពីខាងក្រៅផ្ទះដែរ ទោះបីជាប្រពន្ធជាអ្នកមើលកូន និងធ្វើកិច្ចការផ្ទះក៏ដោយ។

ជាធម្មតានៅពេលដែលមានចំណងអាពាហ៍ពិពាហ៍មួយបានកើតឡើង វាក៏មានការបញ្ចប់ចំណងអាពាហ៍ពិពហ៍ទៅវិញដែរ តើការលែងលះធ្វើឱ្យជះឥតទ្ធិពលបែបណាខ្លះដល់ទំនាក់ទំនងទ្រព្យសម្បត្តិប្តីប្រពន្ធ?

ការបង្កើតអាពាហ៍ពិពាហ៍មួយ នាំឱ្យមានចំណងគតិ្តយុត្តទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ផ្នែកទី៣ ស្តីពីប្រព័ន្ធទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ ក្នុងជំពូកទី៣ ទាក់ទងនឹងអាពាហ៍ពិពាហ៍ នៃគន្ថីទី៧ ស្តីអំពីទំនាក់ទំនងញាតិ។ ដែលបញ្ញត្តិអំពីប្រព័ន្ធទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ រួមមានៈ ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់តាមច្បាប់ និងប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា។ ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់តាមច្បាប់មានពីរប្រភេទគឺ ទ្រព្យសម្បត្តិរួម និងទ្រពសម្បត្តិដោយឡែក។ ស្តីអំពី ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ ជាមូលដ្ឋានរួមមានៈ ទ្រពសម្បត្តិដោយឡែក (Separate Property System) គឺជាប្រព័ន្ធដែលមិនធ្វើឱ្យមានផលប៉ះពាល់ដល់ទំនាក់ទំនងទ្រព្យសម្បត្តិរបស់ប្រពន្ធទេ ទោះបីជាបានរៀបអាពាហ៍ពិពាហ៍ក៏ដោយ និង ប្រព័ន្ធទ្រព្យរួម (Community Property System) គឺជាប្រព័ន្ធ

ដែលនឹងមានផលប៉ះពាល់ទៅដល់ទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធនៅក្រោយរៀបអាពាហ៍ពិពាហ៍ ហើយទ្រព្យទាំងនោះត្រូវក្លាយជាទ្រព្យរួម។

នៅក្នុងប្រព័ន្ធទ្រព្យដោយឡែក ជាគោលការណ៍ ប្តីប្រពន្ធមានកម្មសិទ្ធិ និង ការគ្រប់គ្រងលើទ្រព្យសម្បត្តិរបស់ខ្លួនរៀងៗខ្លួន។ គេនិយាយថា ប្រព័ន្ធទ្រព្យដោយឡែក បានធានានូវភាពឯករាជនៃទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ ហើយធ្វើឱ្យទំនាក់ទំនងគតិយុត្តនៃទ្រព្យមានភាពច្បាស់លាស់ ហើយធ្វើឱ្យមានសុវត្ថិភាពលើកិច្ចការជំនួញ។ ផ្ទុយមកវិញក៏មានការរិះគន់ដែរថា ប្រព័ន្ធនេះមិនអាចឆ្លុះបញ្ចាំងឱ្យឃើញនូវទំនាក់ទំនងនៃការសហការគ្នាខាងផ្នែកសេដ្ឋកិច្ចរបស់ប្តីប្រពន្ធ និង ភាពតែមួយនៃផ្នែកសេដ្ឋកិច្ចរបស់ប្តីប្រពន្ធខ្លាំងពេក ហើយមិនអាចវាយតម្លៃបានអំពីការងារដែលប្រពន្ធត្រូវជួយគាំទ្រទៅប្តី។

ចំណែកប្រព័ន្ធទ្រព្យសម្បត្តិរួម គឺជាប្រព័ន្ធដែលទទួលស្គាល់អំពីអត្ថិភាពនៃទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ តាមរយៈអាពាហ៍ពិពាហ៍ក្នុងទំហំមួយដែលបានកំណត់ ហើយនៅពេលដែលអាពាហ៍ពិពាហ៍រលាយ នឹងត្រូវយកទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធមកធ្វើការបែងចែក។ ផ្ទុយទៅវិញចំពោះប្រព័ន្ធទ្រព្យរួម គឺជាប្រព័ន្ធដែលធ្វើឱ្យអាចសម្រេចនូវការវាយតម្លៃអំពីភាពស្មើភាពគ្នា និងភាពតែមួយនៃផ្នែកសេដ្ឋកិច្ចរបស់ប្តីប្រពន្ធបាន ប៉ុន្តែ គុណវិបត្តិនៃប្រពន្ធនេះគឺ ធ្វើឱ្យទំនាក់ទំនងគតិយុត្តមានភាពស្មុគស្មាញ ហើយធ្វើឱ្យប៉ះពាល់ដល់ទំនាក់ទំនងជាមួយតតិយជន និងសុវត្ថិភាពនៃកិច្ចការជំនួញ។ ដូច្នេះហើយ ទោះបីជាចាប់ផ្តើមពីប្រព័ន្ធមួយណាក៏ដោយ ក៏ប្រព័ន្ធទាំងពីរនេះ នៅតែមានផលវិបាកម្យ៉ាងម្នាក់ដែរ។

ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា ពោលគឺជាប្រព័ន្ធទ្រព្យសម្បត្តិដែលផ្តល់សិទ្ធិ និងសេរីភាពដល់ (១) ប្តីប្រពន្ធអាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិនៅមុន ឬក្រោយអាពាហ៍ពិពាហ៍បាន។ ប៉ុន្តែ កិច្ចសន្យានេះមិនអាចធ្វើផ្ទុយនឹងបញ្ញត្តិស្តីពីសិទ្ធិទាមទារអាហារកាតព្វកិច្ចនិងភាគបម្រុងបានឡើយ។ (២) នៅពេលដែលមិនបានធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធទេ និងត្រូវអនុលោមតាមប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ (CCកម្ពុជា មាត្រា៩៦៩)។ ក្រមរដ្ឋប្បវេណីនេះបានទទួលស្គាល់នូវសេរីភាពនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធក៏ពិតមែន ប៉ុន្តែ បានកម្រិតនូវអានុភាពនៃកិច្ចសន្យាដែលមានខ្លឹមសារបោះបង់នូវអាហារកាតព្វកិច្ច រវាងប្តីប្រពន្ធ ឬសិទ្ធិលើទ្រព្យសម្បត្តិដែលជាសិទ្ធិសំខាន់ចំពោះប្តីប្រពន្ធ។[1] លើសពីនេះទៅទៀត ដើម្បីឱ្យមានភាពងាយស្រួលក្នុងការសិក្សាប្រធានបទមួយនេះឱ្យកាន់តែ ច្បាស់ និងស៊ីជម្រៅ យើងខ្ញុំសូមលើកយកតែពីរប្រភេទ និងខ្លឹមសារនៃប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ យន្តការនៃការជម្រះបញ្ជីនៅពេលចំណងអាពាហ៍ពិពាហ៍ត្រូវបានរំលាយ និងបែបបទនីតិវិធីនៃការកំណត់បែងចែកទ្រព្យសម្បត្តិពេលលែងលះប៉ុណ្ណោះ មកលើការស្រាវជ្រាវលើប្រធានបទមួយ

[1] Professor of Law, Waseda Universit (Massayuki Tanamura)

នេះ បានធ្វើឱ្យយើងខ្ញុំយល់កាន់តែ ច្បាស់ពីការកំណត់នូវប្រព័ន្ធទ្រព្យសម្បត្តិរវាងសហព័ទ្ធទាំងពីរ។ ចំណែកឯប្រភពឯកសារជំនួយស្មារតីរបស់ពួកយើងខ្ញុំក្នុងការចងក្រងប្រធានបទមួយនេះ គឺក្រុមយើងខ្ញុំ ស្រាវជ្រាវបានមកពីច្បាប់ និងលិខិតបទដ្ឋានផ្សេងៗនៃក្រសួងយុត្តិធម៌ ក្រមរដ្ឋប្បវេណី២០០៧ ច្បាប់ស្តីពីការ អនុវត្តក្រមរដ្ឋប្បវេណី២០១១ និងកម្រងមេរៀនពីលោក លោកស្រីសាស្ត្រាចារ្យ ព្រមទាំងតាមបណ្ណាបណ្ណាល័យ ផ្សេងៗជាច្រើនទៀត។ ក្រៅពីឯកសារដែលបានរៀបរាប់ខាងលើ ឯកសារមួយចំនួន យើងខ្ញុំបានស្រាវជ្រាវចេញ ពីប្រព័ន្ធអ៊ីនធឺណេតផងដែរ។ បន្ទាប់ពីយើងខ្ញុំទទួលបានឯកសារគ្រប់គ្រាន់ហើយ យើងខ្ញុំបានសិក្សាស្វែងយល់ទៅលើឯកសារទាំង នោះ ហើយបានបែងចែកចំណាត់ថ្នាក់នៃឯកសារនីមួយៗ ដាក់ទៅជាបណ្តុំ ទើបបង្កើតបានជាប្លង់សារណានិង ដាក់ជូនលោកសាស្ត្រាចារ្យធ្វើការពិនិត្យ និងកែសម្រួល។ ក្រោយពេលឆ្លងកាត់នូវការត្រួតពិនិត្យចប់សព្វគ្រប់ យើងខ្ញុំទទួលបាននូវប្លង់ជាស្ថាពរមួយ ដែលនៅក្នុងនោះបានបែងចែកជា បីជំពូក ដូចខាងក្រោមនេះ៖ ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធដែលកំណត់តាមច្បាប់ (ជំពូកទី១) ប្រព័ន្ធទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមកិច្ចសន្យា (ជំពូកទី២) ការបែងចែកទ្រព្យសម្បត្តិ និងកាតព្វកិច្ចរបស់សហព័ទ្ធ (ជំពូកទី៣)។

# ជំពូកទី១

# ប្រព័ន្ធទ្រព្យសម្បត្តិរបស់សហព័ទ្ធដែលកំណត់ដោយច្បាប់

# ជំពូកទី១
# ប្រព័ន្ធទ្រព្យសម្បត្តិរបស់សហព័ទ្ធដែលកំណត់ដោយច្បាប់

ប្ដីប្រពន្ធនៅពេលដែលរៀបអាពាហ៍ពិពាហ៍ តែងតែមានទ្រព្យសម្បត្តិមុនពេលអាពាហ៍ពិពាហ៍ និង ក្រោយពេលរៀបអាពាហ៍ពិពាហ៍។ ជាការពិតណាស់នៅពេលចំណងអាពាហ៍ពិពាហ៍បានកើតឡើត នាំឱ្យមាន ទំនាក់ទំនងទៅលើទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធ។ នៅក្នុងសង្គមយើងជាក់ស្ដែង ភាគច្រើនគេប្រើប្រាស់ទៅលើ ប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធដែលកំណត់ដោយច្បាប់ ព្រោះថានៅមិនទាន់មានអ្នកប្រើប្រាស់នូវប្រព័ន្ធទ្រព្យសម្បត្តិ តាមកិច្ចសន្យាទេ។ ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ បានកំណត់អំពីប្រភេទទ្រព្យសម្បត្តិ ដូចជាចំ ណាត់ថ្នាក់នៃទ្រព្យសម្បត្តិ ការកំណត់អំពីសិទ្ធិ និងករណីយកិច្ចក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ និងការបញ្ចប់នៃ របបនេះ។ នៅក្នុងរបបនៃការគ្រប់គ្រងទ្រព្យសម្បត្តិតាមច្បាប់កំណត់ គឺមានការលាយឡំគ្នារវាងទ្រព្យសម្បត្តិ ទាំងឡាយណា ដែលភាគីនីមួយៗជាកម្មសិទ្ធិករលើទ្រព្យសម្បត្តិនោះ។ ហេតុនេះហើយទើបមានការបែងចែក ទ្រព្យរបស់សហព័ទ្ធជាពីរ គឺទ្រព្យសម្បត្តិដោយឡែក និងទ្រព្យសម្បត្តិរួម។ ទំនាក់ទំនងរវាងទ្រព្យសម្បត្តិប្ដីប្រពន្ធ គឺជាវិធានមួយដែលកំណត់ដោយច្បាប់ ហើយក៏មានលក្ខណៈខុសគ្នាទៅតាមវប្បធម៌របស់ប្រទេសនីមួយៗផង ដែរ។

ប្រព័ន្ធទ្រព្យសម្បត្តិកំណត់ដោយច្បាប់ ពេលដែលមានចំណងអាពាហ៍ពិពាហ៍កើតឡើង បានជះឥទ្ធិ ពលដល់ទំនាក់ទំនងទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធ ក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ និងនៅពេលលែង លះ។ ចំពោះការប្រើប្រាស់ និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធ សហព័ទ្ធម្ខាងអាចទាមទារចំពោះភាគីម្ខាង ទៀត ឱ្យធ្វើការចាត់ចែងនិងគ្រប់គ្រងទ្រព្យសម្បត្តិ និងរក្សាទុកនូវទ្រព្យសម្បត្តិរួមបាន។ ប្រសិនបើប្ដីប្រពន្ធមិន អាចពិគ្រោះយោបល់គ្នាអំពីការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិរួមភាគីម្ខាងណាមួយអាចទាមទារទៅតុលា ការឱ្យធ្វើការចាត់ចែងចំពោះការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិរួមបាន ដើម្បីដោះស្រាយវិវាទលើការគ្រប់ គ្រងទ្រព្យសម្បត្តិរវាងប្ដីប្រពន្ធ។

ដូច្នេះដើម្បីស្វែងយល់ឱ្យកាន់តែស៊ីជម្រៅទាក់ទងនឹងប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធដែលកំណត់ដោយ ច្បាប់នេះ យើងគប្បីសិក្សាអំពី ខ្លឹមសារនៃប្រព័ន្ធទ្រព្យសម្បត្តិរបស់ប្ដីប្រព័ន្ធ (ផ្នែកទី១) សិទ្ធិ និងការទទួលខុសត្រូវ របស់សហព័ទ្ធ(ផ្នែកទី២) ជាមុនសិន។

## ផ្នែកទី១ ខ្លឹមសារនៃប្រព័ន្ធទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធ

ប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធ គឺជាប្រព័ន្ធទ្រព្យសម្បត្តិមួយដែលបានកំណត់អំពីទ្រព្យសម្បត្តិរបស់សហព័ទ្ធនីមួយៗដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍ និងក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ជាទ្រព្យសម្បត្តិដែលប្ដី ឬប្រពន្ធរកបាន ទទួលបានរៀងខ្លួនៗ នឹងទ្រព្យសម្បត្តិដែលប្ដីប្រពន្ធទាំងពីរទទួលបានដោយសហការគ្នា។ តាមរយៈប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធ គេសង្កេតឃើញមានមូលដ្ឋានពីររួមមាន៖ ប្រព័ន្ធទ្រព្យសម្បត្តិដោយឡែក (ផ្ទាល់ខ្លួន) និង ប្រព័ន្ធទ្រព្យសម្បត្តិរួម (ប្ដីប្រពន្ធ)។ ប្រព័ន្ធទ្រព្យសម្បត្តិដោយឡែក ជាប្រព័ន្ធដែលមិនធ្វើឱ្យមានផលប៉ះពាល់ទៅដល់ទំនាក់ទំនងទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធនោះទេ ទោះបីបានរៀបអាពាហ៍ពិពាហ៍ក៏ដោយ។ រីឯប្រព័ន្ធទ្រព្យសម្បត្តិរួមវិញ ជាប្រព័ន្ធដែលនឹងធ្វើឱ្យមានផលប៉ះពាល់ទៅដល់ទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធនៅក្រោយពេលរៀបអាពាហ៍ពិពាហ៍ ហើយទ្រព្យទាំងនេះនឹងក្លាយជាទ្រព្យរួម។

### ១.១. ទ្រព្យសម្បត្តិដោយឡែករបស់ប្ដីប្រពន្ធ

ទ្រព្យសម្បត្តិដោយឡែក គឺជាទ្រព្យសម្បត្តិដែលស្ថិតនៅក្រោមកម្មសិទ្ធិរបស់សហព័ទ្ធណាម្នាក់ ដែលសហទ័ព្ធមានមុនពេលរៀបអាពាហ៍ពិពាហ៍ ទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបានដោយ ប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍ និងទ្រព្យសម្បត្តិដែលជាតម្លៃតបដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិខាងលើនេះ ( ទ្រព្យសម្បត្តិដែលទទួលបានមានមុនពេលរៀបអាពាហ៍ពិពាហ៍ ឬទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបានដោយ ប្រទានកម្ម សន្តតិកម្ម ឬ អច្ច័យទាន នៅក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍ )។[2] ចំពោះទ្រព្យសម្បត្តិប្ដីប្រពន្ធដែលទទួលបានមុនពេលរៀបអាពាហ៍ពិពាហ៍ គឺជាទ្រព្យសម្បត្តិដោយឡែករបស់ប្ដី ឬប្រពន្ធ ដែលជាទ្រព្យផ្ទាល់ខ្លួន។ សហព័ទ្ធម្នាក់ៗ មានសិទ្ធិពេញលេញក្នុងការប្រើប្រាស់ អាស្រ័យផល និងចាត់ចែងទ្រព្យផ្ទាល់របស់ខ្លួន។[3]

#### ១.១.១. ទ្រព្យសម្បត្តិដែលទទួលបានមុនពេលរៀបអាពាហ៍ពិពាហ៍

ទ្រព្យសម្បត្តិដែលសហព័ទ្ធណាម្ខាងមានមុនពេលរៀបអាពាហ៍ពិពាហ៍ សំដៅលើទ្រព្យសម្បត្តិទាំងឡាយណាដែលសហព័ទ្ធណាម្ខាងបង្កើតឡើងតាមរយៈ ការប្រកបរបរការងារ ឬជាទ្រព្យដែលសហព័ទ្ធទទួលបានពីប្រទានកម្ម សន្តតិកម្ម និងអច្ចយ័ទានជាអាទិ៍មុនពេលរៀបអាពាហ៍ពិពាហ៍។ ហើយទ្រព្យសម្បត្តិដែលទទួលបានមុនពេលរៀបអាពាហ៍ពិពាហ៍ មិនអាចក្លាយជាទ្រព្យរួមបានដែរ ព្រោះវាជាកម្មសិទ្ធរបស់ប្ដី ឬប្រពន្ធដែលទទួលបានមុនពេលដែលក្លាយជាប្ដីប្រពន្ធស្របច្បាប់។ ដូច្នេះប្រសិនបើវាក្លាយជាទ្រព្យរួមនោះវាមិនអយុត្តិធម៌សម្រាប់

[2] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៧២ ។

[3] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៧៥។
និង ច្បាប់ស្ដីពីអាពាហ៍ពីពាណ៍ និង គ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា ៣៤។

សហព័ទ្ធណាម្ខាង ព្រោះវាជាកម្មសិទ្ធិផ្ទាល់ខ្លួនរបស់សហព័ទ្ធណាម្នាក់ ដោយគាត់ចង់ចាត់ចែងយ៉ាងមេចក៏បាន អាស្រ័យលើឆន្ទៈរបស់គាត់។

ឧទាហរណ៍៖ នារីមានម៉ូតូមួយគ្រឿង និងខ្សែកមាស២ ដំឡឹង ដែលជាអំណោយរបស់ឪពុករបស់គាត់។ រីឯ បញ្ញា មានផ្ទះល្វែងដែលមានតម្លៃ ៥០០០០ ដុល្លាអាមេរិក និងមានចម្ការកៅស៊ូ ចំនួនពីរហិចតា ដែលគាត់បានទិញដោយលុយផ្ទាល់ខ្លួនគាត់ ។ ក្រោយមកនារី និង បញ្ញា ក៏បានរៀបអាពាហ៍ពិពាហ៍និងគ្នាស្របច្បាប់ ដូច្នេះទោះបីជាពួកគេទាំងពីបានក្លាយជាប្តីប្រពន្ធនឹងគ្នាក៏ដោយ ក៏ទ្រព្យសម្បត្តិដែលពួកគាត់មាននៅមុនពេលរៀបអាពហ៍ពិពាហ៍នៅតែជាទ្រព្យដោយឡែករបស់គាត់ដដែលដូចជា ម៉ូតូមួយគ្រឿង និងខ្សែកមាស ២ ដំលឹង គឺជាទ្រព្យដោយឡែករបស់នារី ចំណែកឯផ្ទះល្វែងដែលមានតម្លៃ ៥០០០០ ដុល្លាអាមេរិក និងមានចម្ការកៅស៊ូ ចំនួនពីរហិចតា គឺជាទ្រព្យដោយឡែករបស់បញ្ញាដដែល។

ម្យ៉ាងវិញទៀត ចំពោះទ្រព្យសម្បត្តិដែលមានលក្ខណៈពិសេស ដូចជា មូលនិធិពាណិជ្ជកម្ម (ឧទាហរណ៍ អាជីវកម្មភោជនីយដ្ឋាន ឬ អាជីវកម្មសណ្ឋាគា) គឺចាំបាច់ត្រូវពិនិត្យមើលទៅលើកាលបរិច្ឆេទនៃការបង្កើតមូលនិធិពាណិជ្ជកម្ម ពោលគឺពិនិត្យមើលកាលបរិច្ឆេទនៃការបើកហាងទទួលអតិថិជន។

ឧទាហរណ៍៖ នៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២ លោក សំខាន់ បានរៀបចំបើកភោជនីយដ្ឋានមួយកន្លែង (មូលនិធិពាណិជ្ជកម្ម)។ លុះដល់ថ្ងៃទី ០២ ខែ មេសា ឆ្នាំ២០១២ លោក សំខាន់ បានជួលដីមួយកន្លែង ដើម្បីបើកភោជនីយដ្ឋាន ជួលបុគ្គលិកបម្រើការងារ ព្រមទាំងទិញសម្ភារៈផ្សេងៗទៀតសម្រាប់ប្រើប្រាស់ក្នុងភោជនីយដ្ឋាន។ រហូតមកដល់ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១២ លោក សំខាន់ ក៏បានសម្ពោធបើកភោជនីដ្ឋាន បម្រើដល់អតិថិជន។ នៅថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១២ លោក សំខាន់ បានចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយនឹងលោកស្រី ណារី។ យ៉ាងណាមិញ ភោជនីយដ្ឋាននេះ ត្រូវបានបង្កើតឡើងថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១២ ពោលគឺមុនពេលដែលលោក សំខាន់ បានរៀបការជាមួយលោកស្រី ណារី។ ដូច្នេះ ភោជនីយដ្ឋាននោះ គឺជាទ្រព្យសម្បត្តិដោយឡែករបស់លោក សំខាន់។ ប៉ុន្តែ ចំពោះផលចំណេញដែលបានកមពីអាជីវកម្មភោជនីយដ្ឋាន គិតចាប់ពីថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១២ រហូតដល់ពេលរំលាយអាពាហ៍ពិពាហ៍ គឺជាទ្រព្យសម្បត្តិរួម។[4]

[4] នីតិព្រហ្មទណ្ឌ និង គ្រួសារ, រុន ពណ្ណារឹទ្ធ, ចាំង ស៊ីណាត, ២០១៧, ទំព័រទី ៣៥៣។

### ១.១.២. ទ្រព្យសម្បត្តិដែលទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍

ក្នុងកំឡុងពេលរៀបអាពាហ៍ពិពាហ៍ ប្រសិនបើប្ដី ឬប្រពន្ធណាម្នាក់ទទួលបានទ្រព្យសម្បត្តិ ពីប្រទានកម្ម សន្តតិកម្ម ឬអច្ច័យទាន ទ្រព្យសម្បត្តិនោះនឹងក្លាយជាទ្រព្យផ្ទាល់ខ្លួនរបស់សហព័ទ្ធ។ ដូច្នេះថាតើប្រព័ន្ធទ្រព្យសម្បត្តិទទួលបានពីប្រទានកម្ម សន្តតិកម្ម ឬអច្ច័យទានមានខ្លឹមសារយ៉ាងណានោះ សូមមើលទៅអត្ថបទខាងក្រោម៖

- **ប្រទានកម្ម** គឺជាកិច្ចសន្យាមួយដែលត្រូវមានអានុភាព ដោយភាគីម្ខាង (ទាយក) បង្ហាញឆន្ទៈផ្ដល់ទៅឱ្យភាគីម្ខាងទៀត នូវទ្រព្យសម្បត្តិដោយមិនគិតថ្លៃ ហើយភាគីម្ខាងទៀត (បដិគ្គាហក) យល់ព្រមទទួល។[5]

ឧទាហរណ៍៖ ក្រោយពីរៀបការជាមួយនឹងលោកស្រី ណារី បានប្រហែលជាមួយខែ ម្ដាយមីង (ហៅទាយក) របស់លោក សំខាន់ បានប្រគល់ ផ្ទះមួយល្វែងឱ្យលោក សំខាន់ (ហៅថា បដិគ្គាហក)។ ក្នុងករណីបែបនេះ ទោះបីជាប្រទានកម្មបានធ្វើក្នុងអំឡុងពេលដែលលោក សំខាន់ កំពុងតែមានចំណងអាពាហ៍ពិពាហ៍ជាមួយនឹង ណារីក៏ដោយក៏ផ្ទះមួយល្វែងនេះ ត្រូវចាត់ទុកជា ទ្រព្យសម្បត្តិដោយឡែករបស់លោក សំខាន់ ដែរ។

សូមធ្វើការកត់សម្គាល់ថា ប្រសិនបើទាយកធ្វើប្រទានកម្មឱ្យសហព័ទ្ធទាំងសងខាង គួរចាត់ទុកថាជាទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធ។ យ៉ាងណាមិញ ប្រសិនបើទាយកមិនបានបង្ហាញឆន្ទៈច្បាស់លាស់វិញ គេត្រូវពិនិត្យមើលទៅលើ ស្ថានភាពជាក់ស្ដែងនៃការធ្វើប្រទានកម្មនោះ។

ឧទាហរណ៍៖ នៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍រវាងលោក សំខាន់ និង លោកស្រី ណារី ម្ដាយមីងរបស់លោក សំខាន់ បានចងដៃនូវរថយន្តមួយគ្រឿង។ ក្នុងស្ថានភាពបែបនេះគួរចាត់ទុកថា រថយន្តនោះគឺជាទ្រព្យសម្បត្តិរួម ពីព្រោះថា ការចងដៃ គឺ សម្រាប់ទាំងពីរនាក់ មិនមែនសម្រាប់តែកូនក្រមុំ ឬ កូនកម្លោះនោះទេ។

- **សន្តតិកម្ម** គឺជារបៀបនៃការផ្ទេរមរតកតាមការកំណត់របស់ច្បាប់ ពីមតកជន (អ្នកស្លាប់) មកឱ្យសន្តតិជន។[6]

ឧទាហរណ៍៖ ក្រោយពីលោក សំខាន់ រៀបការជាមួយនឹងលោកស្រី ណារី បានប្រហែលជាមួយខែ ឪពុក (មតកជន) របស់លោក សំខាន់ បានស្លាប់បាត់បង់ជីវិត។ ក្នុងករណីបែបនេះ គឺមានតែលោក សំខាន់ ប៉ុណ្ណោះដែលជា សន្តតិជន (អ្នកមានសិទ្ធិទទួលសន្តតិកម្ម ឬ មរតក) ចំណែកឯលោកស្រី ណារី វិញ មិនមែនជាសន្តតិជនទេ តាមច្បាប់ស្ដីពីសន្តតិកម្ម។ ឧបមាថា ក្នុងនាមជាសន្តតិជន លោក សំខាន់ ទទួលបានមរតកពីឪពុកនូវដីមួយកន្លែង និង ប្រាក់ចំនួន ២០ ម៉ឺនដុល្លារ។ ដូច្នេះ ដីមួយកន្លែង និង ប្រាក់ចំនួន ២០ ម៉ឺនដុល្លារនេះ គឺជាទ្រព្យ

[5] សទ្ទានុក្រម ក្រមរដ្ឋប្បវេណី, ០៨ ធ្នូ ២០០៧, លេខរៀង ៩៩។

[6] សទ្ទានុក្រម ក្រមរដ្ឋប្បវេណី, ០៨ ធ្នូ ២០០៧, លេខរៀង ១៤៣។

សម្បត្តិដោយឡែករបស់លោក សំខាន់ ទោះបីជាគាត់ទទួលបាន នៅក្នុងពេលដែលគាត់មានចំណង អាពាហ៍ពិពាហ៍ជាមួយនឹងលោកស្រីណារីក៏ដោយ។

- **អច្ច័យទាន** គឺជាប្រទានកម្មដែលម្ចាស់បណ្តាំធ្វើទៅឱ្យមនុស្សម្នាក់ ឬច្រើននាក់ នូវទ្រព្យសម្បត្តិទាំងអស់ ឬ មួយផ្នែកដែលកំណត់ទៅតាមភាគនោះ (អច្ច័យទានសកល) ឬក៏ជាប្រទានកម្ម ដែលកំណត់ទ្រព្យសម្បត្តិជាក់លាក់ទៅមនុស្សម្នាក់ ឬ ច្រើននាក់(អច្ច័យទានមានកំណត់)។[7]

ឧទាហរណ៍៖ បន្ទាប់ពីលោក សំខាន់ បានរៀបការជាមួយនឹងលោកស្រី ណារី បានមួយឆ្នាំកន្លងផុតទៅ ឪពុកមារបស់លោក សំខាន់ បានស្លាប់បាត់បង់ជីវិត ហើយគាត់បានបន្សល់ទុកនូវបណ្តាំ (មតកសាសន៍) មួយច្បាប់ ដែលមានខ្លឹមសារថា ប្រគល់រថយន្តមួយគ្រឿងម៉ាកតូយូតាឱ្យទៅលោក ក្នុងករណីដូច្នេះបានន័យថា រថយន្តមួយគ្រឿងនេះ គឺជាអច្ច័យទានមានកំណត់ ដែលឪពុកមា (ម្ចាស់បណ្តាំ) បានប្រគល់ទៅឱ្យលោក សំខាន់ (ហៅថា អច្ច័យលាភី ។ ទោះបីជា សំខាន់ ទទួលបានរថយន្ត នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ជាមួយនឹងលោកស្រី ណារី ក៏ដោយ ក៏រថយន្តខាងលើ ត្រូវចាត់ទុកជាទ្រព្យសម្បត្តិដោយឡែករបស់លោក សំខាន់ដែរ។[8]

### ១.១.៣. ទ្រព្យសម្បត្តិដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដោយឡែក

ទ្រពសម្បត្តិដែលទទួលបានពីការចាត់ចែងទ្រព្យដោយឡែក គឺជាទ្រព្យសម្បត្តិដែលជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដោយឡែក។ មានន័យថា ជាផលប្រផលប្រយោជន៍ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដែលយើងទទួលបានមុនពេលរៀបអាពាហ៍ពិពាហ៍ និងតាមរយៈប្រទានកម្ម សន្តតិកម្ម និងអច្ច័យទានក្នុងកំឡុងពេលរៀបអាពាហ៍ពិពាណ៍។[9]

ឧទាហរណ៍៖ លោក ឧត្តម មានដីមួយកន្លែងដែលជាទ្រព្យផ្ទាល់ខ្លួនរបស់គាត់ ដែលគាត់មានមុនពេលរៀបអាពាហ៍ពិពាហ៍ បន្ទាប់ពីគាត់បានរៀបអាពាហ៍ពិពាហ៍ជាមួយលោកស្រី លក្ខិណា រួចគាត់បានលក់ដីនោះ រួចយកលុយទៅទិញផ្ទះមួយល្វែង ដូច្នេះផ្ទះមួយល្វែងនោះគឺនៅតែជាទ្រព្យដោយឡែករបស់ លោក ឧត្តម ដដែល។ ដោយយោងតាមមាត្រា ៩៧២ ចំណុច គ ចែងថា ទ្រពសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដែលត្រូវបានកំណត់នៅក្នុងចំណុច ក និងចំណុច ខ នៃមាត្រានេះ។

[7] សទ្ទានុក្រម ក្រមរដ្ឋប្បវេណី, ០៨ ធ្នូ ២០០៧, លេខរៀង ១៧៧។

[8] នីតិព្រហ្មទណ្ឌ និង គ្រួសារ, រុន ពណ្ណារិទ្ធ, ចាំង ស៊ីណាត, ២០១៧, ទំព័រទី ៣៥៤ ដល់ ៣៥៦។

[9] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៧២, វាក្យខណ្ឌ គ។

## ១.២. ទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ

ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិទាំងឡាយ ដែលប្ដីប្រពន្ធទាំងសងខាង ឬ តែម្ខាង ទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ លើកលែងតែទ្រព្យសម្បត្តិដែលកំណត់ក្នុង ចំណុច ខ និង ចំណុច គ នៃមាត្រា ៩៧២ (ទ្រព្យសម្បត្តិដោយឡែក) ខាងលើនេះ។[10]

ឧទាហរណ៍៖ ធីដា និង សុខាបានរៀនអាពាហ៍ពិពាហ៍និងគ្នាកាលពីឆ្នាំ ២០២០។ កំឡុងពេលរៀបអាពាហ៍ពិពាហ៍ពួកគាត់ទាំងពីរបានប្រកបរបររកស៊ីជាមួយជាគ្នា ដោយបណ្ដាក់ទុន ម្នាក់ ៣០០០ដុល្លា ដែលជាទ្រព្យដោយឡែករបស់ខ្លួនជួលទីតាំងមួយកន្លែងសម្រាប់បើកហាងលក់កាហ្វេ។ ដូចនេះ ហាងកាហ្វេនោះគឺជាទ្រព្យរួបរបស់ពួកគាត់ទាំងពីរ។

### ១.២.១. ទ្រព្យសម្បត្តិទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍

ទ្រព្យសម្បត្តិទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ដែលចាត់ចូលជា "ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិទាំងឡាយ ដែលប្ដីប្រពន្ធទាំងសងខាង ឬ តែម្ខាងទទួលបានអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ លើកលែងតែ ទ្រព្យសម្បត្តិដោយឡែក"។[11] ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិទាំងឡាយណា ដែលប្ដីប្រពន្ធទាំងសងខាង ឬតែម្ខាងទទួលបាននៅក្នុង អំឡុងពេលអាពាហ៍ពិពាហ៍ក្នុងលក្ខណៈជាប្រាក់បៀវត្សរ៍ ឬ ប្រាក់ឈ្នួល ឬ ប្រាក់កម្រៃឬ ប្រយោជន៍នានា ផ្សេងពីចំនុចទាំង ៣ ក្នុងទ្រព្យសម្បត្តិដោយឡែក ។

ឧទាហរណ៍៖ ប្ដីធ្វើការជាមន្ត្រីរាជការ និងទទួលបានប្រាក់បៀវត្ស ១លានរៀល ក្នុងមួយខែ ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។ ហេតុដូច្នេះហើយប្រាក់បៀវត្សរបស់ប្ដី ត្រូវចាត់ទុកជាទ្រព្យសម្បត្តិរួមរបស់ប្ដី និងប្រពន្ធ។ ក្នុងករណីប្រាក់ចំណូលដែលប្ដីរកបានតែម្ខាង ហើយប្រពន្ធត្រឹមតែជាស្ត្រីមេផ្ទះ ធ្វើតែការងារគេហកិច្ច ការងារក្នុងផ្ទះ) តើប្រាក់ចំណូលដែលប្ដីរកបានតែម្ខាងត្រូវចាត់ទុកថាវាជាទ្រព្យរួម ឬ ទ្រព្យដោយឡែក? ជាគោលការណ៍ច្បាប់ការងារគេហកិច្ច (ការងារនៅក្នុងផ្ទះ) ត្រូវចាត់ទុកថាមានតម្លៃស្មើនឹងការងារដែល ធ្វើនៅក្រៅផ្ទះដែរ មានន័យថា ប្ដីមិនអាចបដិសេធចំពោះចំណូលដែលខ្លួនរក បានពីការងារក្រៅផ្ទះ ថាមិនមែនជាទ្រព្យរួម ឬបន្ថយសិទ្ធិរបស់ប្រពន្ធលើចំណូលរបស់ខ្លួន ដោយសំអាងថាប្រពន្ធរបស់ខ្លួនធ្វើតែការងារផ្ទះ មើលថែទាំកូន ដាំស្ល បោកគក់។ល។ ដោយមិនបានប្រឡូកនឹងការងារខាងក្រៅ ដែលនឿយហត់ដូចការងាររបស់ខ្លួនឡើយ។ ចំពោះប្រាក់ឈ្នួលដែលបានមកពីការជួលផ្ទះ ដែលជាទ្រព្យរបស់ប្ដី ឬ ប្រពន្ធមានមុនពេលរៀបអាពាហ៍ពិពាហ៍ តើយើងអាចចាត់ទុកថាជាទ្រព្យរួម ឬ ជាទ្រព្យដោយឡែក? ដូចនឹងឧទាហរណ៍ខាងលើ ដែលប្ដីធ្វើការជាមន្ត្រីរាជការ និងទទួលបានប្រាក់បៀវត្ស ១លានរៀល ក្នុងមួយខែ ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។ ហេតុដូច្នេះហើយប្រាក់

[10] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៧៣។

[11] សទ្ទានុក្រម ក្រមរដ្ឋប្បវេណី,០៨ ធ្នូ ២០០៧, លេខរៀង ៦២។

បៀវត្សរបស់ប្តី ត្រូវចាត់ទុកជាទ្រព្យសម្បត្តិរួមរបស់ប្តី និងប្រពន្ធ។ ស្របពេលគ្នានោះដែរ ប្តីក៏មានផ្ទះមួយល្វែង ដែលជាទ្រព្យដោយឡែករបស់ខ្លួន ហើយប្តីបានដាក់ផ្ទះនោះជួលដើម្បីបាន ថ្លៃឈ្នួលប្រចាំខែ។ ដូច្នេះថ្លៃឈ្នួលប្រចាំខែ ដែលបានមកពីការជួលផ្ទះនោះ គេចាត់ទុកថាជាទ្រព្យរួមរបស់ប្តី និងប្រពន្ធ។ ក្នុងករណីបំណុលរួមប្តីប្រពន្ធត្រូវតែទទួលខុសត្រូវរួមគ្នា ទោះបីជាបំណុលនោះប្តីប្រពន្ធទាំងពីរជាអ្នកខ្ចីរួមគ្នា ឬក៏សហព័ទ្ធណាម្នាក់ជាអ្នកខ្ចីឱ្យតែមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីសហព័ទ្ធម្នាក់ទៀត។ ប៉ុន្តែបើទោះបីជាគ្មានការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីសហព័ទ្ធម្ខាងទៀតក៏ដោយ ក៏អាចចាត់ទុកថាជាបំណុលរួមបានផងដែរ ប្រសិនបើបំណុលនោះស្ថិតក្រោមរូបភាពជាបំណុលដែលជាប់ពាក់ព័ន្ធនឹងការរក្សាជីវភាពរួមរបស់ប្តីប្រពន្ធ ការអប់រំ ការថែទាំ និង ព្យាបាលកូន បំណុលដែលជាប់ពាក់ព័ន្ធនឹងការគ្រប់គ្រង និងរក្សាទ្រព្យសម្បត្តិរួម។[12]

## ១.៣. ចំណែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍

ប្តីប្រពន្ធ ត្រូវមានចំណែកបន្ទុកលើសោហ៊ុយ ដែលកើតចេញពីអាពាហ៍ពិពាហ៍ ដោយពិចារណាទៅលើទ្រព្យសម្បត្តិ ប្រាក់ចំណូល និងស្ថានភាពផ្សេងៗទៀត។ មាត្រានេះ ចែងអំពី បន្ទុកនៃសោហ៊ុយដើម្បីថែទាំជីវភាពរួមនៃអាពាហ៍ពិពាហ៍ ដោយតម្រូវឱ្យប្តីប្រពន្ធចែករំលែក សោហ៊ុយទៅតាមទ្រព្យសម្បត្តិ ប្រាក់ចំណូល ឋានៈក្នុងសង្គម និង មុខរបរ ជាដើម របស់ប្តីប្រពន្ធ សោហ៊ុយ អាពាហ៍ពិពាហ៍ទាំងនោះ៖ មិនសំដៅលើត្រឹមតែសោហ៊ុយចាំបាច់ដែលចំណាយលើការស្លៀកពាក់ ម្ហូបអាហារ និង ការស្នាក់ នៅប៉ុណ្ណោះទេ តែរាប់បញ្ចូលទាំងសោហ៊ុយលើថ្លៃព្យាបាល ការសិក្សា និង ថែទាំកូនផងដែរ។[13]

ឧទាហរណ៍៖ ជាចុងក្រោយ សីហា មិនអាចលក់ផ្ទះនៅផ្សារដើមគបាន ហើយស្រីពៅ និង ចិត្រាកំពុងរស់នៅលើផ្ទះនោះទៀត។ សីហា កំពុងរស់នៅផ្ទះរបស់រស្មីនៅជ្រោយចង្វា។ សីហា គិតថាចង់លែងលះជាមួយស្រីពៅ ប៉ុន្តែ ស្រីពៅបានគិតពីចិត្រា ហើយក៏ស្ទាក់ស្ទើរចំពោះការលែងលះនោះ។ ដោយសារតែក្រុមហ៊ុនទេសចរណ៍ដែលស្រីពៅកំពុងធ្វើការបាន ក្ស័យធន បច្ចុប្បន្ន នាងកំពុងតែធ្វើការនៅភោជនីយដ្ឋាន។ ប្រាក់ខែជារៀងរាល់ខែ ១៥០ដុល្លារ។ ស្រីពៅ ត្រូវការប្រាក់ចំនួន២០០ ដុល្លារ ក្នុង១ខែ ដើម្បីប្រើប្រាស់សម្រាប់ថ្លៃជីវភាពដូចជា ថ្លៃម្ហូបអាហារ ថ្លៃទឹក ភ្លើង ហ្គាស និង ថ្លៃសម្លៀកបំពាក់។ ជារៀងរាល់ខែ នាងត្រូវការ ៣០ដុល្លារ សម្រាប់ថ្លៃសាលាកូន។ ពោល ទោះបីជាស្រីពៅមានប្រាក់ខែចំនួន ១៥០ដុល្លារ ក្នុង១ខែក៏ដោយ ដោយសារតែប្រាក់នោះមិនទាន់គ្រប់គ្រាន់ ដូច្នេះ នាងត្រូវការ២៣០ដុល្លារក្នុង ១ខែ ។ បច្ចុប្បន្ន សីហា កំពុងបន្តធ្វើការនៅ ធនាគារ ហើយប្រាក់ខែទទួលបាន៦០០ដុល្លារក្នុង ១ខែ។ តើស្រីពៅ អាចទាមទារចំពោះសីហាឱ្យជួយផ្គត់ផ្គង់ថ្លៃសាលា និង ថ្លៃ

[12] ក្រមរដ្ឋប្បវេណីលេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៧៣ និង Website CICLG.COM (Kanann Neam – Law)។

[13] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី (ភាគ ៥ គន្ថីទី៧) មាត្រា ៩៧១។

ជីវភាព បានដែរឬទេ? តើសោហ៊ុយដែលកើតចេញពីអាពាហ៍ពិពាហ៍មានអ្វីខ្លះ? មានទីមួយ ថ្លៃម្ហូបអាហារ ថ្លៃភ្លើង ថ្លៃទឹក ថ្លៃហ្គាស ថ្លៃទូរស័ព្ទ ទីពីរ ថ្លៃសម្លៀកបំពាក់ ទីបី ថ្លៃព្យាបាល ទីបួន ថ្លៃសិក្សារបស់កូន និងផ្សេងទៀត។ នៅក្នុងពេលដែលអ្នកទាំង៣ រស់នៅជាមួយគ្នាសីហា និងស្រីពៅ ទទួលបន្ទុកចំពោះសោហ៊ុយអាពាហ៍ពិពាហ៍។ ក្នុងអំឡុងពេលរស់នៅជាមួយគ្នា ចំណែកនៃការទទួលបន្ទុកលើសោហ៊ុយអាពាហ៍ពិពាហ៍ នឹងមិនមានបញ្ហាឡើយ។ ចំណែកនៃការទទួលបន្ទុកម្នាក់ៗទៅលើការផ្គត់ផ្គងជីវភាពរស់នៅប្រចាំថ្ងៃ មានដូចជា សីហា មានការទទួលបន្ទុកក្នុងការចំណាយចំនួន១៥០ ដុល្លា (ទៅលើម្ហូបអាហារ សម្លៀកបំពាក់ និងផ្សេងៗ)។ ស្រីពៅ មានការទទួលបន្ទុកចំនួន១៥០ ដុល្លា (សម្រាប់ចំណាយលើសម្លៀកបំពាក់ ម្ហូបអាហារ ថ្លៃហ្គេស ទឹក ភ្លើង និងសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ)។ រីឯចិត្រា មានការទទួលបន្ទុកចំនួន ៥០ ដុល្លា (៣០ដុល្លា ថ្លៃបង់សាលារៀន និង២០ ដុល្លា ទៀត ចំណាយផ្សេងៗ)។ ពោលនេះ គឺជាភាពចាំបាច់នៃចំនួនប្រាក់ សម្រាប់ជីវភាពរបស់មនុស្សម្នាក់ៗ។ បន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍ មានអានុភាពនៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។ ដូច្នេះហើយ ក្រោយការលែងលះ បញ្ញត្តិនៃបន្ទុកសោហ៊ុយអាពាហ៍ពិពាហ៍មិនត្រូវបានយកមកអនុវត្តឡើយ។ ដូច្នេះ ប្រសិនបើ សីហា និង ស្រីពៅបានលែងលះគ្នា ស្រីពៅមិនអាចទាមទារចំពោះសីហាឱ្យបង់សោហ៊ុយអាពាហ៍ពិពាហ៍បានឡើយ។ ពោល ក្នុងការអនុវត្តជាក់ស្តែង បន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍ក្លាយជាបញ្ហា គឺក្នុងអំឡុងពេល ក្រោយការរស់នៅបែកគ្នា និង មុនការលែងលះ។

ចុះប្រសិនបើ បានធ្វើការលែងលះ តើស្រីពៅ និង ចិត្រាអាចទាមទារចំពោះសីហាឱ្យជួយផ្គត់ផ្គង់ថ្លៃជីវភាពជាអាទិ៍ដោយផ្អែកលើសិទ្ធិបែបណា? ដូច្នេះ បញ្ហានេះនឹងយកមកធ្វើការបកស្រាយតែបន្តិចប៉ុណ្ណោះ។ ស្រីពៅអាចទាមទារចំពោះសីហាឱ្យជួយផ្គត់ផ្គង់ថ្លៃជីវភាពរបស់ចិត្រាជាអាទិ៍បាន ដោយផ្អែកតាមបញ្ញត្តិស្តីពីសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន (ក្រមរដ្ឋប្បវេណី មាត្រា ១០៤០ កថាខណ្ឌទី១ ឪពុក ឬ ម្តាយដែលពុំមានអំណាចមេបា ក្រោយពេលលែងលះគ្នា មានសិទ្ធិចូលជួប និង ប្រាស្រ័យទាក់ទងជាមួយកូន និងមានករណីកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន។ ស្រីពៅ អាចទាមទារចំពោះសីហាឱ្យផ្គត់ផ្គង់ជីវភាពរបស់ខ្លួនបាន ដោយផ្អែកតាមមាត្រា ៧៦ នៃច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និងគ្រួសារ។ នេះហៅថា អាហារកិច្ច។ ច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និង គ្រួសារ មាត្រា ៧៦ កថាខណ្ឌទី១ ក្នុងករណីលែងលះគ្នាភាគីដែលគ្មានកំហុស ហើយខ្វះខាត អាចស្នើសុំអាហារកិច្ចពីភាគីម្ខាងទៀតបាន។[14]

[14] សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, សិក្ខាសាលាក្រមរដ្ឋប្បវេណីលើកទី ៦, ប្រព័ន្ធទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ។

### ១.៣.១. ការទទួលខុសត្រូវចំណាយក្នុងពេលអាពាហ៍ពិពាហ៍

ប្តីប្រពន្ធ ត្រូវមានចំណែកបន្ទុកលើសោហ៊ុយ ដែលកើតចេញពីអាពាហ៍ពិពាហ៍ ដោយពិចារណាទៅលើទ្រព្យសម្បត្តិ ប្រាក់ចំណូល និងស្ថានភាពផ្សេងៗទៀត ។[15] វាមានន័យថាប្តីប្រពន្ធ ត្រូវមានករណីយកិច្ចទទួលខុសត្រូវនូវសោហ៊ុយចំណាយ ដើម្បីថែទាំជីវភាពរួមនៃអាពាហ៍ពិពាហ៍ ដោយតម្រូវឱ្យប្តីប្រពន្ធ ចែករំលែកនូវការទទួលខុសត្រូវសោហ៊ុយជីវភាពរួមនៃអាពាហ៍ពិពាហ៍ ទៅតាមទ្រព្យសម្បត្តិ ប្រាក់ចំណូល ឋានៈ ក្នុងសង្គម និងមុខរបររបស់ប្តីប្រពន្ធជាដើម។ ការទទួលខុសត្រូវនូវសោហ៊ុយ ចំណាយដើម្បីថែទាំជីវភាពរួមនៃ អាពាហ៍ពិពាហ៍ មិនសំដៅលើត្រឹមតែការចំណាយសម្រាប់សម្លៀកបំពាក់ ម្ហូបអាហារ ការស្នាក់នៅ ថ្លៃព្យាបាល ប៉ុណ្ណោះទេ គឺរាប់បញ្ចូលទាំងការចំណាយលើការសិក្សា និង ថែទាំកូនផងដែរ។ មិនតែប៉ុណ្ណោះ ក្រោយពេលប្តីប្រពន្ធរស់នៅបែកគ្នាក៏ដោយ ក៏ប្តីប្រពន្ធ ត្រូវតែបន្តនូវករណីកិច្ចទទួលបន្ទុកនូវចំណែកនេះផងដែរប្រសិនបើពួកគេ មិនទាន់លែងលះនឹងគ្នា។ ទោះបីជា ប្តីប្រពន្ធ រស់នៅបែកគ្នាក៏ដោយ ក៏ប្តីប្រពន្ធត្រូវមានអាហារកាតព្វកិច្ច រវាងសហព័ទ្ធដែរ។ មានន័យថា សហព័ទ្ធម្ខាង អាចទាមទារ រួមទាំងសោហ៊ុយសម្រាប់ជីវភាពរស់នៅរបស់កូន ដែលរស់នៅជាមួយខ្លួន ពីសហព័ទ្ធម្ខាងទៀតបានដែរ។

ក្នុងករណីដែលសហព័ទ្ធណាមួយ មិនអនុវត្តកាតព្វកិច្ចនៃសោហ៊ុយចំណាយពេលក្នុងអាពាហ៍ពិពាហ៍ សហពទ្ធ័ម្ខាងទៀតអាចដាក់ពាក្យសុំទៅតុលាការឱ្យសម្រេចអំពីសោហ៊ុយចំណាយនេះបាន ក្នុងនីតិវិធីរឿងក្តីដែលមិនមែនជាបណ្តឹង ។

#### ក. ទំនាក់ទំនងរវាងការទទួលខុសត្រូវសោហ៊ុយចំណាយក្នុងពេលអាពាហ៍ពិពាហ៍នឹងរឿងក្តីសុំលែងលះ

សហពទ្ធ័ ត្រូវបន្តនូវករណីកិច្ចទទួលបន្ទុកនូវចំណែកបន្ទុកនៃសោហ៊ុយចំណាយ ក្នុងពេលអាពាហ៍ពិពាហ៍ រហូតដល់ពេលដែល ប្តីប្រពន្ធ បានលែងលះគ្នាដាច់ស្រេច មិនថាឡើយសូម្បីតែនីតិវិធីលែងលះកំពុងតែអនុវត្ត។ នៅក្នុងករណីដែលតុលាការច្រានចោលនូវការទាមទារលែងលះរបស់សហព័ទ្ធ នោះបន្ទុកនៃការទទួលខុសត្រូវ សោហ៊ុយចំណាយក្នុងពេលអាពាហ៍ពិពាហ៍ នៅតែបន្តដដែលសម្រាប់សហព័ទ្ធ។ នៅពេលដែលការសុំលែងលះ បានសម្រេចរួចរាល់ហើយ ករណីយកិច្ចទទួលខុសត្រូវនូវចំណែកបន្ទុកនៃ សោហ៊ុយអាពាហ៍ពិពាហ៍ ក៏ត្រូវអស់ពីពេលនោះដែរ ប៉ុន្តែ មាត្រា ៧៦ (អាហារកិច្ចនៅក្រោយការលែងលះ) នៃ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ គឺត្រូវបានរក្សាទុក ទោះជានៅក្រោយក្រមរដ្ឋប្បវេណីថ្មី ត្រូវបានអនុវត្ត ដោយផ្អែកទៅលើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី។

[15] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៧១។

**ខ. វិធីគណនាទឹកប្រាក់នៃការទទួលខុសត្រូវចំណាយក្នុងពេលអាពាហ៍ពិពាហ៍**

វិធីគណនាទឹកប្រាក់នៃការទទួលខុសត្រូវចំណាយក្នុងពេលអាពាហ៍ពិពាហ៍មានវិធីដូចខាងក្រោម៖

a. ត្រូវគណនាទៅតាមចំណូលមូលដ្ឋាន (x) របស់អ្នកមានសិទ្ធិ (ច្រើនតែប្រពន្ធ) និង ចំណូលមូលដ្ឋាន (Y) របស់អ្នកមានករណីយកិច្ច (ច្រើនតែប្តី)។

b. ត្រូវគណនាសោហ៊ុយអាពាហ៍ពិពាហ៍ (Z) ដែលត្រូវចែកទៅឱ្យខាងគ្រួសារអ្នកមានសិទ្ធ ។

$$Z=(x+Y) \times Z=(X+Y) \times \frac{\text{សូចនាយករណ៍នសោហ៊ុយសម្រាប់ជីវភាពគ្រួសារអ្នកមានសិទ្ធិ (អ្នកមានករណ៍កិច្ច គឺជាអ្នកមានបន្ទុកលើអាហារកាតព្វកិច្ច)}}{\text{សូចនាយករណ៍នៃសោហ៊ុយសម្រាប់ជីវភាពទាំងសងខាង (អ្នកមានករណីយកិច្ច គឺជាអ្នកមានបន្ទុកលើអាហារកាតព្វកិច្ច)}}$$

c. ត្រូវគណនាទឹកប្រាក់ ដែលអ្នកមានករណីយកិច្ចត្រូវទទួលបន្ទុក (ទឹកប្រាក់នៃចំណែកបន្ទុកសោហ៊ុយអាពាហ៍ពិពាហ៍) ពីទឹកប្រាក់ដែលបានគណនានៅចំណុច "ខ"

ទឹកប្រាក់នៃចំណែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍ = Z – Y ។[16]

## ផ្នែកទី២ សិទ្ធិ និងការទទួលខុសត្រូវរបស់សហព័ទ្ធ

នៅពេលបុរស និងស្ត្រីរៀបអាពាហ៍ពិពាហ៍នឹងគ្នា គេត្រូវទទួលបានសិទ្ធនឹងការទទួលខុសត្រូវខ្លះចំពោះគ្នាទៅវិញទៅមក ចំពោះកូន និងចំពោះសាច់ញាតិរបស់សហព័ទ្ធ ។ សិទ្ធិ និងការទទួលខុសត្រូវទាំងអស់នេះមានមែកធាងមកពីច្បាប់អន្តរជាតិ ក៏ដូចជាមកពីរដ្ឋធម្មនុញ្ញ ក្រមរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ និងបទបញ្ញត្តិនានារបស់ប្រទេសនីមួយៗ។ ផ្នែកនេះនឹងធ្វើការពិភាក្សាអំពីសិទ្ធិ និងការទទួលខុសត្រូវជាមូលដ្ឋានខ្លះៗរបស់សហ ទ័ព្វដែលឋិតនៅក្រោមច្បាប់របស់ ព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន។

កាលពីអតីតកាល នៅក្នុងប្រទេសជាច្រើន ច្បាប់បានចែងអំពីសិទ្ធិ និងករណីយកិច្ចផ្សេងៗសម្រាប់ប្តី និងប្រពន្ធ។ នៅទូទាំងពិភពលោក សិទ្ធិតាមផ្លូវច្បាប់របស់ប្រពន្ធមានភាពមិនស្មើគ្នានឹងសិទ្ធិតាមផ្លូវច្បាប់របស់ប្តីប្រពន្ធទេ។ នៅក្នុងអតីតកាលកន្លងថ្មីៗនេះច្បាប់របស់ប្រទេសកម្ពុជា មិនបានផ្តល់ឱ្យស្ត្រីមានសិទ្ធិស្មើគ្នាតាមផ្លូវច្បាប់នៅពេលមានចំណងអាពណ៍ពិពាហ៍ទេ។

ឧទាហរណ៍៖ ក្រមរដ្ឋប្បវេណីសង្គមចាស់របស់ប្រទេសកម្ពុជាបានកំណត់ថាស្ត្រីដែលរៀអាពាហ៍ពិពាហ៍

[16] សេចក្តីពន្យល់អំពី ក្រមរដ្ឋប្បវេណី, ភាគទី៣, ទំព័រ២៥ដល់២៦។

មានសិទ្ធិរៀបអាពាហ៍ពិពាហ៍បានប្ដីតែមួយ ប៉ុន្តែប្ដីអាចមានសិទ្ធិយកប្រពន្ធបានច្រើននាក់ដោយស្របច្បាប់។ ម្យ៉ាងទៀតស្ត្រីដែលបានរៀបអាពាហ៍ពិពាហ៍ហើយពុំមានសិទ្ធិចុះកិច្ចសន្យា ឬធ្វើបណ្ដឹងដោយពុំមានការអនុញ្ញាតរបស់ប្ដីបានឡើយ។

ជាច្រើនទសវត្សន៍កន្លងមកនេះ មានប្រទេសជាច្រើនបានសរសេរច្បាប់របស់ខ្លួនឡើងវិញ ដោយមានការកែលម្អជាច្រើន ដើម្បីផ្ដល់ឱ្យស្ត្រីមានអំណាចស្មើនឹងបុរស នៅក្នុងចំណងអាពាហ៍ពិពាហ៍។ កម្ពុជាជាប្រទេសមួយក្នុងចំណោម ប្រទេសនានាដែលបានបញ្ចូលគោលការណ៍ស្ដីពីសមភាពរបស់បុរសនារីនៅក្នុងច្បាប់។ ដូច្នេះ ច្បាប់របស់ប្រទេសកម្ពុជាបច្ចុប្បន្នចែងថា "ប្ដីនិងប្រពន្ធមានសិទ្ធិស្មើគ្នាក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ"។

យ៉ាងហោចណាស់នៅកម្ពុជាក៏មានច្បាប់ចំនួនបី ដែលចែងពីគោលការណ៍សមភាពរវាងប្ដី និងប្រពន្ធ។ ទី១ អនុសញ្ញាអន្តរជាតិស្ដីអំពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទឆ្នាំ ១៩៧៩ ត្រង់មាត្រា ១៦ ចំណុច ឃ ចែងថា "បុរស និងនារីត្រូវមានសិទ្ធិនិងការទទួលខុសត្រូវដូចគ្នា នៅពេលមានចំណងអាពាហ៍ពិពាហ៍ និងនៅពេលរំលាយចំណងអាពាហ៍ពិពាហ៍" ដែលប្រទេសកម្ពុជាបានផ្ដល់សច្ចាប័នលើអនុសញ្ញានេះ។ ទី២ រដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជាចែងថា "បុរស និងស្ត្រីមានសិទ្ធិដូចគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសការរៀបអាពាហ៍ពិពាហ៍ និងគ្រួសារ"។

ការខ្វះចន្លោះរវាងច្បាប់ជាលាយលក្ខណ៍អក្សរ និងការអនុវត្តជាក់ស្ដែង មានប្រជាជាតិជាច្រើនបានរកឃើញថា ជាការពិបាកណាស់ដើម្បីបង្គាប់មនុស្សឱ្យប្រត្តិបត្តិសិទ្ធិស្មើគ្នា ដែលរដ្ឋធម្មនុញ្ញនិងច្បាប់របស់ជាតិបានចែង។ នៅក្នុងប្រទេសខ្លះ ទំនៀមទម្លាប់និង ប្រពៃណីតឹងរ៉ឹង បានធ្វើឱ្យមានការលំបាកដល់ការធ្វើឱ្យសម្រេចនូវគោលការណ៍នៃសកម្មភាពនេះ។ ទោះជាយ៉ាងណាក៏ដោយ ជាការសំខាន់ណាស់ ដែលត្រូវមានច្បាប់សរសេរជាលាយលក្ខណ៍អក្សរ ហើយត្រូវទទួលស្គាល់សមភាព ជាគោលដៅក្នុងចំណោមគោលដៅសំខាន់ៗនានារបស់សង្គម។ កាលណាច្បាប់ទទួលស្គាល់សមភាពជាគោលដៅមួយហើយ ប្រជាពលរដ្ឋអាចប្រើប្រាស់ដើម្បីជួយឱ្យគោលបំណងនេះក្លាយទៅជាការពិត។[17]

[17] នីតិគ្រួសារ និង អាពាហ៍ពិពាហ៍, ភាគ១, បោះពុម្ពលើកទី២, ២០២១, ទំព័រទី១៤៥ដល់១៤៨, ឥន យឿន។

## ២.១. សិទ្ធិ ក្នុងការគ្រប់គ្រង និងចាត់ចែងលើទ្រព្យសម្បត្តិប្តីប្រពន្ធ

នៅក្នុងការចាត់ចែកទ្រព្យសម្បត្តិរួមប្តីប្រពន្ធ គឺត្រូវមានការយល់ព្រមពីភាគីទាំងសងខាង ទើបអាចយកទ្រព្យសម្បត្តិនោះទៅបែងចែកបាន បើគ្មានការយល់ព្រមពីប្តីប្រពន្ធទាំងសងខាងទេទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធមិនអាចយកទៅលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀតបានឡើយ ។ ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៩៧៦ នៃក្រមរដ្ឋប្បវេណីក៏ដោយបើមានស្ថានភាពមិនអាចជៀសវាងបាន សម្រាប់ការថែទាំជីវភាពរួមក្នុងអាពាហ៍ពិពាហ៍ និង ដើម្បីរក្សាជីវភាពរស់នៅនោះប្តីប្រពន្ធណាម្ខាង អាចលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀត នូវទ្រព្យសម្បត្តិរួមបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។ ក្នុងករណីដែលប្តី ឬ ប្រពន្ធណាម្ខាង បានលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀតនូវទ្រព្យសម្បត្តិរួម ដោយគ្មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតផង និង គ្មានការអនុញ្ញាតពីតុលាការផង សហព័ទ្ធដែលមិនបានផ្តល់ការយល់ព្រម អាចទាមទារឱ្យលុបចោលនូវការចាត់ចែងនោះទៅតុលាការ បាន នៅក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំគិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ ទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះ ជាអចលនវត្ថុនិង នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះ ជាទ្រព្យសម្បត្តិផ្សេង។[18]

### ២.១.១. ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិដោយឡែក

ការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិ គឺជាចំណុចសំខាន់មួយដែលប្តីប្រពន្ធ ត្រូវដឹងអំពីសិទ្ធិក្នុងកំឡុងអាពាហ៍ពិអាពាហ៍ និងការទទួលខុសត្រូវសំខាន់ៗ គឺអាស្រ័យលើការចាត់ថ្នាក់ប្រភេទទ្រព្យសម្បត្តិ ។ ប្តីប្រពន្ធនីមួយៗ មានសិទ្ធិប្រើប្រាស់ ទទួលផលប្រយោជន៍ និងគ្រប់គ្រងទ្រព្យសម្បត្តិរៀងៗខ្លួនបាន និងមានសិទ្ធិអំណាចស្មើគ្នាចំពោះសហព័ទ្ធក្នុងការចាត់ចែង និងការប្រើប្រាស់ទ្រព្យសម្បត្តិរួម។ តាមខ្លឹមសារនេះហើយប្តី ឬ ប្រពន្ធក៏មានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ក្នុងទំហំដែលចាំបាច់ ដូចជាការចំណាយទៅលើការទិញសម្ភារៈសិក្សាកូន និងការចំណាយប្រចាំថ្ងៃនៅក្នុងគ្រួសារ។ ចំពោះទ្រព្យសម្បត្តិរួម សហព័ទ្ធត្រូវសហការគ្នាក្នុងការគ្រប់គ្រងរក្សាទុកទ្រព្យសម្បត្តិរួម មានសិទ្ធក្នុងការចាត់ចែងឱ្យភាគីប្តីឬប្រពន្ធ ជាអ្នកចាត់ចែង គ្រប់គ្រងទ្រព្យសម្បត្តិរួម។ ចំណែកឯនៅក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិប្តីប្រពន្ធអាចឱ្យភាគីណាម្នាក់ចាត់ចែង និងគ្រប់គ្រងលើទ្រព្យសម្បត្តិបានតាមការពិភាក្សាគ្នារវាងសហព័ទ្ធ ប៉ុន្តែប្រសិនបើការគ្រប់គ្រង ឬប្រើប្រាស់ទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធពុំអាចពិភាក្សាបាន ភាគីប្តី ឬប្រពន្ធអាចទាមទារទៅតុលាការឱ្យ ធ្វើការចាត់ចែងចំពោះការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិរួមបាន។ យោងតាមខ្លឹមសារនៃមាត្រា ៩៧៨នៃក្រមរដ្ឋប្បវេណី។

អំពីការគ្រប់គ្រង ឬប្រើប្រាស់ទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ មិនបានសម្រេច ឬបើពុំអាចពិភាក្សាបានទេភាគីម្ខាងទៀតអាចទាមទារទៅតុលាការ ឱ្យធ្វើការចាត់ចែងចំពោះការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិរួម

[18] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៣។

បាន។ កថាខណ្ឌទី ៣ និងទី៤ បានកម្រិតអំពីសិទ្ធិអំណាចរបស់សហព័ទ្ធក្នុងការចាត់ចែងទ្រព្យសម្បត្តិរួមដោយសហការគ្នា ក្នុងករណីដែលសហព័ទ្ធ ត្រូវការចាត់ចែងទ្រព្យសម្បត្តិរួមលើសពីទំហំនៃសេចក្ដីត្រូវការ នៃការប្រើប្រាស់ប្រចាំថ្ងៃ ដូចជាការចំណាយធំៗ ដែលនៅក្នុងរយៈពេលយូរៗត្រូវការទិញឬចំណាយម្ដងៗ។ សហព័ទ្ធក៏មានសិទ្ធិក្នុងការស្នើសុំឱ្យសហព័ទ្ធម្ខាងទៀតក្នុងការថែរក្សាទ្រព្យសម្បត្តិឱ្យគង់វង្ស ហើយសហព័ទ្ធម្ខាងទៀតក៏មានសិទ្ធិស្នើទៅតុលាការ ដើម្បីឱ្យសម្រេចចាត់ចែងទ្រព្យសម្បត្តិនេះជំនួសសហព័ទ្ធម្ខាងទៀត។[19]

### ២.១.២. សិទ្ធិលើចំណូលបានមកពីទ្រព្យសម្បត្តិដោយឡែក

ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ភាគីមួយ ឬភាគីទាំងពីរ អាចជាម្ចាស់ទ្រព្យសម្បត្តិដែលផ្តល់ប្រាក់ចំណូល។ បញ្ហាអាចកើតមានឡើងថា តើនរណាម្នាក់ជាអ្នកត្រួតត្រាប្រាក់ចំណូលដែលបានមកពីទ្រព្យសម្បត្តិក្នុងពេលមានចំណងអាពាហ៍ពិពាហ៍។ ដើម្បីឆ្លើយទៅនឹងសំណួរនេះ ដំបូងយើងត្រូវបែងចែកប្រភេទទ្រព្យសម្បត្តិជាទ្រព្យសម្បត្តិរួម ឬទ្រព្យសម្បត្តិដោយឡែក។

នៅក្នុងច្បាប់ប្រទេសកម្ពុជា និងនៅស្ទើតែគ្រប់ប្រទេសផ្សេងទៀត ដែលច្បាប់ទទួលស្គាល់ទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ ប្រសិនបើទ្រព្យសម្បត្តិដែលបានកើតឡើង ពីប្រាក់ចំណូលដែលជាទ្រព្យសម្បត្តិរួម ដូច្នេះប្រាក់ចំណូលនោះនឹងក្លាយជាទ្រព្យសម្បត្តិរួមដែរ។ គោលការណ៍នេះ ត្រូវបានទទួលស្គាល់តាមមាត្រា ៩៧៤ នៃក្រមរដ្ឋប្បវេណីថ្មី។

តើមានអ្វីកើតឡើងចំពោះប្រាក់ចំណូល ដែលបានដោយសារ ទ្រព្យសម្បត្តិដោយឡែកក្នុងពេលមានចំណងអាពាហ៍ពិពាហ៍? តើប្រាក់ចំណូលនោះជាទ្រព្យសម្បត្តិរួម ឬជាទ្រព្យសម្បត្តិផ្ទាល់ខ្លួន? ប្រទេសជាច្រើនបានឆ្លើយបញ្ហានេះក្នុងវិធីខុសៗគ្នា។ នៅក្នុងរដ្ឋជាច្រើនរបស់សហរដ្ឋអាមេរិក ប្រាក់ចំណូលដែលបានមកពីទ្រព្យសម្បត្តិដោយឡែក ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ជាទ្រព្យសម្បត្តិរួម។ នៅប្រទេសបារាំងនិងអេស្ប៉ាញ ប្រាក់ចំណូលបានមកពីទ្រព្យសម្បត្តិដោយឡែក ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ត្រូវបានចាត់ជាប្រាក់ចំណូលដោយឡែក ហើយអាចត្រូវបានទទួល និងចាត់ចែងដោយសហព័ទ្ធម្នាក់ ដែលជាម្ចាស់ទ្រព្យសម្បត្តិផ្ទាល់ខ្លួន។ ក្រមរដ្ឋប្បវេណី បានបញ្ញត្តិមានភាពច្បាស់លាស់ទាំងស្រុង ដូចជា ប្រាក់ចំណូលដែលបានមកពីទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ប្តី ឬប្រពន្ធ គឺជារបស់សហព័ទ្ធនីមួយៗរៀងខ្លួននោះ មិនមែនជាទ្រព្យសម្បត្តិរួមទេ។

មាត្រា ៩៧២ កថាខណ្ឌ «គ» នៃក្រមរដ្ឋប្បវេណីកំណត់ថា ទ្រព្យសម្បត្តិដែលជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដោយឡែក ត្រូវចាត់ទុកថា ជាទ្រព្យសម្បត្តិដោយឡែក របស់សហព័ទ្ធតែម្ខាង

[19] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៧៤។

ផងដែរ។ មាត្រា ៩៧៤ បានចែងបន្ថែមទៀតថា «...សហព័ទ្ធនីមួយៗ មានសិទ្ធិប្រើប្រាស់ ទទួលផលប្រយោជន៍ និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនរៀងៗខ្លួន»។

ដូច្នេះ មាត្រានេះបង្ហាញថា ប្ដីឬប្រពន្ធត្រូវបានអនុញ្ញាតឱ្យ ធ្វើជាម្ចាស់ និងត្រួតត្រាប្រាក់ចំណូលដោយឡែកពីគ្នា ដោយពុំចាំ បាច់មានការព្រមព្រៀងគ្នា ឬការយល់ព្រមរបស់សហព័ទ្ធម្ខាងទៀតទេចំពោះទ្រព្យសម្បត្តិផ្ទាល់ខ្លួន។[20]

### ២.១.៣. ការស្នាក់អាស្រ័យនៅរបស់ប្ដីឬប្រពន្ធលើទ្រព្យសម្បត្តិដោយឡែក

ប្ដីប្រពន្ធម្ខាង អាចអាស្រ័យនៅអចលនវត្ថុដែលជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្ខាងទៀតបាន ហើយដែលត្រូវបានប្រើសម្រាប់ការអាស្រ័យនៅរបស់គ្រួសារ។ ការស្នាក់អាស្រ័យនៅរបស់ប្ដី ឬប្រពន្ធម្ខាងលើអចលនវត្ថុដែលជាកម្មសិទ្ធរបស់ប្ដី ឬប្រប្រពន្ធម្ខាងទៀតនោះ គឺអាចបន្តស្នាក់នៅតទៅទៀតបាន ទោះបីជាអចលនវត្ថុនោះត្រូវបានប្ដី ឬប្រពន្ធម្ខាងទៀតបានចាត់ហើយក៏ដោយ(មាត្រា ៩៧៧ នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍៖ សហព័ទ្ធម្ខាងមានផ្ទះមួយល្វែងដែលជាកេរ្តិ៍បន្សល់ទុកពីឪពុកម្ដាយ ហើយក្រោយពេលរៀបអាពាហ៍ពិពាហ៍ ភាគីទាំងពីរមិនមានប្រាក់ដើម្បីទិញផ្ទះសម្បែងថ្មីទេ ដូច្នេះ សហព័ទ្ធម្ខាងទៀតមានសិទ្ធិស្នាក់នៅលើផ្ទះល្វែងនេះបាន ហើយក្នុងករណីសហព័ទ្ធដែលជាម្ចាស់កម្មសិទ្ធិលើផ្ទះល្វែងបានជួល ឬលក់ ឬផ្ទេរកម្មសិទ្ធិទៅអ្នកដ៏ទៃទៀតក៏ដោយ បើមិនមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតទេ មិនអាចធ្វើការចាត់ចែងបានទេ ហើយសហព័ទ្ធម្ខាងទៀតនោះនៅតែមានសិទ្ធិបន្តស្នាក់នៅដដែល។[21]

ឧទាហរណ៍៖ សីហា ធុញទ្រាន់នឹងការទាមទារឱ្យលុបចោលកិច្ចសន្យាលក់ទិញទៅកាន់ តុលាការពេកក៏លះបង់ការត្រឡប់ទៅរស់នៅផ្ទះនៅពោធិ៍ចិនតុងនោះវិញ។ ដូច្នេះ សីហាបានលក់ចំណែករបស់ខ្លួនឱ្យទៅអ្នកស្គាល់គ្នាជាមួយសីហាដែលកំពុងរស់នៅផ្ទះនៅពោធិ៍ចិនតុងងនោះ។ ថ្លៃលក់មានតម្លៃ ២០០០០ដុល្លារ។ សីហាបានយកប្រាក់ចំនួន ២០០០០ដុល្លារនោះ សងត្រឡប់នូវឥណទានរបស់ធនាគារនៅច្បារអំពៅ។ បច្ចុប្បន្ន សីហាកំពុងរស់នៅជាមួយស្រីពៅ និងចិត្រាជាមួយគ្នានៅផ្ទះនៅច្បារអំពៅ។ ១ឆ្នាំក្រោយមកឪពុករបស់សីហាបានស្លាប់។ ក្រោយពីលទ្ធផលនៃការបែងចែកទ្រព្យសម្បត្តិ ដោយការពិភាក្សា សីហាបានទទួលសន្តតិកម្មផ្ទះពីឪពុក។ ផ្ទះនោះជាផ្ទះល្វែងដែលនៅជិតផ្សារដើមគ។ ផ្អែកតាមក្រមរដ្ឋប្បវេណី មាត្រា ៩៧២ កថាខណ្ឌទី ២ ផ្ទះនោះជាទ្រព្យសម្បត្តិដោយឡែក របស់សីហា។ សីហាបានពីទៅផ្ទះនោះនិងចាប់ផ្តើមរស់នៅជាមួយស្រីពៅ និងចិត្រា។

[20] នីតិគ្រួសារ និង អាពាហ៍ពិពាហ៍, ភាគ១, បោះពុម្ពលើកទី២, ២០២១, ទំព័រទី១៦៩ដល់១៧១, ឥន យឿន។

[21] នីតិគ្រួសារ និង អាពាហ៍ពិពាហ៍, ភាគ១ បោះពុម្ពលើកទី២, ២០២១, ទំព័រទី១៧២, ឥន យឿន។

១ឆ្នាំក្រោយមក នៅលើ FACEBOOK របស់សីហាបានទទួលសារពីរស្មីថា "អូននៅនឹកបង"។ សីហាបានចាប់ផ្តើមជួបជាមួយរស្មី ហើយបានចាប់ផ្តើមទំនាក់ទំនងម្តងទៀតដោយលួចលាក់នឹងស្រីពៅ។ ១ឆ្នាំក្រោយមក សីហាបានលែងលះជាមួយស្រីពៅ ហើយគិតថា ចង់ទៅរស់នៅជាមួយរស្មី។ ដូច្នេះ សីហា បានស្នើរចំពោះស្រីពៅថា ខ្ញុំចង់លែងលះ។ ប៉ុន្តែ ស្រីពៅមិនបានឆ្លើយតបនឹងការលែងលះនោះទេ។ ហេតុនេះ សីហាបាននិយាយចំពោះស្រីពៅថា "ផ្ទះនេះជាផ្ទះរបស់ខ្ញុំ នាងចេញពីផ្ទះនេះជាមួយចិត្រាទៅ"។ ក្នុងករណីនេះ តើស្រីពៅត្រូវតែចេញពីផ្ទះដែរឬទេ? ដូច្នេះ យោងតាមក្រមរដ្ឋប្បវេណី មាត្រា ៩៧៧ កថាខណ្ឌទី ១ ទោះបីជាផ្ទះនោះជាទ្រព្យសម្បត្តិដោយឡែករបស់សីហាក៏ដោយ ក៏ស្រីពៅអាចអាស្រ័យនៅ លើផ្ទះនោះបានដែរ។

ដោយសារតែស្រីពៅមិនព្រមចេញពីផ្ទះនៅផ្សារដើមគ សីហាបានចេញពីផ្ទះនោះ ហើយបានចាប់ផ្តើមជីវភាពនៅផ្ទះរបស់រស្មីដែលនៅជ្រោយចង្វា។ រស្មីបាននិយាយចំពោះសីហាថា "ចង់រស់នៅផ្ទះថ្មីជាមួយគ្នា "។ ដូច្នេះ សីហាគិតថានឹងលក់ផ្ទះដែលស្រីពៅកំពុងរស់នៅនៅច្បារអំពៅ ហើយ យកលុយនៅទៅទិញផ្ទះថ្មី។ សីហាបានពឹងពាក់ភ្នាក់ងារអចលនវត្ថុ ហើយបានរកឃើញអ្នកទិញ។ អ្នកទិញបានទៅផ្ទះនោះមើលមុននឹងចុះកិច្ចសន្យាលក់ទិញជាមួយសីហា។ ខណៈនោះ ក៏ដឹងថា ស្រីពៅ និង ចិត្រាកំពុងតែរស់នៅ។ ដូច្នេះហើយ អ្នកទិញបានបញ្ជាក់ពីស្ថានភាពនោះជាមួយសីហា។

សីហា បានហៅទូរស័ព្ទទៅកាន់ស្រីពៅថា "ដោយសារតែខ្ញុំសម្រេចចិត្តលក់ផ្ទះនោះហើយ អញ្ជឹងសូមចេញពីផ្ទះនេះក្នុងខែនេះ"។ បន្ទាប់មក សីហាបានពន្យល់ទៅកាន់អ្នកទិញថា "អ្នកទាំងពីរនោះ នឹងចេញពីផ្ទះនេះក្នុងខែនេះហើយ ។ ដូច្នេះ ចាប់ពីខែក្រោយ អ្នកអាចប្រើផ្ទះនេះបានហើយ " ។ ដូច្នេះ អ្នកទិញបានយល់ព្រមហើយបានចុះកិច្ចសន្យាលក់ទិញជាមួយសីហាម្យ៉ាងទៀតបានចុះបញ្ជីផ្ទេរកម្មសិទ្ធិពីសីហាទៅ អ្នកទិញ។ ថ្លៃលក់មានតម្លៃ ១០០០០០ដុល្លារ។

ខែបន្ទាប់មក អ្នកទិញបានទៅផ្ទះនោះ ប៉ុន្តែ ស្រីពៅ និង ចិត្រា កំពុងរស់នៅទីនោះនៅឡើយ។ ក្នុងករណីនេះ តើអ្នកទិញអាចទាមទារឱ្យចំពោះស្រីពៅ និងចិត្រា ឱ្យចេញពីផ្ទះដោយផ្អែកលើសិទ្ធិកម្មសិទ្ធិនៃផ្ទះបានដែរឬទេ? យោងតាមក្រមរដ្ឋប្បវេណីមាត្រា៩៧៧កថាខណ្ឌទី២ អ្នកទិញមិនអាចទាមទារចំពោះស្រីពៅឱ្យចុះចេញពីអាគារនោះបានទេ។ ប៉ុន្តែអ្នកទិញអាចលុបចោលកិច្ចសន្យាលក់ទិញដោយផ្អែកតាមការភាន់ច្រឡំបាន។[22]

[22] សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវុទ្យាសាស្ត្រសេដ្ឋកិច្ច, សិក្ខាសាលាក្រមរដ្ឋប្បវេណីលើកទី ៦, ប្រព័ន្ធទ្រព្យសម្បត្តិប្រីប្រពន្ធ។

### ២.១.៤. កម្មសិទ្ធិលើកំណើនទ្រព្យសម្បត្តិរួម ឬទ្រព្យសម្បត្តិដោយឡែក

ភាគីទាំងអស់អាចធ្វើជាម្ចាស់លើទ្រព្យសម្បត្តិដែលតម្លៃកាន់តែឡើងខ្ពស់ ក្នុងពេលមានចំណង អាពាហ៍ពិពាហ៍ ដែលបានមកពីទ្រព្យសម្បត្តិរួម ឬទទួលបានមកពីទ្រព្យសម្បត្តិដោយឡែក។ កំណើនតម្លៃទ្រព្យសម្បត្តិនេះ ជួនកាលគេហៅថា «ការកើនតម្លៃទ្រព្យសម្បត្តិ»។ កំណើន ឬការកើននៃទ្រព្យសម្បត្តិនេះ អាចកើតមានឡើង ពីព្រោះភាគីទាំងអស់បានធ្វើការយ៉ាងលំបាក ឬការកើនតម្លៃទ្រព្យសម្បត្តិនេះអាចកើតមាន ដោយពុំចាំបាច់មានការខិតខំរបស់សហព័ទ្ធម្នាក់ណាទេ ប៉ុន្តែដោយសារការរីកចម្រើនសេដ្ឋកិច្ច។ ឧទាហរណ៍៖ ទ្រព្យសម្បត្តិអាចកាន់តែមានតម្លៃ ដូចជាតម្លៃជួលដី ជួលផ្ទះ ឬ ការឡើងថ្លៃនៃអចលនវត្ថុដោយសារសេដ្ឋកិច្ចមានសភាពកាន់តែល្អប្រសើរឡើង។ ដីធ្លីអាចមានតម្លៃកាន់តែខ្ពស់ ពីព្រោះសេដ្ឋកិច្ចកម្ពុជាកាន់តែរីកចម្រើន។ បញ្ហាបានកើតមានថានរណាជាម្ចាស់នៃកំណើនតម្លៃទ្រព្យសម្បត្តិទាំងនេះ?

នៅពេលទ្រព្យសម្បត្តិមានម្ចាស់រួមគ្នាកើនតម្លៃនៃកំណើននេះ ក៏ត្រូវចាត់ជាទ្រព្យសម្បត្តិរួមគ្នាដែរ។ ប្តី និងប្រពន្ធមានសិទ្ធិលើចំណែករួមគ្នា ក្នុងផលប្រយោជន៍ដែលបានមកពីកំណើនតម្លៃនៃចលនវត្ថុ ឬអចលនវត្ថុ។

ឧទាហរណ៍៖

១-នាងរំដួល និងលោកជន បានរៀបអាពាហ៍ពិពាហ៍។ គ្រួសារនាង រំចួល បានឱ្យដីស្រែសម្រាប់ធ្វើកសិកម្មមួយកន្លែងដល់នាង រំដួល និង លោក ថន នៅពេលអ្នកទាំងពីរបានរៀបអាពាហ៍ពិពិពាហ៍។ នៅពេលនោះ ដីស្រែមានតម្លៃ១០០០០ដុល្លារ។ ដប់ឆ្នាំ ក្រោយមក នាងរំដួល និងលោកថននៅតែជាប្តីប្រពន្ធ។ តម្លៃដីបានឡើងថ្លៃដប់ដង។ អ្នកទាំងពីរសម្រេចលក់ដីស្រែនោះ ហើយបែងចែកប្រាក់គ្នា។ នៅក្រោមច្បាប់តើអ្នកទាំងពីរត្រូវ ចែកប្រាក់ដូចម្តេច?

២-នាងបុប្ផា និងលោកសុជាតិ បានរៀបអាពាហ៍ពិពាហ៍នឹងគ្នា។ អ្នក ទាំងពីរបានទិញហាងតូចមួយ។ នាងបុប្ផា បានធ្វើការនៅក្នុងហាងនោះចំនួន៥ឆ្នាំ ហើយអាជីវកម្មមានការកើនឡើង។ លោក សុជាតិ បានធ្វើការនៅក្នុងរដ្ឋាភិបាល។ លោកបានចំណាយ ប្រាក់ទាំងអស់របស់គាត់សម្រាប់តែវត្ថុផ្សេងៗ ដើម្បីខ្លួនគាត់ផ្ទាល់។ អ្នកទាំងពីរបានលក់ហាងជំនួញនោះ។ តាមច្បាប់តើ អ្នកទាំងពីត្រូវចែកប្រាក់គ្នាដូចម្តេច?

នៅពេលដែលទ្រព្យសម្បត្តិផ្ទាល់ខ្លួនបានកើនតម្លៃ មានវិធីជាច្រើនខុសគ្នាក្នុងការដោះស្រាយកំណើននោះ ដើម្បីឱ្យសហព័ទ្ធ ម្នាក់ៗអាចទទួលផលបានដោយត្រឹមត្រូវ។ តាមធម្មតា កំណើន តម្លៃនឹងមិនផ្លាស់ប្តូរដល់ការបែងចែកប្រភេទទ្រព្យសម្បត្តិ ដែលជា ទ្រព្យសម្បត្តិផ្ទាល់ខ្លួនទេ ប៉ុន្តែអាចកើតមានករណីជាច្រើន ដែលក្នុងនោះកំណើនតម្លៃ គឺជាលទ្ធផលដែលបានមកពីការខិតខំរួមគ្នា ដ៏សម្បើមរបស់សហព័ទ្ធទាំងពីរនាក់។ ក្នុងករណីនោះ តុលាការ អាចសម្រេចថា ការរួមវិភាគទានរួមគ្នាមានភាពធំធេងណាស់ដែល ទ្រព្យសម្បត្តិត្រូវតែបានបញ្ជាក់លក្ខណៈជាថ្មី ពីទ្រព្យសម្បត្តិផ្ទាល់ខ្លួនទៅជាទ្រព្យសម្បត្តិរួម ឬយ៉ាងហោចណាស់ត្រូវតែបានចាត់ទុកថា

មួយផ្នែកជាទ្រព្យសម្បត្តិរួម ហើយមួយចំណែកទៀតជាទ្រព្យសម្បត្តិផ្ទាល់ខ្លួន។ យើងដឹងថា គ្មានច្បាប់ណាមួយអាចផ្តល់និយមន័យលម្អិត ពីទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិផ្ទាល់ខ្លួនដែលនឹងរាប់បញ្ចូល គ្រប់សភាពការណ៍នោះទេ។ កាលណាមានបញ្ហាអំពីការចាត់ថ្នាក់ លក្ខណនៃទ្រព្យសម្បត្តិជាទ្រព្យសម្បត្តិរួម ឬទ្រព្យសម្បត្តិផ្ទាល់ខ្លួន ធ្វើតាមទំនៀមទម្លាប់ក្នុងការធ្វើសេចក្តីសម្រេច ប្រហែលនឹងប៉ះពាល់ដល់សេចក្តីសម្រេចនានារបស់ចៅក្រមដែលបានធ្វើទាក់ទងទៅនឹងទ្រព្យសម្បត្តិ ។ ចៅក្រមអាចដឹងថា អ្វីខ្លះជាវិធានតាម ប្រពៃណី។ ចំពោះបញ្ហានេះជាការសំខាន់ណាស់ដែលត្រូវយល់ តើនិយមន័យនៃទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិផ្ទាល់ខ្លួនតាមផ្លូវច្បាប់ មានការខុសគ្នាពីវិធានតាមប្រពៃណីដូចម្តេច?[23]

**២.១.៥. សិទ្ធិគ្រប់គ្រងលើទ្រព្យសម្បត្តិក្នុងពេលមានអាពាហ៍ពិពាហ៍**

ការចាត់ចែងទ្រព្យសម្បត្តិសហព័ទ្ធ ពុំមែនជារឿងដូចគ្នាទៅនឹងកម្មសិទ្ធទ្រព្យសម្បត្តិទេ។ ការចាត់ចែងមានន័យថា ជាសិទ្ធ និងការទទួលខុសត្រូវក្នុងការគ្រប់គ្រង ឬត្រួតត្រាទ្រព្យសម្បត្តិ។ ការចាត់ចែងទ្រព្យសម្បត្តិជាប់ទាក់ទងទៅនឹងសិទ្ធិថែទាំទ្រព្យសម្បត្តិ សិទ្ធិធ្វើឱ្យមានលក្ខណៈល្អឡើង និងសិទ្ធិចំណាយលើទ្រព្យសម្បត្តិ ឬលៃទុកសម្រាប់សងបំណុល។ ការចាត់ចែងទ្រព្យសម្បត្តិក៏ជាប់ទាក់ទងទៅនឹងការទទួលខុសត្រូវដើម្បីថែរក្សាទ្រព្យសម្បត្តិ និងចៀសវាងការបាត់បង់ ឬការវិនាសអន្តរាយទ្រព្យសម្បត្តិផងដែរ។

សិទ្ធិចាត់ចែងនិងគ្រប់គ្រងទាំងទ្រព្យសម្បត្តិផ្ទាល់ខ្លួន ទាំងសិទ្ធិចាត់ចែងសម្បត្តិរួម ត្រូវបានកំណត់ដោយក្រមរដ្ឋប្បវេណីថ្មី។ សហព័ទ្ធម្នាក់ៗមានសិទ្ធិពេញលេញក្នុងការប្រើប្រាស់ អាស្រ័យផលនិងចាត់ចែងទ្រព្យសម្បត្តិផ្ទាល់ខ្លួន។ សិទ្ធិចាត់ចែងនិងគ្រប់គ្រងទ្រព្យសម្បត្តិផ្ទាល់ខ្លួនដោយពុំបាច់ធ្វើការពិគ្រោះជាមួយសហព័ទ្ធម្ខាងទៀត វិធានមានការខុសគ្នាចំពោះទ្រព្យសម្បត្តិរួម។ មាត្រា៩៧៤ នៃក្រមរដ្ឋប្បវេណីបានចែងថា «ប្តីប្រពន្ធមានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ ទទួលផលប្រយោជន៍ និងគ្រប់គ្រងទ្រព្យសម្បត្តិរួម។ សហព័ទ្ធ ត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរួមដោយសហការគ្នា។ សហព័ទ្ធម្ខាងអាចទាមទារចំពោះសហព័ទ្ធម្ខាងទៀត ឱ្យធ្វើចំណាត់ការដែលចាំបាច់ដើម្បីគ្រប់គ្រង និងរក្សាទុកនូវ ទ្រព្យសម្បត្តិរួមបាន...»។ ច្បាប់តម្រូវឱ្យសហព័ទ្ធទាំងពីរធ្វើសេចក្តីសម្រេចរួមគ្នា និង ស្មើគ្នាអំពីទ្រព្យសម្បត្តិរួម។

ទោះបីជាពាក្យពេចន៍នៅក្នុងក្រមរដ្ឋប្បវេណីមានលក្ខណច្បាស់លាស់ និងត្រង់ក្តីក៏ ទំនៀមទម្លាប់ និងការអនុវត្តក្នុងអាពាហ៍ពិពាហ៍នៅក្នុងសង្គមមានការខុសគ្នាពីអ្វីដែលត្រូវបានសរសេរនៅក្នុងច្បាប់។ គឺជាការសំខាន់ណាស់ក្នុងការគិតគូរពីបទពិសោធន៍របស់ប្រជាពលរដ្ឋយ៉ាងណាហើយ ដើម្បីឱ្យបានដឹងថាតើការផ្លាស់ប្តូរអាច ឬពុំអាចកើតមានក្នុងពេលអនាគត។

[23] នីតិគ្រួសារ និង អាពាហ៍ពិពាហ៍, ភាគ១, បោះពុម្ពលើកទី២, ២០២១ ទំព័រទី១៧៣ ដល់ ១៧៥, ឥន យឿន។

ឧទាហរណ៍៖

១-លោកវុធី និងនាងធីតា បានរៀបអាពាហ៍ពិពាហ៍១០ឆ្នាំមកហើយ។ អ្នកទាំងពីរមានកន្លែងអាជីវកម្មតូចមួយរួមគ្នា។ លោក វុធី មានបំណងពង្រីកអាជីវកម្ម ប៉ុន្តែនាងធីតា មិនចង់ចំណាយ ប្រាក់ដែលអ្នកទាំងពីរបានសន្សំ ដើម្បីបង្កើតអាជីវកម្មថ្មីទេ។ នាងធីតា ខ្លាចខាតឡុងចុងអស់។ នាងសុំឱ្យតុលាការសម្រេច។

២-នាងឆវី និងលោកដារា បានរៀបអាពាហ៍ពិពាហ៍ដប់ឆ្នាំហើយ។ អ្នកទាំងពីរមានដីចំការតូចមួយ។ លោកដារា ថាចង់ទិញដីច្រើន ថែមទៀតដោយយកប្រាក់គ្រួសារមកទិញ។ នាងឆវី មានបំណងចេញប្រាក់សម្រាប់សិក្សារបស់កូនប្រុស។ លោកដារា បានយកប្រាក់នេះហើយទិញដី។ នាងឆវី គិតសុំឱ្យតុលាការឱ្យសម្រេចរឿងនេះ។[24]

## ២.១.៦. ការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ

ការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ មាត្រា ៩៧៦ នៃក្រមរដ្ឋប្បវេណីបានកំណត់នូវលក្ខខណ្ឌសំខាន់សម្រាប់ប្តីប្រពន្ធឱ្យធ្វើការចាត់ចែងទ្រព្យសម្បត្តិរួម ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ដូចខាងក្រោម ៖

### ក- ការលក់ទ្រព្យសម្បត្តិរួមត្រូវមានការយល់ព្រមពីសហព័ទ្ធ

ក្រមរដ្ឋប្បវេណីបានចែងថា «បើគ្មានការយល់ពីប្តីប្រពន្ធទាំងសងខាងទ្រព្យសម្បត្តិរួមប្តីប្រពន្ធ មិនអាចយកទៅលក់ ឬធ្វើការចាត់ចែងផ្សេងទៀតបានឡើយ»។ ច្បាប់មិនបានចែងថា តើសហព័ទ្ធម្នាក់ៗត្រូវសំដែងការយល់ព្រមរបស់ខ្លួនដូចម្តេចទេ។ ជួនកាលអាចមានការលំបាកនឹងយល់ថា តើសហព័ទ្ធទាំងពីរបាន ឬមិនបានផ្តល់ការយល់ព្រម។ វិធីមួយដើម្បីបញ្ជាក់ថាសហព័ទ្ធទាំងពីរយល់ព្រមគឺថាតម្រូវឱ្យសហព័ទ្ធទាំងពីរចុះហត្ថលេខាលើឯកសារណាមួយដែលត្រូវលក់ ឬ ធ្វើអំណោយនៃទ្រព្យសម្បត្តិ។ ច្បាប់របស់ប្រទេសខ្លះបានតម្រូវឱ្យធ្វើរបៀបនេះ។

### ខ- ការលក់ទ្រព្យសម្បត្តិរួមត្រូវមានការយល់ព្រមពីតុលាការ

ក្រមរដ្ឋប្បវេណីបានផ្តល់លទ្ធភាពចាំបាច់នានាសម្រាប់ប្តីឬប្រពន្ធតែម្ខាងអាចលក់ទ្រព្យសម្បត្តិបានដែរក្នុងករណីចាំបាច់ ឬ ក្នុងករណីស្ថានភាពតម្រូវទោះបីភាគីម្ខាងទៀតមិនផ្តល់ការយល់ព្រមក៏ដោយគេអាចស្នើសុំទៅតុលា ការ ដើម្បីសម្រេចជំនួសសហព័ទ្ធម្ខាងទៀតបាន។ ក្រមរដ្ឋប្បវេណីបានកំណត់ថា ប្រសិនបើស្ថានភាពមិនអាចចៀសវាងបានសម្រាប់ការថែទាំជីវភាពរួមក្នុង ពេលមានចំណងអាពាហ៍ពិពាហ៍និងដើម្បីរក្សាជីវភាពរស់នៅនោះប្តីប្រពន្ធម្ខាងអាចលក់ ឬធ្វើការចាត់ចែងផ្សេងនូវទ្រព្យសម្បត្តិរួមបាន ដោយមានការយល់ព្រមពីតុលាការ។ បើសិនច្បាប់បានផ្តល់ឆន្ទានុសិទ្ធិឱ្យ អ្វីជាបញ្ហាសំខាន់នៅត្រង់ថាតុលាការ ដើម្បីសម្រេចលក់ទ្រព្យសម្បត្តិរួមហើយមិនបានផ្តល់លទ្ធភាពឱ្យសហព័ទ្ធម្ខាងទៀតប្តឹងតវ៉ាបានក្នុងករណីដែលភាគីមិន សុខចិត្តចំពោះ

[24] នីតិគ្រួសារ និង អាពាហ៍ពិពាហ៍, ភាគ១, បោះពុម្ពលើកទី២, ២០២១, ទំព័រទី១៧៦ដល់១៧៨, ឥន យឿន។

សេចក្តីសម្រេចរបស់តុលាការ។ ច្បាប់ផ្តល់លទ្ធភាពឱ្យប្តីឬប្រពន្ធអាចប្តឹងតវ៉ាបានតែក្នុងករណីដែលការសម្រេចលក់ ឬចាត់ចែងលក់ដូរនោះ មិនមានការសម្រេចពីតុលាការ ឬ មិនមានការឯកភាពពីភាគីម្ខាងទៀតដែលមានដូចចំណុចខាងក្រោមនេះ។

**គ- ការប្តឹងតវ៉ាចំពោះការលក់ទ្រព្យសម្បត្តិរួម**

ក្នុងករណីដែលប្តី ឬ ប្រពន្ធតែម្ខាងណាបានលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀតនូវទ្រព្យសម្បត្តិរួមដោយគ្មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតផង ឬ គ្មានការអនុញ្ញាតពីតុលាការផង សហព័ទ្ធដែលមិនបានផ្តល់ការយល់ព្រម អាចទាមទារឱ្យលុបចោលនូវការចាត់ចែងនោះទៅតុលាការបាន នៅក្នុងអំឡុងពេល ២ ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមត្រូវបានចាត់ចែងនោះជាអចលនវត្ថុ។ ការប្តឹងសុំលុបនេះមានរយៈពេលត្រឹម ១ឆ្នាំ គិតពីពេលដែលបានដឹងអំពីការចាត់ចែងនោះ។ ប្រសិនបើទ្រព្យសម្បត្តិរួមត្រូវបានចាត់ចែងនោះ ជាទ្រព្យសម្បត្តិផ្សេង។[25]

## ២.២. ការទទួលខុសត្រូវលើបំណុល និងកាតព្វកិច្ចផ្សេងៗទៀត

ប្តីប្រពន្ធ ត្រូវទទួលខុសត្រូវដោយសាមគ្គីគ្នា ចំពោះកាតព្វកិច្ចទាំងឡាយ ដូចជាសោហ៊ុយសម្រាប់ការចំណាយជីវភាពប្រចាំថ្ងៃ របស់គ្រួសារ សោហ៊ុយសម្រាប់ការសិក្សាអប់រំរបស់កូន សោហ៊ុយសម្រាប់ការព្យាបាលជំងឺ និងក្នុងករណីពិធីរវល់ចាំបាច់ណាមួយ ដូចជាចូលក្នុងបុណ្យទាន ពិធីមង្គលការជាដើម។ ប្តីប្រពន្ធ ត្រូវទទួលខុសត្រូវចំពោះកាតព្វកិច្ចទាំងឡាយ ដែលភាគីទាំងពីរបានព្រមព្រៀងគ្នាតាមរយៈលិខិតលាយលក្ខណ៍អក្សរជាមួយម្ចាស់បំណុល ឬជាមួយកូនបំណុល ឬជាប់បំណុលទាំងឡាយដែលភាគីតែម្ខាងបានធ្វើជាលាយលក្ខណ៍អក្សរ ហើយមានការយល់ព្រមពីភាគីម្ខាងទៀត។ សោហ៊ុយចំណាយសម្រាប់ការថែរក្សាទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធ។ រាល់ការចំណាយទាំងអស់នៅក្នុងផ្នែកនេះ ជាបន្ទុករបស់ទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ។ ក្នុងករណីដែលភាគីម្ខាងបានជាប់បំណុលគេដោយគ្មានការយល់ព្រមពីភាគីម្ខាងទៀត ដើម្បីប្រើប្រាស់ជាប្រយោជន៍ផ្ទាល់ខ្លួនរបស់ភាគីតែម្ខាង នោះភាគីដែលបានជំពាក់បំណុលគេនោះត្រូវទទួលខុសត្រូវតែម្នាក់ឯង។ ប៉ុន្តែក្នុងករណីដែលភាគីតែម្ខាងបាន ជំពាក់បំណុលគេ ហើយមិនមានការដឹងឮពីភាគីម្ខាងទៀត ហើយយកបំណុលនោះមកប្រើប្រាស់ក្នុងជីវភាពគ្រួសាររួម សហព័ទ្ធម្ខាងទៀតដែលមិនបានដឹងនោះក៏ចូលរួមទទួលខុសត្រូវផងដែរ។[26]

[25] នីតិគ្រួសារ និង អាពាហ៍ពិពាហ៍, ភាគ១, បោះពុម្ពលើកទី២, ២០២១, ទំព័រទី១៧៩ដល់១៨១, ឥន យឿន។

[26] នីតិគ្រួសារ និង អាពាហ៍ពិពាហ៍, ភាគ១, បោះពុម្ពលើកទី២, ២០២១, ទំព័រទី១៦៨ដល់១៦៩, ឥន យឿន។

### ២.២.១. ការទទួលខុសត្រូវដោយសាមគ្គីភាព ចំពោះកាតព្វកិច្ច

ប្ដីប្រពន្ធ ត្រូវទទួលខុសត្រូវដោយសាមគ្គីភាព ចំពោះកាតព្វកិច្ចដែលកំណត់ខាងក្រោមនេះ ៖

ក-សោហ៊ុយដើម្បីរក្សាជីវភាពរួមរបស់ប្ដីប្រពន្ធ និងសោហ៊ុយដើម្បីការអប់រំ ឬការព្យាបាល ថែទាំកូនជាអាទិ៍។

ខ-កាតព្វកិច្ច និងករណីយកិច្ចផ្សេងៗទៀត ដែលប្ដីប្រពន្ធទាំងសងខាងបានព្រមព្រៀងតាមលិខិតជាលាយល័ក្ខណ៍អក្សរជាមួយម្ចាស់បំណុលនៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ឬកាតព្វកិច្ច និងករណីយកិច្ចផ្សេងៗទៀតដែលប្ដី ឬប្រពន្ធណាម្ខាងបានទទួលបន្ទុក ដោយមានការយល់ព្រមតាមលិខិតជាលាយល័ក្ខណ៍អក្សរពីប្រពន្ធ ឬប្ដី ម្ខាងទៀត នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។

គ-សោហ៊ុយដើម្បីគ្រប់គ្រង និងរក្សាទ្រព្យសម្បត្តិរួម។[27]

ឧទាហរណ៍៖ ក្រោយពីរៀបអាពាហ៍ពិពាហ៍ ៣ឆ្នាំក្រោយមក ស្រីពៅបានបង្កើតកូនប្រុស ម្នាក់ឈ្មោះចិត្រាក្រោយពីរៀបអាពាហ៍ពិពាហ៍ ៥ ឆ្នាំ ប្រាក់សន្សំរបស់ សីហា និងស្រីពៅបានកើនឡើងដល់ ១២០០០ ដុល្លារ។ អ្នកទាំង២ បានគិតថានឹងទិញផ្ទះល្វែងនៅក្បែរពោធិ៍ចិនតុង។ ផ្ទះនោះ មានតម្លៃសរុបរួមទាំងដី ៥០០០០ដុល្លារ។ ដូច្នេះ អ្នកទាំង២ បានខ្ចីលុយពីធនាគារចំនួន ៤០០០០ដុល្លារ ហើយបានដកលុយរបស់ខ្លួនឯង ចំនួន១០០០០ដុល្លារ សរុប ៥០០០០ដុល្លារ បង់ទៅឱ្យអ្នកលក់ ហើយបានទិញយកផ្ទះនោះ។ អ្នកទាំង ២ បានធ្វើកិច្ចសន្យាឥណទានជាមួយនឹងធនាគារ។ កិច្ចសន្យា ឥណទាននោះ មានខ្លឹមសារថា នឹងសងប្រាក់កម្ចីទាំងអស់ចំនួន៤០០០០ ដុល្លារ ដោយធ្វើការសងចំនួនប្រាក់៤០០ដុល្លារជារៀងរាល់ខែ រយៈពេល ១០០ខែ ស្មើនឹង៨ឆ្នាំ ៤ខែ។ សីហា និង ស្រីពៅ បានចុះហត្ថលេខាទាំងពីរនាក់ក្នុងនាមជាកូនបំណុល លើកិច្ចសន្យាឥណទាននោះ។ អ្នកទាំងពីរ បានចុះបញ្ជីដាក់ឈ្មោះរួមថា សីហា និង ស្រីពៅ ចំពោះដីនិងផ្ទះថ្មីនោះ។ ចិត្រាដែលជាកូនរបស់សីហា និង ស្រីពៅ មានជម្ងឺបេះដូងតាំងពីកំណើត។ ដើម្បីព្យាបាលជម្ងឺនោះ ចាំបាច់ត្រូវតែទទួលការវះកាត់ នៅមន្ទីពេទ្យក្នុងទីក្រុងបាំងកក។ ដើម្បីព្យាបាលចាំបាច់ត្រូវចំណាយប្រាក់សរុបចំនួន១០០០០ដុល្លារ។ ដូច្នេះ សីហា បានខ្ចី លុយពីមិត្តភក្តិរៀននៅសាកលវិទ្យាល័យចំនួន១០០០០ដុល្លារ។ សីហា និងស្រីពៅ បានយកចិត្រាទៅធ្វើការវះកាត់នៅមន្ទីពេទ្យក្នុង ទីក្រុងបាងកក ហើយជម្ងឺរបស់ចិត្រាក៏បានជាសះស្បើយ។ សីហាគិតថា ចង់មានទំនាក់ទំនងជាមួយនឹងរស្មីដែលជាសិស្សប្អូននៅកន្លែងធ្វើការដោយសំងាត់ មិនឱ្យស្រីពៅដឹង។ ដូច្នេះ សីហាបានខ្ចីលុយ ពីប្អូនប្រុសចំនួន១០០០ដុល្លារ ហើយបានទិញទូរស័ព្ទ សំលៀកបំពាក់ និង គ្រឿងអលង្ការ។ បន្ទាប់មកបានធ្វើជាកាដូឱ្យទៅរស្មី។ តើសីហា និង ស្រីពៅត្រូវទទួលខុសត្រូវដោយសាមគ្គីភាពចំពោះកាតព្វកិច្ចខាងក្រោមនេះដែរឬទេ?

[27] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៧៥។

- កាតព្វកិច្ចចំពោះធនាគារនូវប្រាក់ចំនួន៤០០០០ដុល្លារ
- កាតព្វកិច្ចចំពោះមិត្តភក្តិរៀនសាកលវិទ្យាល័យជាមួយសីហានូវប្រាក់ ចំនួន១០០០០ដុល្លារ
- កាតព្វកិច្ចចំពោះប្អូនប្រុសរបស់សីហានូវប្រាក់ចំនួន១០០០ដុល្លារ

កាតព្វកិច្ច ៤០០០០ដុល្លារចំពោះធនាគារ គឺជាកាតព្វកិច្ចដែលប្តីប្រពន្ធទាំងសងខាងបានព្រមព្រៀងគ្នាដោយលាយលក្ខណ៍អក្សរ។ ដូច្នេះ អ្នកទាំងពីរត្រូវទទួលខុសត្រូវដោយសាមគ្គីភាព។

កាតព្វកិច្ចចំនួន ១០០០០ដុល្លារ ដែលសីហា មានចំពោះមិត្តភក្តិរៀននៅសាកលវិទ្យាល័យជាមួយគ្នា គឺជាកាតព្វកិច្ចដែលប្រើប្រាស់ដើម្បីថ្លៃព្យាបាលកូន ដូច្នេះ អ្នកទាំងពីរត្រូវទទួលខុសត្រូវដោយសាមគ្គីភាព។

កាតព្វកិច្ចចំនួន ១០០០ដុល្លារដែលសីហាមានចំពោះប្អូនប្រុស គឺជាកាតព្វកិច្ចដើម្បីអំពើសាវារបស់សីហា ដូច្នេះ ស្រីពៅមិនត្រូវទទួលខុសត្រូវដោយសាមគ្គីភាពទេ។[28]

[28] សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, សិក្ខាសាលាក្រមរដ្ឋប្បវេណីលើកទី ៦, ប្រព័ន្ធទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ។

# ជំពូកទី២
# ប្រព័ន្ធទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមកិច្ចសន្យា

# ជំពូកទី២

# ប្រព័ន្ធទ្រព្យសម្បត្តិរបស់សហព័ទ្ធតាមកិច្ចសន្យា

ជាការពិតណាស់ នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់មនុស្សក្នុងសង្គមការប្រាស្រ័យទាក់ទងគ្នាគឺជាកត្តាចាំបាច់ដែលជៀសមិនផុតអំពីទំនាក់ទំនងនេះឡើយ។ យ៉ាងណាមិញ នៅក្នុងការប្រាស្រ័យទាក់ទងគ្នានេះផងដែរ មនុស្សរមែងតែងតែប្រព្រឹត្តនៅកំហុសដែលជាមូលហេតុចម្បងធ្វើឱ្យមានជម្លោះកើតឡើង។ បើយើងសង្កេតមើលទៅលើការដោះស្រាយជម្លោះ ឬវិវាទរបស់មនុស្សវិញក្រៅពីការចរចារ សម្រុះសម្រួលគ្នា បទដ្ឋានគតិយុត្តនិងបទបញ្ញត្តិផ្សេងៗទៀត ត្រូវបានបង្កើតឡើងជាបន្តបន្ទាប់វាអាស្រ័យទៅលើតម្រូវការ និងបរិបទនៃសង្គមដើម្បីស្វែងរកនូវដំណោះស្រាយដ៏សមស្រប និងប្រកបទៅដោយប្រសិទ្ធភាពណាមួយ។

ដូចដែលយើងទាំងអស់គ្នាបានដឹងហើយថា ប្រទេសកម្ពុជាយើងធ្លាប់បានឆ្លងកាត់សង្គ្រាមរ៉ាំរ៉ៃអស់រយៈពេលជាច្រើនឆ្នាំកន្លងមក ដែលជាហេតុធ្វើឱ្យវិស័យគតិយុត្ត ពោលគឺប្រព័ន្ធច្បាប់របស់កម្ពុជាត្រូវបានបំផ្លិចបំផ្លាញស្ទើរតែទាំងស្រុងនឹងជាកត្តាបណ្តាលឱ្យច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាត្រូវបានគេយកមកប្រើប្រាស់ដើម្បីដោះស្រាយវិវាទនឹងបង្ករឱ្យមានភាពខ្វះខាត ដែលតម្រូវឱ្យមានការបង្កើតបន្ថែមរាល់នូវបទដ្ឋានគតិយុត្តនានា ដើម្បីពង្រឹងយន្តការដោះស្រាយជម្លោះដែលកើតឡើងនេះប្រកបដោយប្រសិទ្ធភាព។ ជាក់ស្តែងនៅក្នុងរឿងក្តីរដ្ឋប្បវេណី ជាពិសេសក្នុងរឿងអាពាហ៍ពិពាហ៍ និងគ្រួសារ បញ្ហា ឬវិវាទភាគច្រើនរមែងតែងតែមានការជាប់ទាក់ទងអំពីបញ្ហាទ្រព្យសម្បត្តិនេះ។ ដូច្នេះយើងសង្កេតឃើញថាជម្លោះទាក់ទងអំពីបញ្ហាទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ ជានិច្ចកាលតែងតែកើតមានឡើងនៅក្នុងបាតុភូតសង្គមជាក់ស្តែង ទើបធ្វើឱ្យប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធមានការវិវត្តទៅមុខឥតឈប់ឈរ ហើយនៅក្នុងនោះទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យាក៏ត្រូវបានបង្កើតឡើង។ ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យានេះ គេធ្វើឡើងក្នុងគោលបំណងដើម្បីការពារសិទ្ធិរបស់ភាគីដែលជាសហព័ទ្ធ និងទប់ស្កាត់ជាមុនមិនឱ្យមានការកែប្រែផ្លូវច្បាប់ និងស្ថានភាពជាក់ស្តែង ព្រមទាំងកំណត់ឱ្យបានច្បាស់លាស់អំពីទំនាក់ទំនងទ្រព្យសម្បត្តិប្តីប្រពន្ធ និងចងភ្ជាប់នូវចំណងកាតព្វកិច្ចប្តីប្រពន្ធក្នុងតម្រូវការគ្រួសារ និងបង្ការនៅភាពស្មុគស្មាញក្នុងការធ្វើបំណែងចែកទ្រព្យសម្បត្តិ នៅពេលដែលសហព័ទ្ធបញ្ចប់កិច្ចសន្យាអាពាហ៍ពាពិពាហ៍ផងដែរ។

ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា ដែលបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ត្រូវបានតាក់តែងឡើងក្រោមកិច្ចសហប្រតិបត្តិការរវាងក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ទើបសញ្ញាណនៃការកំណត់ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា ត្រូវបានដាក់បញ្ចូលនៅក្នុងក្រមរដ្ឋប្បវេណីថ្មីឆ្នាំ ២០០៧ របស់កម្ពុជា គឺមានចែងនៅត្រង់មាត្រា ៩៦៩ ដល់មាត្រា ៩៧០។ បើផ្អែកតាមតែបទបញ្ញត្តិនៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ត្រឹមតែ ២ មាត្រានេះ គឺមិន

មានភាពគ្រប់គ្រាន់សម្រាប់ការអនុវត្តនោះឡើយ ព្រោះថា បើយោងទៅតាមមាត្រាទាំង ២ នេះមិនបានបង្ហាញអំពីបែបបទ នីតិវិធី និងទម្រង់នៃការចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យាឡើយ។ ចំពោះការកំណត់អំពីបែបបទ នីតិវិធី និងទម្រង់នៃការចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា គឺត្រូវបានបញ្ញត្តិនៅក្នុងប្រកាសរបស់ក្រសួងយុត្តិធម៌ នោះគឺប្រកាសស្តីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ នាថ្ងៃទី ០៩ ខែសីហា ឆ្នាំ២០១៣នេះឡើង។[29] ក្រោមការចង្អុលបង្ហាញនៅក្នុង ជំពូកទី៤ ស្តីពី ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ចាប់ពីមាត្រា ២៦ ដល់មាត្រា ៣២ នៃច្បាប់ស្តីពី ការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ ២០១១។ គួយ៉ាង ដើម្បីជ្រើសរើសការគ្រប់គ្រងទ្រព្យសម្បត្តិ តាមប្រព័ន្ធកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះ គប្បីធ្វើការស្វែងយល់ឱ្យបានច្បាស់នូវសញ្ញាណទូទៅនៃប្រព័ន្ធទ្រព្យសម្បត្តិរបស់ប្តីប្រព័ន្ធតាមកិច្ចសន្យា(ផ្នែកទី១)និង លក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (ផ្នែកទី២) ជាមុនសិន។

## ផ្នែកទី១ សញ្ញាណទូទៅនៃប្រព័ន្ធទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធតាមកិច្ចសន្យា

សញ្ញាណទូទៅនៃប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យានឹងបង្ហាញអំពីប្រវត្តិដើម ក៏ដូចជាការវិវត្តនៃប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យានៅក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងឆ្លុះបញ្ចាំងអំពីគោលគំនិតដែលបង្កប់នៅក្នុងការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះ។ ផ្នែកនេះរៀបរាប់អំពី មូលហេតុ ក៏ដូចជាគុណប្រយោជន៍នៃការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ និងការវិវត្តនៅក្នុងវិស័យគតិយុត្ត ដែលចែងទៅលើប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យានៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ការព្រមព្រៀងរបស់សហព័ទ្ធទាំងសងខាង ចំពោះការកំណត់អំពីសិទ្ធិទៅលើទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធនេះគឺ មានតាំងពីមុនការបង្កើតនូវប្រព័ន្ធទ្រព្យសម្បត្តិ ដែលចែងនៅក្នុងក្រមរដ្ឋប្បវេណីទៅទៀត។ គេសង្កេតឃើញថាកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធច្រើនធ្វើឡើងនៅក្នុងកាលៈទេសៈនៃការលែងលះគ្នា ដោយធ្វើការព្រមព្រៀងគ្នារវាងសហព័ទ្ធនៅក្នុងការបែងចែកទ្រព្យសម្បត្តិ តាមរយៈនៃការចុះកិច្ចសន្យាអំពីសិទ្ធិទៅលើទ្រព្យរវាងសហព័ទ្ធ។

### ១.១. ការវិវត្តនៃប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា

ដើមឡើយប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យាត្រូវបានគេកត់សម្គាល់ថា ស្តែងឡើងតាមរយៈការលែងលះដែលមានការព្រមព្រៀងគ្នា នៅក្នុងការបែងចែងទ្រព្យសម្បត្តិនៅចំពោះមុខតុលាការ។ ក្រោយមកមានបណ្តាលប្រទេសជាច្រើនបានយល់ឃើញថា ចំណងអាពាហ៍ពិពាហ៍ មិនអាចជាមូលហេតុដាច់ខាតធ្វើឱ្យ ទ្រព្យក្រោយអាពាហ៍ពិពាហ៍ស្ថិតនៅក្នុងចំណងនៃទ្រព្យរួមទាំងស្រុងនោះទេ។ ដូច្នេះវាត្រូវបានបង្ហាញនូវសេរីភាព និង

[29] លោកជំទាវ ចាន់ សុទ្ធាវី (រដ្ឋលេខាធិការក្រសួងយុត្តិធម៌), https://youtu.be/fLCbqZyfNbw។

ឯករាជ្យភាពរបស់សហព័ទ្ធ ដោយអាពាហ៍ពិពាហ៍មានឥទ្ធិពលតែទៅលើទំនាក់ទំនងឋានៈបុគ្គលតែប៉ុណ្ណោះ។ រីឯទ្រព្យសម្បត្តិវិញគឺស្ថិតទៅតាមការសម្រេច និងគោលបំណងរបស់សហព័ទ្ធទាំងសងខាង។ ហេតុនេះហើយ នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ការវិវត្តន៍នៃប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា មានដំណាក់កាលពីរ ដែលយើងអាចស្វែងយល់ពីការបង្កើតនូវលិខិតបទដ្ឋានគតិយុត្ត ដែលទាក់ទងទៅនឹងប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យានេះ។ ជាដំបូងច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ និងក្រោយមកទៀតមានការបង្កើតសញ្ញាណនៃប្រព័ន្ធទ្រព្យតាមកិច្ចសន្យា នៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ និងក្រោយមកទើបមានការបែងចែកពីភាពស៊ីជម្រៅនៃប្រព័ន្ធទ្រព្យតាមកិច្ចសន្យានេះតាមរយៈ ច្បាប់ស្តីពីការអនុវត្តន៍ក្រមរដ្ឋប្បវេណីឆ្នាំ២០១១ និងជាចុងក្រោយបង្អស់នេះ ក្រសួងយុត្តិធម៌បានចេញនូវ ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយចង្អុលបង្ហាញពីនីតិវិធី និងទម្រង់បែបបទនៃការចុះបញ្ជី។

### ១.១.១. ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធនៅមុនការអនុវត្តក្រមរដ្ឋប្បវេណី

មុនពេលដែលមិនទាន់មានការអនុវត្តក្រមរដ្ឋប្បវេណី ការអនុវត្តច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ នៅតែបន្តរហូតដល់ថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០១១ ទើបមានការអនុវត្តក្រមរដ្ឋប្បវេណីបានពេញលេញទាំងស្រុង។ តាមការជាក់ស្តែង ក្រមរដ្ឋប្បវេណីត្រូវបានអនុម័តតាំងពីឆ្នាំ ២០០៧ ក៏ប៉ុន្តែការអនុវត្តនៅតែមិនអាចធ្វើទៅបាន ដោយមូលហេតុថាពុំទាន់មានច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីនៅឡើយ ហេតុនេះហើយត្រូវរង់ចាំឱ្យច្បាប់នេះចូលជាធរមាននៅថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០១១ និងប្រាំមួយខែក្រោយមកទើប ក្រមរដ្ឋប្បវេណីត្រូវបានប្រើនៅថ្ងៃទី២១ ខែ ធ្នូ ឆ្នាំ ២០១១។ ចំពោះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធវិញ ក៏ត្រូវមានការអនុវត្តទៅតាមបទដ្ឋានគតិយុត្តជាបន្តបន្ទាប់ផងដែរ ដើមឡើយមានប្រភពសញ្ញាណនៅក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ។

### ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យាដែលមាននៅក្នុងក្រមរដ្ឋប្បវេណី

ប្រព័ន្ធទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ ត្រូវបានធ្វើឡើងដើម្បីទប់ស្កាត់វិវាទអំពីទំនាក់ទំនងសិទ្ធិ និងករណីយកិច្ចរបស់ប្តីប្រពន្ធ។ នៅក្នុងទំនាក់ទំនងជាក់ស្តែងរបស់ប្តីប្រពន្ធមានលក្ខណៈច្រើនបែបច្រើនយ៉ាង ហើយប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យានេះ បានផ្តល់លទ្ធភាពឱ្យប្តីប្រពន្ធនូវ ជម្រើសដែលមានលក្ខណៈបត់បែនសមស្របទៅតាមភាពចាំបាច់របស់ប្តីប្រពន្ធជាក់លាក់។ ដូច្នេះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះ ក៏មានអានុភាពសម្របសម្រួលការពិភាក្សាអំពីអនាគតរបស់ប្តី ប្រពន្ធផងដែរ។ យ៉ាងណាមិញចំពោះមាត្រា ៩៧០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់សម្គាល់អំពីលក្ខខណ្ឌចាំបាច់នៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ នេះគឺទម្រង់នៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយសារតែកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះនាំឱ្យមានឥទ្ធិពលយ៉ាងខ្លាំងទៅលើទំនាក់ទំនងសិទ្ធិ និងករណីយកិច្ចលើទ្រព្យសម្បត្តិរវាងប្តីប្រពន្ធ។ បញ្ញត្តិក្នុងកថាខណ្ឌ២ នៃមាត្រាដដែលនេះផងដែរ ក៏តម្រូវឱ្យចុះបញ្ជីកិច្ចសន្យានេះក្នុង

ករណីដែលធ្វើខុសពីប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ ដើម្បីជៀសវាងនូវផលប៉ះពាល់អាក្រក់ចំពោះផលប្រយោជន៍របស់តតិយជន។ នៅក្នុងច្បាប់នៃប្រទេសដែលទទួលស្គាល់ការធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនៅក្រោយពេលរៀបអាពាហ៍ពិពាហ៍ ការកែប្រែកិច្ចសន្យានៅក្រោយការៀបអាពាហ៍ពិពាហ៍ ក៏ត្រូវបានទទួលស្គាល់ផងដែរ ក៏ប៉ុន្តែដើម្បីការពារតតិយជន ច្បាប់នៃប្រទេសកាណាដា និងអេស្ប៉ាញជាដើម បានហាមឃាត់ការធ្វើកិច្ចសន្យា និងការកែប្រែណាដែលប៉ះពាល់ដល់សិទ្ធិតតិយជន។

**១.១.២. ប្រព័ន្ធទ្រពសម្បត្តិប្តីប្រពន្ធ ក្រោយការអនុវត្តក្រមរដ្ឋប្បវេណី**

នៅក្រោយពេលដួលរលំរបបខ្មែរក្រហម រហូតដល់មុនពេលអនុម័តក្រមរដ្ឋប្បវេណីថ្មី កម្ពុជាមិនទាន់មានច្បាប់សារធាតុគ្រប់គ្រាន់ ដើម្បីដោះស្រាយវិវាទទាក់ទងនឹងរឿងរដ្ឋប្បវេណីនោះទេ ចំណែកឯរឿងអាពាហ៍ពិពាហ៍ និងគ្រួសារ ជាពិសេសទាក់ទងនឹងទ្រព្យរបស់សហព័ទ្ធ ក៏នៅមានការខ្វះខាតផងដែរ នៅពេលនោះកម្ពុជាមានត្រឹមតែច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និងគ្រួសារដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៥ តែប៉ុណ្ណោះ។ ក៏ប៉ុន្តែ ក្រោយមកក្រមរដ្ឋប្បវេណីថ្មីត្រូវបានអនុម័តនៅថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ លុះមកដល់ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ ទើបក្រមនេះត្រូវបានអនុវត្តជាផ្លូវការ។ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានក្លាយទៅជាមូលដ្ឋានថ្មីមួយនៅក្នុងការដោះស្រាយចំពោះរឿងក្តីរដ្ឋប្បវេណី និងគ្រប់គ្រងរាល់ទំនាក់ទំនងផ្សេងៗនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ដែលក្នុងនោះក៏រួមបញ្ចូលទាំងរឿង អាពាហ៍ពិពាហ៍ តួយ៉ាងដូចជាប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធជាដើម។ នៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា គន្ថីទី៧ ជំពូកទី៣ ពោលគឺចាប់ពីមាត្រា ៩៤៨ ដល់មាត្រា ៩៨២ សុទ្ធសឹងតែជាបទបញ្ញត្តិដែលទាក់ទងទៅនឹង «អាពាហ៍ពិពាហ៍» ដែលបានចែងអំពីការបង្កើតអាពាហ៍ពិពាហ៍ រហូតដល់ការលែងលះ។ ចំណែកឯប្រព័ន្ធទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធក៏មានបញ្ញត្តិចង្អុលបង្ហាញផងដែរ នៅក្នុងផ្នែកទី៣ ចាប់ពីមាត្រា ៩៦៩ ដល់ មាត្រា ៩៧០។ ជាការពិតណាស់ នៅតាមបណ្តាលប្រទេសជឿនលឿនមួយចំនួន ដើម្បីបើកឱកាសភាគីអាចកំណត់ឱ្យបានច្បាស់លាស់នូវទំនាក់ទំនងទ្រព្យសម្បត្តិទាំងនោះ និងងាយស្រួលដល់ការដោះស្រាយវិវាទទៅលើទំនាក់ទំនងទ្រព្យសម្បត្តិ គេបានរៀបចំឱ្យមានបទបញ្ញត្តិ ដែលទាក់ទងទៅនឹងការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ។ ប្រកាសរបស់ក្រសួងលេខ ៨កយ.ប្រក/១៣ ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៣ ដោយបានបង្កើតឡើងក្រោមការចង្អុលបង្ហាញនៃមាត្រា ២៦ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីដែលបានបញ្ជាក់ និងប្រគល់សមត្ថកិច្ចឱ្យក្រសួងយុត្តិធម៌ មានសមត្ថកិច្ចលើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយក្រសួងត្រូវរៀបចំបែបបទ និងទម្រង់នៃការចុះបញ្ជីតាមរយៈប្រកាសរបស់ក្រសួង។ ប្រកាសនេះត្រូវបានចងក្រងឡើងដើម្បីអនុញ្ញាតឱ្យប្តីប្រពន្ធ ឬបុគ្គលដែលត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា អាចធ្វើការចុះបញ្ជីកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិ ដើម្បីកំណត់ឱ្យបាន

ច្បាស់លាស់អំពីទំនាក់ទំនងទ្រព្យសម្បត្តិប្តីប្រពន្ធ ព្រមទាំងដើម្បីធានានូវប្រសិទ្ធភាព នៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ឱ្យបានត្រឹមត្រូវតាមក្រមរដ្ឋប្បវេណី និងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីផងដែរ។

## ១.២. គោលគំនិតនៃការបង្កើតប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា

គោលគំនិតនៃការបង្កើតប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា អាពាហ៍ពិពាហ៍រវាងប្តីប្រពន្ធគឺត្រូវបានបង្កើតចំណងគតិយុត្តមួយដែលអាចកកើតបាននូវ ឥណទេយ្យ និងបំណុលរវាងសហព័ទ្ធ។ ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យា គេធ្វើឡើងដោយគោរពតាមឆន្ទៈព្រមព្រៀងរបស់សហព័ទ្ធ ក៏ប៉ុន្តែការព្រមព្រៀងនេះមិនអនុញ្ញាតឱ្យធ្វើផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ឬផ្ទុយនឹងច្បាប់ដែលបានកំណត់នោះទេ។ តាមរយៈប្រព័ន្ធនេះ គេធ្វើឡើងក្នុងគោលបំណងដើម្បីការពារសិទ្ធិរបស់ភាគីដែលជាសហព័ទ្ធ និងទប់ស្កាត់ជាមុនមិនឱ្យមានការប្រែប្រួលផ្លូវច្បាប់ និងស្ថានភាពជាក់ស្តែង។ កិច្ចសន្យានេះគឺធ្វើឡើងដើម្បីកំណត់ឱ្យបានច្បាស់លាស់អំពីទំនាក់ទំនងទ្រព្យសម្បត្តិប្តីប្រពន្ធ និងចងភ្ជាប់នូវចំណងកាតព្វកិច្ចប្តីប្រពន្ធក្នុងតម្រូវការក្នុងគ្រួសារផងដែរ ព្រមទាំងបង្ការនូវភាពស្មុគស្មាញក្នុងការបែងចែងទ្រព្យសម្បត្តិ ពេលដែលសហព័ទ្ធរំលាយកិច្ចសន្យាអាពាហ៍ពិពាហ៍ផងដែរ។ លើសពីនេះទៅទៀតវាអាចជាកត្តាធ្វើឱ្យទំនាក់ទំនងសហព័ទ្ធមានភាពច្បាស់លាស់ តម្លាភាពលើបញ្ហាទ្រព្យ និងចូលរួមពង្រឹងសមភាពយេនឌ័រក្នុងសង្គមផងដែរ។

### ១.២.១. ការពារផលប្រយោជន៍របស់សហព័ទ្ធ

ការកំណត់នូវទ្រព្យសម្បត្តិរបស់ប្តី ប្រពន្ធតាមកិច្ចសន្យា ជាកត្តាមួយដែលជួយឱ្យសហព័ទ្ធមានភាពងាយស្រួលក្នុងការបែងចែកទ្រព្យសម្បត្តិឱ្យបានត្រឹមត្រូវ និងមានសមភាពក្រោយពេលចំណងអាពាហ៍ពិពាហ៍ត្រូវបានបញ្ចប់។ ជាក់ស្តែងនៅក្នុងករណីដែលសហព័ទ្ធកំណត់ថា ទ្រព្យណាមួយជាទ្រព្យរួម នោះនៅពេលដែលភាគីណាមួយទទួលមរណភាព ទ្រព្យនោះនឹងក្លាយជាទ្រព្យរបស់ភាគីជាសហព័ទ្ធម្ខាងទៀត ក៏ប៉ុន្តែមិនអាចបំពានលើភាគបម្រុងបានទេ។ សហព័ទ្ធរបស់មតកជនត្រូវក្លាយជាសន្តិជនជានិច្ច។

### ១.២.២. កំណត់លើទំនាក់ទំនងកាតព្វកិច្ច និងសិទ្ធិលើបំណុល

ជាគោលការណ៍ចំពោះប្តី ឬប្រពន្ធ មានកាតព្វកិច្ចទំនុកបម្រុងក្នុងជីវភាពប្រចាំថ្ងៃ ចំណូលដែលរកបាន ឬប្រាក់បៀវត្សដែលរកបានត្រូវចាត់ទុកជាទ្រព្យរួម ដែលទំនាក់ទំនងទ្រព្យនេះត្រូវបានកំណត់នៅមុនពេល ឬក្រោយពេលរៀបអាពាហ៍ពីពាហ៍របស់សហព័ទ្ធ តាមរយៈកិច្ចសន្យា។ ដោយឡែកក្នុងកំឡុងពេលនៃអាពាហ៍ពិពាហ៍ដែលប្តីប្រពន្ធបានព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយម្ចាស់បំណុលវាជាការទទួលខុសត្រូវរួមដោយសាមគ្គី។ នៅត្រង់ចំណុចនៃមាត្រានេះ ទាមទារឱ្យមានលក្ខខណ្ឌចាំបាច់នៃលិខិតជាលាយលក្ខណ៍អក្សរ និងការព្រមព្រៀងរវាងប្តីប្រពន្ធទាំងសងខាង ដើម្បីជៀសវាងការដាក់បន្ទុកធ្ងន់ធ្ងរទៅលើភាគីម្ខាងៗ។ ទោះជាយ៉ាងណាក៏ដោយជាគោលការណ៍បន្ទុកនៃកាតព្វកិច្ចត្រូវជាទ្រព្យសម្បត្តិរួម ដូច្នេះហើយសិទ្ធិចំពោះទ្រព្យសម្បត្តិរួមរបស់

សហព័ទ្ធម្ខាងទៀត មិនត្រូវបានការពារទេ នៅក្នុងទំនាក់ទំនងជាមួយតតិយជនដែលសុចរិត ហើយគ្មានកំហុស លើកលែងតែករណីដែលបានធ្វើការចាត់វិធានការរក្សាការពារចំពោះទ្រព្យសកម្ម។

### ១.២.៣. កំណត់ពីសិទ្ធិគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិ

ជាទូទៅកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដើរតួនាទីយ៉ាងសំខាន់នៅក្នុងការកំណត់ យ៉ាងជាក់លាក់អំពីទ្រព្យសម្បត្តិដែលសហព័ទ្ធមាន។ ការបែងចែកឱ្យដាច់ពីគ្នារវាងទ្រព្យរបស់សហព័ទ្ធ ពោលគឺទ្រព្យណាដែលជាទ្រព្យរបស់ប្តី ទ្រព្យណាជារបស់ប្រពន្ធ ហើយទ្រព្យណាជាទ្រព្យរួមដែលសហព័ទ្ធរកបាននៅក្នុងចំណងអាពាហ៍ពិពាហ៍នឹងជាកត្តាមួយយ៉ាងសំខាន់នៅក្នុងការកំណត់អំពីម្ចាស់កម្មសិទ្ធិ នៃទ្រព្យ ហើយតាមរយៈការកំណត់កម្មសិទ្ធិនេះអាចធ្វើឱ្យប្តីប្រពន្ធអាចបែងចែកគ្នាដាច់ចំពោះសិទ្ធិក្នុងការគ្រប់គ្រងចាត់ចែង និងថែរក្សាទ្រព្យដែលអាចបង្ការ ឬធ្វើឱ្យសហព័ទ្ធជៀសផុតបញ្ហាជម្លោះដែលកើតមានឡើងតាមរយៈការប្រើប្រាស់ទ្រព្យ។ ម៉្យាងវិញទៀតសហព័ទ្ធទាំងសងខាងមានសិទ្ធិយ៉ាងពេញលេញក្នុងការប្រើប្រាស់ និងគ្រប់គ្រងលើទ្រព្យទាំងឡាយណាដែលជាទ្រព្យដោយឡែក និងមានសិទ្ធិគ្រប់គ្រងទៅលើទ្រព្យរួមផងដែរ ក៏ប៉ុន្តែក្នុងការចាត់ចែងទ្រព្យរួមគេតម្រូវឱ្យមានការសហការគ្នារវាងសហព័ទ្ធទាំងពីរ លើកលែងតែក្នុងករណីចាំបាច់មួយដែលមានបញ្ញត្តិនៅក្នុងច្បាប់។

### ១.២.៤. សម្រួលនីតិវិធីដោះស្រាយរបស់តុលាការ

ជាការពិតណាស់ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា ដែលបង្កើតឡើងឱ្យមានកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះ មានគោលបំណងអនុញ្ញាតឱ្យសហព័ទ្ធអាចចុះនូវកិច្ចសន្យា ដើម្បីកំណត់ឱ្យបានច្បាស់លាស់អំពីទំនាក់ទំនងទ្រព្យប្តីប្រពន្ធ។ ដូច្នេះដោយសារតែកិច្ចសន្យានេះមានទម្រង់ជាលិខិតលាយលក្ខណ៍អក្សរ ថែមទាំងអាចស្នើសុំចុះបញ្ជីដើម្បីក្លាយជាលិខិតយថាភូតទៀតនោះ ដែលនាំឱ្យប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យានេះមានភាពអំណោយផល ក៏ដូចជាអនុគ្រោះយ៉ាងមានប្រសិទ្ធភាពចំពោះដំណើរការនីតិវិធី ព្រមទាំងជាវត្ថុតាងដល់តុលាការចំពោះការវិនិច្ឆ័យ ដែលក្នុងនោះការសម្រួលជាពិសេសដល់តុលាការនៅក្នុងវិវាទលែងលះ វិវាទផ្នែកមរតក និងវិវាទក្នុងករណីទាមទារឱ្យអនុវត្តកាតព្វកិច្ច។[30]

[30]https://thimhorn.wordpress.com/2017/11/09/%E1%9E%94%E1%9F%92%E1%9E%9A%E1%9E%96%E1%9F%90%E1%9E%93%E1%9F%92%E1%9E%92%E1%9E%91%E1%9F%92%E1%9E%9A%E1%9E%96%E1%9F%92%E1%9E%99%E1%9E%9F%E1%9E%98%E1%9F%92%E1%9E%94%E1%9E%8F%E1%9F%92%E1%9E%8F%E1%9E%B7/

## ផ្នែកទី២ លក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ មានលក្ខណៈពិសេស ពីព្រោះអានុភាពនៃកិច្ចសន្យានេះអាច យកមកតតាំងជាមួយតតិយជនបាន (មាត្រា៩៧០ នៃក្រមរដ្ឋប្បវេណី)។ ដើម្បីឱ្យកិច្ចសន្យាមាន អានុភាពពិសេសនេះ ត្រូវបំពេញតាមលក្ខខណ្ឌដូចតទៅ៖

ក. គូភាគី ត្រូវរៀបអាពាហ៍ពិពាហ៍នឹងគ្នា ឬនឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា(ករណីបានធ្វើកំជាប់ពាក្យជាមួយគ្នា)

ខ. កិច្ចសន្យានេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ

គ. កិច្ចសន្យាត្រូវចុះបញ្ជី។

ប្តីប្រពន្ធអនីតិសង្វាស មិនអាចចុះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដែលមានចែងក្នុងក្រមរដ្ឋប្បវេណីបានទេ ដោយសារតែប្តីប្រពន្ធអនីតិសង្វាស មិនបានបំពេញលក្ខខណ្ឌ ក ឡើយ។ ប្តីប្រពន្ធអនីតិសង្វាសអាចធ្វើកិច្ចសន្យាចំពោះទ្រព្យសម្បត្តិរបស់ពួកគេបាន ប៉ុន្តែកិច្ចសន្យានេះមិន មែនជាកិច្ចសន្យាដែលមានចែងក្នុងក្រមរដ្ឋប្បវេណីឡើយ។ ពួកគេអាចចុះបញ្ជីទ្រព្យសម្បត្តិនេះ នៅសារការីអាស្រ័យលើខ្លឹមសារជាលក្ខណៈឯកជន (មាត្រា ៩៧៣ នៃក្រមរដ្ឋប្បណី)។[31]

កិច្ចសន្យាទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធត្រូវធ្វើឡើង ដើម្បីទប់ស្កាត់វិវាទលើទំនាក់ទំនងទ្រព្យសម្បត្តិ និង ដើម្បីបញ្ជាក់ឱ្យច្បាស់អំពីទំនាក់ទំនងសិទ្ធិ និង ករណីកិច្ចរបស់ប្តីប្រពន្ធ។ ទំនាក់ទំនងជាក់ស្តែងរវាងប្តីប្រពន្ធមានលក្ខណៈច្រើនបែបច្រើនយ៉ាង ហើយបញ្ញត្តិនៃមាត្រា ៩៦៩ នេះផ្តល់លទ្ធភាពឱ្យប្តីប្រពន្ធនូវជម្រើសដែលមានលក្ខណៈបត់បែនសមស្របទៅតាមភាពចាំបាច់របស់ប្តីប្រពន្ធជាក់លាក់។ កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះ ក៏មានអានុភាពសម្រួលដល់ការពិភាក្សាអំពីអនាគតរបស់ប្តីប្រពន្ធផងដែរ។

មានបញ្ហាថា តើគួរទទួលស្គាល់នូវសេរីភាពក្នុងការធ្វើកិច្ចសន្យាទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធត្រឹមកម្រិតណា។ មានន័យថា ផ្តើមចេញពីការពិចារណាលើភាពខុសគ្នានៃសមត្ថភាពចរចា និងទំនាក់ទំនងអំណាចរវាងប្តីប្រពន្ធ តើត្រូវធានាភាពយុត្តិធម៌ក្នុងខ្លឹមសារនៃកិច្ចសន្យាយ៉ាងដូចម្តេច ហើយថា តើត្រូវទទួលស្គាល់អានុភាពនៃកិច្ចសន្យាត្រឹមកម្រិតណា ចំពោះទំនាក់ទំនងនៃសុវត្ថិភាពនៃការជួញដូរ និងទំនាក់ទំនងជាមួយតតិយជន។ ប្រទេសជប៉ុន ជាគោលការណ៍ ប្តីប្រពន្ធអាចធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធបានដោយសេរី លុះត្រាតែកិច្ចសន្យានោះមិនផ្ទុយនឹង សណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ បញ្ញត្តិដែលត្រូវអនុវត្តដាច់ខាត ។ នៅប្រទេសបារាំង ខណៈដែលគូភាគីមានសិទ្ធិកំណត់ដោយសេរីនូវខ្លឹមសារ នៃកិច្ចសន្យាស្តីពីប្រព័ន្ធទ្រព្យសម្បត្តិ

[31] សេចក្តីពន្យល់អំពី ក្រមរដ្ឋប្បវេណី, ភាគ៣, ទំព័រ៣២។

របស់ប្តីប្រពន្ធ ក៏ប៉ុន្តែ ដើម្បីភាពងាយស្រួលរបស់ភាគី ទម្រង់កិច្ចសន្យាគំរូដែលភាគីអាចជ្រើសរើសប្រើបានត្រូវបានកំណត់ឡើង ដូចជាទម្រង់កិច្ចសន្យាគំរូ ចំពោះប្រព័ន្ធទ្រព្យសម្បត្តិដោយឡែក ប្រព័ន្ធបញ្ចូលប្រាក់ចំណូលទៅក្នុងទ្រព្យសម្បត្តិរួម និង ប្រព័ន្ធកម្មសិទ្ធិរួមដែលកំណត់ដោយច្បាប់ ដែលមានការកែប្រែខ្លួនខ្លះៗជាអាទិ៍។ ប្រទេសស្វីស អាល្លឺម៉ង់ និង អ៊ីតាលី ធ្វើការកម្រិតចំពោះទម្រង់កិច្ចសន្យាគំរូដែលអាចជ្រើសរើសបានក្នុងចំណោមប្រព័ន្ធទ្រព្យសម្បត្តិដោយឡែក ប្រព័ន្ធទ្រព្យសម្បត្តិរួម និង ប្រព័ន្ធដែលកែសម្រួលចំណុចខ្លះនៃប្រព័ន្ធទ្រព្យសម្បត្តិរួម ។

ចំពោះខ្លឹមសារវិញ ច្បាប់ប្រទេសបារាំង និង រដ្ឋល្វីស៊ៀនណា (Louisiana) របស់សហរដ្ឋអាមេរិក ចែងថា កិច្ចសន្យាប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ មិនត្រូវផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ហើយមិនត្រូវផ្ទុយនឹងបញ្ញត្តិស្តីពីសិទ្ធិ និង ករណីយកិច្ចដែលកើតចេញពីអាពាហ៍ពិពាហ៍ អំណាចមេបា អាណាព្យាបាល និង ការហាមឃាត់ការផ្លាស់ប្តូរលំដាប់នៃសន្តតិកម្មដែលកំណត់ដោយច្បាប់ឡើយ រីឯប្រទេសស្វីស ក៏ធ្វើការហាមឃាត់ ការតាក់តែងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដែលបំពានលើបញ្ញត្តិដែលពាក់ព័ន្ធនឹងការការពារម្ចាស់បំណុល និង ភាគបម្រុងដែរ ។ ប្រទេសជាច្រើនមិនទទួលស្គាល់កិច្ចសន្យាណាដែលលះបង់ ឬកម្រិតសិទ្ធិជាមូលដ្ឋាន ដូចជាការថែរក្សាជីវភាពគ្រួសារ ភាពស្មើគ្នា និង ឯករាជ្យភាពរបស់ប្តីប្រពន្ធ ជាដើម ។ ដូច្នេះ មាត្រានេះក៏ទទួលស្គាល់សេរីភាពរបស់ប្តីប្រពន្ធក្នុងការធ្វើ កិច្ចសន្យាប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ ប៉ុន្តែ ទន្ទឹមគ្នានេះបានដកកម្រិតមួយចំនួនលើសេរីភាពក្នុងការធ្វើកិច្ចសន្យា ដូចជា ការលះបង់សិទ្ធិលើអាហារកាតព្វកិច្ច សិទ្ធិលើទ្រព្យសម្បត្តិរវាងប្តីប្រពន្ធ និង ការលះបង់សិទ្ធិពាក់ព័ន្ធនឹងសន្តតិកម្មដូចជា ភាគបម្រុងដែលកំណត់ដោយច្បាប់ជាដើម ។[32]

## ២.១. លក្ខខណ្ឌគ្រឹះនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

នៅក្នុងសង្គមខ្មែរជីវិតអាពាហ៍ពិពាហ៍រវាងប្តីប្រពន្ធ ជារឿងសំខាន់សម្រាប់ដៃគូត្រូវរួមរស់នៅជាមួយគ្នានៅក្នុងករណី ដែលអាពាហ៍ពិពាហ៍នោះមិនសមប្រកបមានការរកាំរកុះទំនាស់មិនចុះសម្រុងនិងគ្នាអាចឈានដល់ ការលែងលះនិងឈានដល់ការបែងចែកទ្រព្យសម្បត្តិគ្នា។ ដូចន្នេះហើយសហព័ទ្ធត្រូវតែបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយការព្រមព្រៀងនិងការបង្ហាញឆន្ទៈពិតប្រាកដដោយគ្មានវិការៈ និងមានសមត្ថភាពក្នុងការបង្កើតកិច្ចសន្យាមួយនេះ។ ក្នុងករណី ដែលប្តីប្រពន្ធមិនបានធ្វើកិច្ចសន្យាទ្រព្យសម្បត្តិទេ ការបែងចែកទ្រព្យសម្បត្តិនៅពេលដែលមានការលែងលះ គឺអនុវត្តទៅតាមច្បាប់ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីខ្មែរយើង។

[32] សេចក្តីកំណត់ ក្រមរដ្ឋប្បវេណី ភាគ៥ គន្លឹះទី៧ នៃមាត្រា ៩៦៩។

កម្មវត្ថុនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះ គឺមិនត្រូវមានភាពផ្ទុយពីច្បាប់ឡើយហើយត្រូវកំណត់ឱ្យបានច្បាស់លាស់នៅក្នុងកិច្ចសន្យាថាអ្នកណាជាកម្មសិទ្ធិករលើទ្រព្យមួយណានិងជាកម្មសិទ្ធិអវិភាគរបស់ប្តីប្រពន្ធ។

ជាគោលការណ៍ ដើម្បីអាចជ្រើសរើសប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា សហព័ទ្ធត្រូវធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។ មួយវិញទៀត កិច្ចសន្យាត្រូវធ្វើ ជាលាយលក្ខណ៍អក្សរនៅមុន ឬក្រោយពេលរៀបអាពាហ៍ពិពាហ៍។ ជាពិសេសទៅទៀត កិច្ចសន្យានេះត្រូវតែចុះបញ្ជី ដើម្បីអាចយកមក តតាំង នឹងតតិយជនបាន។ ម្យ៉ាងវិញទៀត ការចុះបញ្ជីនេះត្រូវធ្វើនៅនាយកដ្ឋានកិច្ចការរដ្ឋប្បវេណីក្រសួងយុត្តិធម៌ តាមពាក្យសុំចុះបញ្ជីរបស់ប្តីប្រពន្ធ ឬ បុគ្គលដែលនឹងរៀបការជាមួយគ្នា ដោយផ្អែកតាមបទប្បញ្ញត្តិនៃមាត្រា ២៦ និង មាត្រា ២៨ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី និង ប្រកាសរបស់ក្រសួងយុត្តិធម៌ស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។ យ៉ាងណាមិញ ពាក្យថា "លក្ខខណ្ឌតតាំង" គឺចង់សំដៅទៅលើលក្ខខណ្ឌដែលត្រូវបំពេញ ដើម្បីឱ្យមានអានុភាពទៅលើតតិយជន ក្រៅពីគូភាគី ដូច្នេះ កង្វះលក្ខខណ្ឌតតាំង នឹងនាំឱ្យតតិយជនអាចជំទាស់ចំពោះអានុភាពនៃកិច្ចសន្យា ចំពោះរូបគាត់បាន។

ឧទាហរណ៍៖ លោក សំភី និង លោកស្រី រ៉ាវី បានធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដែលមានខ្លឹមសារយ៉ាងច្បាស់ថា ទ្រព្យសម្បត្តិទាំងអស់ដែលរកបានក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ដោយសហព័ទ្ធម្នាក់ៗ គឺជាទ្រព្យសម្បត្តិដោយឡែករបស់សហពទ្ធម្នាក់ៗ។ ក៏ប៉ុន្តែ អ្នកទាំងពីរមិនបានយកកិច្ចសន្យានេះ ទៅចុះបញ្ជីទេ ដែលជាហេតុធ្វើឱ្យកិច្ចសន្យានេះមិនមានអានុភាពចំពោះតតិយជនឡើយ ។ ឧបមាថា ក្រោយពីរៀបការរួច លោកស្រី រ៉ាវី បានខ្ចីប្រាក់លោកស្រី ធីតា ចំនួន ២០០០ ដុល្លារ ដើម្បីយកទៅដោះស្រាយបំណុលរបស់ម្តាយនាង ដោយមិនឱ្យលោក សំភី ដឹងឡើយ។ ក្រោយមក លោកស្រី ធីតា បានទាមទារឱ្យមានការរឹបអូសរថយន្តមួយគ្រឿងដែលលោក សំភី បានទិញនៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ជាមួយនឹងលោកស្រី រ៉ាវី ក្នុងករណីបែបនេះ លោក សំភី ប្រាកដជាលើកសំអាងពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធរវាងគាត់ និង លោកស្រី រ៉ាវី ដើម្បីបញ្ជាក់ថា រថយន្តមួយគ្រឿងនេះ គឺជាទ្រព្យសម្បត្តិដោយឡែករបស់ គាត់ មិនមែនជាទ្រព្យសម្បត្តិរួមរវាងគាត់ និងលោកស្រី រ៉ាវី ទេ។ ក៏ប៉ុន្តែ ទោះជាយ៉ាងនេះក្តី ដោយហេតុថា កិច្ចសន្យាទ្រព្យសម្បត្តិមិនត្រូវបានយកទៅចុះបញ្ជីនៅ ក្រសួងយុត្តិធម៌ នាំឱ្យកិច្ចសន្យានេះមិនអាចយកទៅតតាំងជាមួយនឹងលោកស្រី ធីតា បានទេ ពោលគឺ រថយន្តនេះនឹងត្រូវចាត់ទុកថាជាទ្រព្យសម្បត្តិរួមរវាងលោក សំភី និងលោកស្រី រ៉ាវី ហើយចំណែកដែលជាកម្មសិទ្ធិរបស់លោកស្រី រ៉ាវី (ថ្លៃពាក់កណ្តាលនៃរថយន្ត) អាចនឹងត្រូវរឹបអូស ដើម្បីលក់យកប្រាក់មកសងបំណុលរបស់លោកស្រី ធីតា បាន។ ជាក់ស្តែង កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធអាចមានខ្លឹមសារ ទៅតាមការព្រមព្រៀងរវាងគូភាគី។

ឧទាហរណ៍៖

- ទ្រព្យសម្បត្តិដែលគូភាគីមានមុនពេលរៀបការ ក៏ដូចជាទ្រព្យសម្បត្តិ ដែលទទួលបាននៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ទោះដោយសារមូលហេតុអ្វីក៏ដោយ ត្រូវចាត់ទុកជាទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធ។
- ទ្រព្យសម្បត្តិដែលគូភាគីមានមុនពេលរៀបការ ក៏ដូចជាទ្រព្យសម្បត្តិដែលគូភាគីរកបានក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ត្រូវចាត់ទុកជា ទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធរៀងៗខ្លួន។

ក៏ប៉ុន្តែ ទោះបីជាយ៉ាងណាក្តី ខ្លឹមសារនេះមិនត្រូវផ្ទុយនឹងបញ្ញត្តិស្តីពីសិទ្ធិ ទាមទារអាហារកាតព្វកិច្ច (ពោលគឺ កាតព្វកិច្ចផ្គត់ផ្គង់អាហារដល់ញាតិដែល កំណត់ដោយច្បាប់) ឬ ភាគបម្រុងឡើយ។

ឧទាហរណ៍៖ លោក ដាវណ្ណ មានករណីយកិច្ចនូវផ្គត់ផ្គង់អាហារកាតព្វកិច្ចដល់ឳពុកជរារបស់គាត់នូវទឹកប្រាក់ចំនួន ១០០ ដុល្លារ ក្នុងមួយខែ។ ក្រោយពីបានរៀបការរួច លោក ដាវណ្ណ បានធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្រពន្ធ ជាមួយនឹងលោកស្រី ដានី ដែលមានខ្លឹមសារថា រាល់ចំណាយដែលមានទឹកប្រាក់ចាប់ពី ៥0 ដុល្លារឡើងទៅ ត្រូវតែមានការព្រមព្រៀងពីសហព័ទ្ធទាំងសងខាង។ ខ្លឹមសារបែបនេះ គឺប៉ះពាល់ដល់សិទ្ធិរបស់ឳពុកលោក ដាវណ្ណ។ ម្យ៉ាងទៀត កិច្ចសន្យាទ្រព្យសម្បត្តិប្រពន្ធ ត្រង់ចំណុចនេះ មិនត្រូវមានអានុភាពហាមឃាត់លោក ដាវណ្ណ មិនឱ្យបង់ប្រាក់ចំនួន ១០០ ដុល្លារឱ្យឳពុកគាត់ឡើយ។

ឧទាហរណ៍ ៖ លោក សំខាន់ បានធ្វើកិច្ចសន្យាប្តីប្រពន្ធជាមួយ នឹងភរិយារបស់គាត់ឈ្មោះ ចិន្តា ដែលមានខ្លឹមសារដូចតទៅ ៖ នៅពេលដែលសហព័ទ្ធ ណាម្នាក់ស្លាប់បាត់បង់ជីវិតមុនសហព័ទ្ធដែលនៅរស់មានសិទ្ធិទទួលបានទ្រព្យសម្បត្តិទាំងអស់របស់សហព័ទ្ធដែលបានស្លាប់បាត់បងជីវិត។

ឧបមាថា លោក សំខាន់ មានកូនចំនួន ២ នាក់ មុនពេលដែលគាត់មក រៀបការជាមួយនិង លោកស្រី ចិន្តា ហើយឥឡូវនេះ លោក សំខាន់ ក៏បានស្លាប់ បាត់បង់ជីវិត។ រួមសេចក្តីមក បើសិនជាត្រូវអនុវត្តតាមកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ទ្រព្យសម្បត្តិទាំងអស់របស់លោក សំខាន់ ត្រូវផ្ទេរទៅឱ្យលោកស្រី ចិន្តា នៅពេលនោះ គឺកូនទាំងពីរនាក់របស់លោក សំខាន់ មិនអាចទទួលបានអ្វីទាំងអស់។ ត្រង់ចំណុចនេះ គឺផ្ទុយទាំងស្រុងទៅនឹងបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីទាក់ទងនឹងភាគបម្រុង។ ដូចនេះ ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធខាងលើ គឺ មិនអាចនឹងធ្វើឱ្យប៉ះពាល់ដល់ សិទ្ធិទាមទារភាគបម្រុងនកូនទាំងពីររបស់លោក សំខាន់បានឡើយ។ មួយវិញទៀត ទោះបីជាមានកិច្ចសន្យាបែបនេះ ក៏ដោយ ក៏កូនទាំងពីរនាក់របស់លោក សំខាន់ នៅតែអាច

ទាមទារឱ្យគោរពសិទ្ធិលើភាគបម្រុងរបស់ពួកគេបានដដែល ពោលគឺ ទ្រព្យសម្បត្តិមួយភាគដែលជាមរតករបស់លោក សំខាន់ នឹងត្រូវប្រគល់ឱ្យទៅកូនទាំងពីរនាក់របស់លោក សំខាន់ តាមការទាមទារ។[33]

### ២.១.១. ការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

គោលគំនិតនៃការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ព្រោះអាពាហ៍ពិពាហ៍រវាងប្តីប្រពន្ធនឹងបង្កើតជាចំណងគតិយុត្តដែលបង្កើតបាននូវ ឥណទេយ្យ និងបំណុលរវាងសហព័ទ្ធ។ ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យាគេធ្វើឡើងដោយ គោរពតាមឆន្ទៈព្រមព្រៀងរបស់សហព័ទ្ធ ប៉ុន្តែការព្រមព្រៀងនេះមិនអាចធ្វើផ្ទុយទៅនឹងសណ្តាប់ធ្នាប់សាធារណៈ ឬផ្ទុយពីអ្វីដែលច្បាប់បានកំណត់ទេ។ ការធ្វើនេះ គេធ្វើឡើងក្នុងគោលបំណងការពារសិទ្ធិ និងផលប្រយោជន៍របស់ភាគីសហព័ទ្ធ និងទប់ស្កាត់ការប្រែប្រួលផ្លូវច្បាប់ និងស្ថានភាពជាក់ស្តែង។ កិច្ចសន្យានេះធ្វើឡើង ដើម្បីកំណត់ឱ្យបានច្បាស់លាស់អំពីទំនាក់ទំនងទ្រព្យសម្បត្តិប្តីប្រពន្ធ ព្រមទាំងកាតព្វកិច្ចនៅក្នុងគ្រួសារ និងបង្ការភាពស្មុកស្មាញការបែងចែងទ្រព្យសម្បត្តិ នៅពេលដែលមានរំលាយចំណងអាពាហ៍ពិពាហ៍ផងដែរ។

កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ក៏ដូចជាកិច្ចសន្យាផ្សេងទៀតដែរគឺត្រូវធ្វើដោយគោរពតាមលក្ខខណ្ឌសំខាន់ៗនៃកិច្ចសន្យាគឺ សមត្ថភាព ការបង្ហាញឆន្ទៈដោយសេរី និងពិតប្រាដក។ កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធគឺត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងចុះបញ្ជីនៅក្រសួងយុត្តិធម៌។

### ២.១.២. ការព្រមព្រៀងក្នុងការបង្ហាញឆន្ទៈ

ក្នុងការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ការបង្ហាញឆន្ទៈព្រមព្រៀងរវាងសហព័ទ្ធគឺជារឿងសំខាន់ដោយការព្រមព្រៀងនេះចេញពីការបង្ហាញឆន្ទៈពិតប្រាកដ និងគ្មានវិការៈ។ ការព្រមព្រៀងចេញពីឆន្ទៈពិតប្រាកដគឺមានន័យថាសហព័ទ្ធសុទ្ធតែបានដឹងច្បាស់អំពីខ្លឹមសារនៃកិច្ចសន្យានេះ និង បានដឹងអំពីលទ្ធផលផ្លូវច្បាប់ដែលបានព្រមព្រៀង។ រីឯការព្រមព្រៀងវិញ គឺកើតចេញពីឆន្ទៈពិតប្រាកដ គ្មានការភាន់ច្រឡំ ឆបោក គ្មានការបង្ហាញព័ត៌មានមិនពិត ឬរំលោភលើស្ថានភាព និងគ្មានការគំរាមកំហែង។

### ២.១.៣. សមត្ថភាពរបស់ភាគី(សហព័ទ្ធ)

ប្តីប្រពន្ធ គឺជាភាគីក្នុងការចុះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដែលសហព័ទ្ធទាំងពីរមានសមត្ថភាពផ្លូវច្បាប់គ្រប់គ្រាន់ក្នុងការចុះកិច្ចសន្យាទ្រព្យសម្បត្តិ។ សមត្ថភាពតាមផ្លូវច្បាប់ គឺជាសមត្ថភាពដែលអាចបំពេញភាពត្រឹមត្រូវតាមផ្លូវច្បាប់ ជារួមជាសមត្ថភាពដែលអាចមានលទ្ធភាពធ្វើសកម្មភាពអ្វីមួយបាន ដោយបញ្ញាស្មារតីគ្រប់គ្រាន់ដឹងខុសត្រូវ និងមិនខុសច្បាប់។ ហើយសមត្ថភាពនេះ យើងអាចសង្កេតមើលទៅលើបញ្ហាអាយុ

[33] នីតិព្រហ្មទណ្ឌ និង គ្រួសា, ២០១៧, ទំព័រទី៣៤៩ដល់៣៥២, រុន ពណ្ណារឹទ្ធ, ចាំង ស៊ីណាត។

និងបញ្ហាវិបត្តិស្មារតីរបស់សហព័ទ្ធ។ ចំពោះបញ្ហាអាយុ សហព័ទ្ធទាំងពីរត្រូវតែមានសមត្ថភាពខាងឆន្ទៈ បាន ន័យថា ជាសកម្មភាពដែលភាគីបានធ្វើនៅក្នុងស្ថានភាពដែលខ្លួនមិនអាចយល់ដឹង និង វិនិច្ឆ័យបាន អំពីលទ្ធ ផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន អាចលុបចោលបាន[34]។ ភាគី ឬសហព័ទ្ធទាំងពីរត្រូវតែជាបុគ្គលដែល មានសមត្ថភាពពេញលេញ ដែលមិនមែនជាអនីតិជន ឬជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ឬជាជន ដែលស្ថិតនៅក្រោមហិតូបត្ថម្ភទេ។ អនីតិជន គឺសំដៅទៅលើជនដែលមានអាយុក្រោម ១៨ ឆ្នាំ។ រីឯបញ្ហាវិបត្តិ ស្មារតីវិញ ចង់សំដៅទៅលើជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ឬជនស្ថិតនៅក្រោមហិតូបត្ថម្ភ។ ជន ដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ គឺសំដៅទៅដល់ជនដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យ ពីស្ថានភាពនៃការធ្វើសកម្មភាពរបស់ខ្លួន អំពីលទ្ធផលតាមផ្លូវច្បាប់ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ស្ថិត នៅក្នុងស្ថានភាពជានិរន្តរ៍[35] ហើយរាល់សកម្មភាពរបស់បុគ្គលប្រភេទនេះត្រូវបានលុបចោល បើគ្មានការយល់ ព្រមពីអ្នកអាណាព្យាបាលទូទៅ។ ចំពោះជនស្ថិតនៅក្រោមហិតូបត្ថម្ភ គឺជាជនដែលមានសមត្ថិភាពតិចតួចក្នុង ការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិបញ្ញាស្មារតី[36] តែ មិនជានិរន្តរ៍នោះទេ រាល់សកម្មភាពរបស់បុគ្គលប្រភេទនេះត្រូវបានលុបចោល បើគ្មានការយល់ព្រមពី ហិតូបត្ថម្ភកៈ លើកលែងតែសកម្មភាពមួយចំនួនដែលច្បាប់អនុញ្ញាតិ ដោយមិនចាំបាច់មានការយល់ព្រមពីហិ តូបត្ថម្ភកៈនោះទេ ដែលសកម្មភាពទាំងនោះមានចែងនៅក្នុងមាត្រា ៣០ នៃក្រមរដ្ឋប្បវេណី។

**២.១.៤. កម្មវត្ថុ**

កម្មវត្ថុនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ជាទូទៅអចលវត្ថុ ឬចលនវត្ថុ បានក្លាយជាកម្មវត្ថុដ៏ពេញនិយម នៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ពីព្រោះថា វត្ថុទាំងពីរនេះមានរូបរាងច្បាស់លាស់ និងទទួលបានការទទួល ស្គាល់ច្រើនពីសំណាក់ពលរដ្ឋដែលចូលចិត្តបង្កើតកិច្ចសន្យាផ្សេងៗ ដោយវាមានភាពងាយស្រួលក្នុងការរក្សា ទុក និងការពារ ជាងវត្ថុផ្សេងទៀត។ ប៉ុន្តែមុននឹងយកមកធ្វើជាកម្មវត្ថុនៃកិច្ចសន្យា ភាគីត្រូវដឹងពីសាវតានៃវត្ថុជា មុនសិន ព្រោះវត្ថុនៃកិច្ចសន្យាអាចនឹងក្លាយជាប្រាតិភោគនៃបំណុល ឬទ្រព្យដែលជាប់បំណុល មុននឹងក្លាយជា កម្មវត្ថុនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ។ ហេតុនេះប្ដីប្រពន្ធ គួរតែសិក្សាពីសាវតានៃកម្មវត្ថុ ឬធ្វើការព្រមព្រៀងគ្នា ឱ្យបានល្អិតល្អន់លើបញ្ហានេះ ជៀសវាងនឹងមានវិវាទនៅពេលក្រោយ។

[34] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១៤។

[35] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ២៤។

[36] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ២៨។

## ២.២. លក្ខខណ្ឌទម្រង់នៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

កិច្ចសន្យាគ្រប់គ្រងទ្រព្យសម្បត្តិប្ដីប្រពន្ធ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។ កិច្ចសន្យាធ្វើឡើងដោយផ្ទាល់មាត់គ្មានអានុភាពឡើយ ដែលជាហេតុនាំឱ្យរបបនៃការគ្រប់គ្រងទ្រព្យសម្បត្តិតាមច្បាប់ នឹងចូលខ្លួនអត្តាគមន៍ដោះស្រាយបញ្ហាជុំវិញការគ្រប់គ្រងទ្រព្យសម្បត្តិ។ ម្យ៉ាងវិញទៀត កិច្ចសន្យាគ្រប់គ្រងទ្រព្យសម្បត្តិប្ដីប្រពន្ធនេះ និងមានអានុភាពតតាំងជាមួយតតិយជនបាន លុះត្រាតែមានការចុះបញ្ជី ព្រោះបើគ្រាន់តែមានត្រឹមតែកិច្ចសន្យាប្ដីប្រពន្ធនេះ គឺមិនមានភាពគ្រប់គ្រាន់ឡើយ។ ដូច្នេះហើយក្រៅពីលក្ខខណ្ឌ ដែលបានតម្រូវជាលាយលក្ខណ៍អក្សរហើយ សហព័ទ្ធត្រូវបំពេញលក្ខខណ្ឌចុះបញ្ជីនៅក្រសួងយុត្តិធម៌។ ហើយកិច្ចសន្យាប្ដីប្រពន្ធមានអានុភាពបាន លុះត្រាតែអាពាហ៍ពិពាហ៍នោះមានការចុះបញ្ជីត្រឹមត្រូវតាមផ្លូវច្បាប់ (បានចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នា)។ បានន័យថាបន្ទាប់ពីរ សហព័ទ្ធបានបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធរួច អ្នកទាំងពីរដែលជាប្ដីប្រពន្ធនឹងគ្នាត្រូវយកកិច្ចសន្យានោះ ទៅចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធដោយផ្ទាល់យោងតាមប្រកាសស្ដីពី និតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ។

### ២.២.១. ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

ក្រមរដ្ឋប្បវេណីថ្មី បានអនុញ្ញាតឱ្យភាគីត្រូវចុះកិច្ចសន្យាទ្រព្យសម្បត្តិក្នុងករណីដែលភាគីមានបំណងដើម្បីកំណត់អំពី ទំនាក់ទំនងសិទ្ធិ និងកាតព្វកិច្ចរបស់ប្ដីប្រពន្ធលើទ្រព្យសម្បត្តិ ឬ ការតតាំងចំពោះតតិយជនដែលមានការពាក់ព័ន្ធណាមួយលើទ្រព្យសម្បត្តិរបស់សហព័ទ្ធ។[37] នៅក្នុងច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណីបានអនុញ្ញាត ឱ្យអនាគតប្ដីប្រពន្ធ អាចចុះកិច្ចសន្យាទ្រព្យសម្បត្តិមុនពេលរៀប អាពាហ៍ពិពាហ៍ក៏បាន ឬប្ដីប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នារួចហើយ ចុះកិច្ចសន្យាលើទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ។ បន្ថែមលើនេះទៀត ច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី ក៏អនុញ្ញាតឱ្យអ្នកដែលគ្រោងនឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា អាចនឹងចុះកិច្ចសន្យាលើទ្រព្យសម្បត្តិជាមុន មុននឹងពួកគេឈានទៅរក ការរៀបអាពាហ៍ពិពាហ៍។ ការធ្វើបែបនេះអ្នកដែលមានបំណងនឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា អាចចុះកិច្ចសន្យាលើទ្រព្យសម្បត្តិជាមុន បើភាគីទាំងពីរឯកភាពគ្នាលើទ្រព្យសម្បត្តិហើយ ទើបពួកគេអាចរៀបអាពាហ៍ពិពាហ៍ជាក្រោយ។

ការចុះកិច្ចសន្យាលើទ្រព្យសម្បត្តិប្ដីប្រពន្ធ ឬអ្នកដែលគ្រោងនឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវធ្វើឡើងដោយរួមគ្នា និង តាមរយៈពាក្យសុំរបស់ភាគីទាំងពីរ។ កិច្ចសន្យានេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវធ្វើនៅក្រសួងយុត្តិធម៌។ ការចុះកិច្ចសន្យាលើទ្រព្យសម្បត្តិប្ដីប្រពន្ធ ឬអ្នកដែលគ្រោង នឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានេះ ជារឿងមួយថ្មីសម្រាប់កម្ពុជា ដែលពីមុនមកមិនធ្លាប់មានឡើយ។ ប៉ុន្តែមានករណីស្រដៀងគ្នានេះដែរ គឺប្រជាជនកម្ពុជាខ្លះមុនចូលកាន់មុខដំណែង ឬចេញពីមុខដំណែង ត្រូវបានច្បាប់ស្ដីពីការប្រឆាំងអំពើពុក

[37] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧,មាត្រា ៩៦៩ មាត្រា ៩៧០។

រលួយតម្រូវឱ្យធ្វើ ការប្រកាសទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធផងដែរ ដែលមានដូចជា សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា សមាជិករាជរដ្ឋាភិបាល មន្ត្រីរាជការសាធារណៈដែលមានអាណត្តិជ្រើសតាំង សមាជិកក្រុម ប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ប្រធាន អនុប្រធាន និងមន្ត្រីទាំងអស់នៃអង្គភាពប្រឆាំងអំពើពុករលួយ មន្ត្រីរាជការស៊ីវិល នគរបាលយោធា និងអ្នករាជការសាធារណៈផ្សេងទៀតដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ចៅក្រមអាសនៈ ចៅក្រម អយ្យការ ក្រឡាបញ្ជី សារការី អាជ្ញាសាលា ថ្នាក់ដឹកនាំសង្គមស៊ីវិល...។[38]

ជាការពិត នីតិវិធីនៃការចុះកិច្ចសន្យាលើទ្រព្យសម្បត្តិ គឺមានភាពងាយស្រួលសម្រាប់បែងចែកទ្រព្យសម្បត្តិនៅក្រោយពេលលែងលះគ្នា។ ក៏ប៉ុន្តែ តើនៅពេលទៅស្តីដណ្តឹងកូនស្រីរបស់គ្រួសារណាមួយ តើយើងមានសេចក្តីក្លាហានក្នុងការសាកសួរកូនគេថា តើអ្នកមានទ្រព្យសម្បត្តិប៉ុន្មាន ឬឪពុកម្តាយបែងចែកទ្រព្យសម្បត្តិឱ្យកូនរបស់អ្នកដែរឬទេ? នៅក្នុងប្រទេសមួយចំនួន ក៏មានច្បាប់ស្តីពីកិច្ចសន្យាទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធផងដែរ ក្នុងក្រមរដ្ឋប្បវេណីជប៉ុន ក៏មានបញ្ញត្តិស្តីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ចាប់ពីមាត្រា ៧៥៥ ដល់មាត្រា ៧៥៩ ច្បាប់របស់ប្រទេសបារាំង និងរដ្ឋល្វីស៊ៀណា (Louisiana) របស់សហរដ្ឋអាមេរិកចែងថា កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ មិនត្រូវផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ ហើយមិនត្រូវផ្ទុយនឹងបញ្ញត្តិស្តីពីសិទ្ធិ និងករណីយកិច្ចដែលកើតចេញពីអាពាហ៍ពិពាហ៍ អំណាចមេបា អាណាព្យាបាល និងការហាមឃាត់ការផ្លាស់ប្តូរសន្តតិកម្ម ដែលកំណត់ដោយច្បាប់ឡើយ។

ក្រមរដ្ឋប្បវេណីថ្មីឆ្នាំ២០០៧ បានទទួលស្គាល់សេរីភាពប្តី ប្រពន្ធក្នុងការធ្វើកិច្ចសន្យាប្រពន្ធទ្រព្យសម្បត្តិប្តីប្រពន្ធទៅតាមឆន្ទៈ ដែលចង់បាន ប៉ុន្តែទន្ទឹមគ្នានេះ បានដាក់កម្រិតមួយចំនួនលើសេរីភាពក្នុងការធ្វើកិច្ចសន្យាលើទ្រព្យសម្បត្តិរវាងប្តីប្រពន្ធនេះ ដូចជា ការលះបង់សិទ្ធិលើអាហារកាតព្វកិច្ច សិទ្ធិលើទ្រព្យសម្បត្តិរវាងប្តីប្រពន្ធ និងការលះបង់សិទ្ធិពាក់ព័ន្ធនឹងសន្តតិកម្ម ដូចជាភាគបម្រុង ដែលកំណត់ដោយច្បាប់ជាដើម។[39]

ទោះបីជាក្រមរដ្ឋប្បវេណីថ្មី បានផ្តល់អំណាចដល់ភាគី អាចចុះកិច្ចព្រមព្រៀងលើការគ្រប់គ្រង ឬបែងចែកទ្រព្យសម្បត្តិ នៅមុននិងក្រោយរៀបអាពាហ៍ពិពាហ៍ក៏ដោយ ប៉ុន្តែនៅមិនទាន់មានគ្រួសារខ្មែរណាម្នាក់បានទៅចុះកិច្ចសន្យានេះនៅឡើយទេ បើតាមការអះអាងរបស់មន្ត្រីដែលមានសមត្ថកិច្ចក្នុងការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ នៅនាយកដ្ឋានកិច្ចការច្បាប់រដ្ឋប្បវេណី និងអន្តរវិស័យនៃក្រសួងយុត្តិធម៌ នៅត្រឹមថ្ងៃទី២ ខែសីហា ឆ្នាំ២០២៣។[40]

---

38 ច្បាប់ស្តីពី ការប្រឆាំងអំពើពុករលួយ, មាត្រា ១៧។

39 នីតិគ្រួសា និង អាពាហ៍ពិពាហ៍, ភាគ១, បោះពុម្ពលើកទី២ ឆ្នាំ២០២១, ទំព័រទី១៥៧ដល់១៦០, ឥន យឿន។

40 យោងតាមការចុះស្រាវជ្រាវឯកសារ, នាយកដ្ឋានកិច្ចការច្បាប់រដ្ឋប្បវេណី និងអន្តរវិស័យនៃក្រសួងយុត្តិធម៌, នៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៣។

### ក. ប្រព័ន្ធនៃកាចុះបញ្ជីអចលនវត្ថុនៅកម្ពុជា

ប្រព័ន្ធនៃប្រទេសកម្ពុជាមានភាពខុសគ្នាទៅនឹងច្បាប់នៅប្រទេសជប៉ុនយ៉ាងខ្លាំង ត្រង់ចំណុចស្តីអំពី (១)កម្មវត្ថុនៃការចុះបញ្ជី (២)អានុភាពនៃការចុះបញ្ជី (៣)ឯកសារបញ្ជាក់អំពីមូលហេតុនៃការចុះបញ្ជី (៤)សមត្ថកិច្ចនៃការចុះបញ្ជី។ ជាដំបូង ស្តីអំពីចំណុច (១) កម្មវត្ថុនៃការចុះបញ្ជី។ នៅប្រទេសកម្ពុជា ដី និងអាគារមិនមែនជាវត្ថុផ្សេងៗពីគ្នាឡើយ ហើយគេបានចុះបញ្ជីកម្មសិទ្ធិនៃអាគារលើដីនោះជាអចលនវត្ថុតែមួយ។ ម្យ៉ាងទៀត (២) ស្តីពីអានុភាពនៃការចុះបញ្ជីវិញទាក់ទងនឹងការបង្កើត ឬ ការផ្ទេរនូវផលុបភោគ និង សិទ្ធិប្រាតិភោគប្រត្យក្ស "ការចុះបញ្ជី" ជាលក្ខខណ្ឌតតាំង ប៉ុន្តែ ការផ្ទេរនូវកម្មសិទ្ធិនៃអចលនវត្ថុដោយការព្រមព្រៀងវិញ "ការចុះបញ្ជី" នឹងក្លាយទៅជាលក្ខខណ្ឌដើម្បីបង្កើត អានុភាព ហើយប្រសិនបើមិនបានចុះបញ្ជីទេ អានុភាពនៃការផ្ទេរកម្មសិទ្ធិក៏នឹងមិនកើតឡើងដែរ (CCកម្ពុជា មាត្រា ១១៣-១៣៥)។ ហើយស្តីអំពី (៣)ឯកសារបញ្ជាក់អំពីមូលហេតុនៃការចុះបញ្ជីវិញ ទាក់ទងទៅនឹងលិខិតកិច្ចសន្យាលក់ទិញអចលនវត្ថុជាអាទិ៍ បើមិនបានធ្វើឡើងដោយលិខិតយថាភូតទេ អានុភាពនឹងមិនកើតមាន ច្បាប់ដដែល មាត្រា៣៣៦(កថាខណ្ឌទី២) ហើយការបង្កើតកិច្ចសន្យាផ្សេងក្រៅពីនោះ ដូចជាកិច្ចសន្យាបង្កើតហ៊ីប៉ូតែកជាអាទិ៍ ក៏អាចធ្វើឡើងជាលិខិតលាយលក្ខណ៍អក្សរដែលធ្វើឡើងដោយមន្ត្រីមានសមត្ថកិច្ចក៏បានដែរ។ រីឯ(៤)ការដាក់ពាក្យសុំចុះបញ្ជី និង សមត្ថកិច្ចអនុវត្តការចុះបញ្ជីនៅប្រទេសជប៉ុន គឺជាមន្ទីរកិច្ចការច្បាប់ (Regional Legal Affairs Bureau) ប៉ុន្តែ នៅប្រទេសកម្ពុជារដ្ឋបាលសុរិយោដីមានដូចជា ក្រសួងដែនដីរាជធានី និង ខេត្ត ហើយរដ្ឋបាលសុរិយោដីដែលទទួលពាក្យសុំ ត្រូវបានបែងចែកទៅតាមថ្នាក់ក្រុង ស្រុក ខណ្ឌ ឬ រាជធានី ខេត្ត។

នៅប្រទេសកម្ពុជា សៀវភៅគោលបញ្ជីដីធ្លីត្រូវបានបំផ្លិចបំផ្លាញដោយរដ្ឋាភិបាលប៉ុលពត និង ក្រោមភាពច្របូកច្របល់នៃសង្គ្រាមផ្ទៃក្នុងក្រោយពេលនោះ។ ច្បាប់ភូមិបាលឆ្នាំ ១៩៩២ និង ២០០១ បានចែងនូវបញ្ញត្តិថា មិនទទួលស្គាល់នូវកម្មសិទ្ធិលើអចលនវត្ថុនៅមុនឆ្នាំ១៩៧៩ ហើយកម្ពុជាបានចាប់ផ្តើមបង្កើតនូវសៀវភៅគោលបញ្ជីដីធ្លីចាប់ពីចំណុចសូន្យបន្តរហូតរៀងមក។ ជាលទ្ធផល គិតត្រឹមចុងខែកញ្ញា ឆ្នាំ២០១៧ ក្នុងពេលបច្ចុប្បន្ននេះ មានតែដីចំនួនប្រហែល ៦៥% នៃផ្ទៃប្រទេសតែប៉ុណ្ណោះដែលបានធ្វើការចុះបញ្ជីដំបូង (ចុះបញ្ជីស្តីពីអត្ថិភាពនៃកម្មសិទ្ធ)។ ប៉ុន្តែដោយសារតែសិទ្ធិកាន់កាប់ពិសេស មានស្រដៀងគ្នាទៅនឹងកម្មសិទ្ធិលើដីធ្លី) ត្រូវបានទទួលស្គាល់ដោយច្បាប់ភូមិបាលឆ្នាំ២០០១ (CCកម្ពុជា មាត្រា២៤២ និងមាត្រា២៤៣) ដូច្នេះហើយទំនាក់ទំនងនៃសិទ្ធិលើអចលនវត្ថុ និងការផ្សព្វផ្សាយជាសាធារណៈ (ការចុះបញ្ជី) មានភាពស្មុគស្មាញខ្លាំង។

### ខ. ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

បន្ថែមពីនេះ នៅប្រទេសកម្ពុជាបានយកប្រព័ន្ធទ្រព្យសម្បត្តិរួមប្តីប្រពន្ធ មកធ្វើជាប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ ហើយបានទទួលស្គាល់នូវការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ថាជាប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា។ ប៉ុន្តែ កិច្ចសន្យា នេះមិនត្រឹមតែធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ទំនាក់ទំនងទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធតែប៉ុណ្ណោះទេ ថែមទាំងមិនអាចយកមកតតាំងបានឡើយ (CCកម្ពុជា មាត្រា៩៧០) បើកិច្ចសន្យានោះមិនបានចុះបញ្ជី ក្នុងករណីដែលជួយការពារដល់តតិយជនដែលធ្វើកិច្ចការជំនួញជាមួយនឹងប្តីប្រពន្ធនោះ។

ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធឆ្នាំ២០១៣ បានយកនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី នៃក្រសួងយុត្តិធម៌ ធ្វើជាស្ថាប័នមានសមត្ថកិច្ចក្នុងកិច្ចការចុះបញ្ជី ហើយបានចែងអំពីចុះបញ្ជីការផ្លាស់ប្តូរការលុប ចោលការកែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ និង នីតិវិធីនៃការការចេញលិខិតបញ្ជាក់ជាដើម។ ប៉ុន្តែ អ្នកដែលមិនបានដឹងអំពីអត្ថិភាពនៃក្រុមណ្ឌចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធក៏មានច្រើនផងដែរ ដូច្នេះហើយ ស្ទើរតែគ្មាន អ្នកប្រើប្រាស់នូវការចុះបញ្ជីនេះទេ។[41]

#### ២.២.១.១. បទប្បញ្ញត្តិទូទៅ នៃពាក្យសុំចុះបញ្ជី

#### ក. ពាក្យសុំចុះបញ្ជី

១. រាល់ពាក្យសុំចុះបញ្ជី ទាក់ទងនឹងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។ ពាក្យសុំច្បាប់ដើម ត្រូវមានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់អ្នកដាក់ពាក្យសុំ ដោយភ្ជាប់មក ជាមួយនូវច្បាប់ចតចម្លងនៃច្បាប់ដើមនោះ។

២. ជាគោលការណ៍ពាក្យ សុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ ពិពាហ៍ជាមួយគ្នា ត្រូវធ្វើឡើងរួមគ្នា។ លើកលែងតែករណីដូចខាងក្រោម អាចដាក់ពាក្យសុំតែម្នាក់ឯងបាន ៖

ក. ការផ្លាស់ប្តូរ ឬ ការកែតម្រូវតែ ឈ្មោះ អាសយដ្ឋាន ថ្ងៃខែឆ្នាំកំណើត ប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា។

ខ. ការចុះបញ្ជី ដោយផ្អែកលើសាលក្រម ឬ សាលដីកា ឬ ដីកាសម្រេចស្ថាពរ ប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ដូចមានចែងនៅក្នុងមាត្រា ៣០ កថាខណ្ឌទី ៣ចំណុច ខ, គ, ឃ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី។

៣. រាល់ពាក្យសុំចុះបញ្ជីខាងលើ អ្នកតំណាងក៏អាចកាន់យកមកដាក់នៅ ចំពោះមុខមន្ត្រីចុះបញ្ជីជំនួសប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានដែរ។

[41] Professor of Law, Waseda University MasayukI Tanamura។

៤. បុគ្គល ឬ អ្នកតំណាង ដែលដាក់ពាក្យសុំចុះបញ្ជី ត្រូវយកពាក្យសុំនោះ មកដាក់នៅនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី នៃក្រសួងយុត្តិធម៌ដោយផ្ទាល់។[42]

**ខ. ទម្រង់នៃពាក្យសុំចុះបញ្ជី**

១- ទម្រង់នៃពាក្យសុំចុះបញ្ជី ត្រូវសរសេរបាវចនានៃព្រះរាជាណាចក្រកម្ពុជា ពាក្យសុំចុះបញ្ជី ឈ្មោះ និងអាសាយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាង (ប្រសិនបើមាន) ហើយត្រូវគោរពចូលមករដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ព្រមទាំងមានចុះកាលបរិច្ឆេទ និងហត្ថលេខា ឬ ស្នាមម្រាមដៃរបស់អ្នកដាក់ពាក្យសុំ។

២- ក្រៅពីនេះ ត្រូវសរសេរបន្ថែមនូវចំណុចមួយចំនួនទៅតាមប្រភេទនៃពាក្យសុំចុះបញ្ជីទាក់ទង នឹងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យ សម្បត្តិប្តីប្រពន្ធ ជាអាទិ៍) ដូចមានចែងក្នុងជំពូកទី ៥ (ពាក្យសុំចុះបញ្ជី) នៃប្រកាសនេះ។[43]

**គ. ឯកសារភ្ជាប់ជាមួយពាក្យសុំចុះបញ្ជី**

១. នៅពេលដាក់ពាក្យសុំចុះបញ្ជី អ្នកដាក់ពាក្យសុំចុះបញ្ជីទាក់ទងនឹងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យា ទ្រព្យសម្បត្តិប្តីប្រពន្ធ ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ជាអាទិ៍) ដូចមានចែងក្នុងជំពូកទី ៥ (ពាក្យសុំចុះបញ្ជី) នៃប្រកាសនេះ ត្រូវផ្តល់ឯកសារចាំបាច់មួយចំនួនទៅឱ្យ នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ទៅតាមប្រភេទនៃពាក្យសុំចុះបញ្ជីនោះ។

២. ចំពោះពាក្យសុំចុះបញ្ជី ដែលអ្នកតំណាងយកមកដាក់ ដូចមានចែងក្នុងប្រការ ១៥ កថាខណ្ឌទី៣ ត្រូវភ្ជាប់លិខិតប្រគល់សិទ្ធិតំណាងផងដែរ។[44]

[42] ប្រកាសស្តីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ប្រការ ១៥។
[43] ប្រកាសស្តីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ប្រការ ១៦។
[44] ប្រកាសស្តីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ប្រការ ១៧។

**ឃ. ការប្រគល់ច្បាប់ដើមនៃឯកសារភ្ជាប់**

១. ចំពោះឯកសារដែលភ្ជាប់ជាមួយនឹងពាក្យសុំ អ្នកដាក់ពាក្យសុំអាចទាមទារឱ្យប្រគល់វិញនៅពេលដាក់ពាក្យសុំ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្ត ចំពោះលិខិតប្រគល់សិទ្ធិតំណាង។

២. ដើម្បីទាមទារឱ្យប្រគល់ឯកសារភ្ជាប់ អ្នកដាក់ពាក្យសុំត្រូវភ្ជាប់ជាមួយនឹងពាក្យសុំនោះនូវឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ថា ការសរសេរនៅក្នុងឯកសារនោះគ្មានភាពខុសពីច្បាប់ដើម ។

៣. ក្នុងករណីដែលប្រគល់ច្បាប់ដើមនៃឯកសារភ្ជាប់ មន្ត្រីចុះបញ្ជីត្រូវឱ្យអ្នកទទួលការប្រគល់ សរសេរនៅក្នុងឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នូវការណ៍ ដែលខ្លួនបានទទួលការប្រគល់ឯកសារនោះ និងចុះហត្ថលេខា។[45]

**២.២.១.២. ពាក្យសុំចុះបញ្ជី**

**ក. ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

ប្រសិនបើមានការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ប្តីប្រពន្ធ ឬបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា អាចដាក់ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធបាន។ ក្រៅពីទម្រង់នៃពាក្យចុះបញ្ជីក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោម៖

ក. ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ. គោលបំណងនៃការចុះបញ្ជី

គ. មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ)

ឃ. ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ង. កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ ក្នុងករណីដែលអ្នកដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍។

**+ ឯកសារភ្ជាប់៖**

- កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- សំបុត្រអាពាហ៍ពិពាហ៍ ក្នុងករណីដែលអ្នកដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍
- វិញ្ញាបនបត្របញ្ជាក់ អំពីព័ត៌មានដែលបានចុះនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅចុះបញ្ជីអចលនវត្ថុ សៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍សៀវភៅ

[45] ប្រកាសស្តីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ប្រការ ១៨។

ចុះបញ្ជីផលុបភោគ) ក្នុងករណីដែលកិច្ចសន្យានេះពាក់ព័ន្ធ នឹងបញ្ជីដីធ្លី លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនមាន) អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន។[46]

**ខ. ករណីសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

ប្រសិនបើមានការផ្លាស់ប្តូរនូវចំណុចដែលបានចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ប្តីប្រពន្ធ ឬបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវដាក់ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរនោះ។ ក្រៅពីទម្រង់នៃពាក្យសុំចុះបញ្ជី ក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ ត្រូវសរសេរបន្ថែមនូវ៖

ក. ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ. គោលបំណងនៃការចុះបញ្ជី

គ. មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃការផ្លាស់ប្តូរ)

ឃ. ចំណុចដែលត្រូវផ្លាស់ប្តូរ

- ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- ឈ្មោះ ឬអាសយដ្ឋានថ្មី

**+ ឯកសារភ្ជាប់៖**

- កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធថ្មី
- សាលក្រម ឬសាលដីកាផ្លាស់ប្តូរ
- លិខិតបញ្ជាក់អំពីការផ្លាស់ប្តូរអាសយដ្ឋាន
- វិញ្ញាបនបត្របញ្ជាក់ អំពីព័ត៌មានដែលបានចុះនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅចុះបញ្ជីអចលនវត្ថុ សៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ សៀវភៅចុះបញ្ជីផលុបភោគ) ក្នុងករណីដែលកិច្ចសន្យានេះពាក់ព័ន្ធនឹងបញ្ជាដីធ្លីក្រោយពីមានការផ្លាស់ប្តូរ
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនមាន)
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន។[47]

[46] ប្រកាសស្តីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ប្រការ ១៩។

[47] ប្រកាសស្តីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ប្រការ ២០។

**គ. ករណីសុំចុះបញ្ជីអំពីការកែតម្រូវ ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

នៅពេលកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវបានចុះបញ្ជីរួចហើយ បើពិនិត្យឃើញថាមានកំហុស ឬមិនបានចុះបញ្ជី ប្តីប្រពន្ធ ឬបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាត្រូវដាក់ពាក្យសុំចុះបញ្ជី។ ក្រៅពីទម្រង់នៃពាក្យសុំចុះបញ្ជី ក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោម៖

ក. គោលបំណង

ខ. មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទដែលបានកែតម្រូវ)

ឃ. ចំណុចដែលត្រូវកែតម្រូវ

- ឈ្មោះ
- អាសយដ្ឋាន
- ថ្ងៃ ខែ ឆ្នាំកំណើត
- កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍

**+ ឯកសារភ្ជាប់៖**

- កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រព្ធ
- សំបុត្រអាពាហ៍ពិពាហ៍ វិញ្ញាបនបត្របញ្ជាក់អំពីព័ត៌មានដែលបានចុះនៅក្នុងសៀវភៅចុះបញ្ជី (សៀវ ភៅចុះបញ្ជីអចលនវត្ថុ សៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ សៀវភៅចុះបញ្ជីផលុបភោគ) ក្នុងករណីដែលកិច្ចសន្យានេះ ពាក់ព័ន្ធនឹងបញ្ហាដីធ្លីក្រោយពេលមានការកែតម្រូវ
- លិខិតបញ្ជាក់អាសយដ្ឋាន
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន។[48]

**ឃ. ករណីសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយមូលហេតុ៖**

**❖ រំលាយអាពាហ៍ពិពាហ៍ ឬ កំជាប់ពាក្យ**

ប្រសិនបើប្តីប្រពន្ធបានរំលាយអាពាហ៍ពិពាហ៍ ឬ ប្រសិនបើបុគ្គលដែលនឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានរំលាយកំជាប់ពាក្យ ប្តីប្រពន្ធ ឬ បុគ្គលដែលនឹងរៀបអាពាហ៍ពិពាហ៍ ជាមួយគ្នាត្រូវដាក់ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។ ក្រៅពីទម្រង់នៃពាក្យ សុំចុះបញ្ជី ក្នុងកថាខណ្ឌទី១

[48] ប្រកាសស្តីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ប្រការ ២១។

នៃប្រការ ១៦ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោម៖

ក. ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ. គោលបំណងនៃការចុះបញ្ជី

គ. មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទរំលាយអាពាហ៍ពិពាហ៍ ឬ កំជាប់ពាក្យ)

**+ ឯកសារភ្ជាប់៖**

- ដីកាសម្រេច ដែលរំលាយអាពាហ៍ពិពាហ៍តាមការព្រមព្រៀង
- លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃដីការសម្រេច
- កិច្ចព្រមព្រៀង ឬ ការជូនដំណឹងពីការរំលាយកំជាប់ពាក្យ
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន។[49]

### ❖ មោឃភាព ការលុបចោល ឬ ការរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

ប្រសិនបើកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធដែលបានចុះបញ្ជីរួច ត្រូវបាន មោឃៈ រំលាយ ឬ លុបចោល ប្ដីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានោះ ត្រូវដាក់ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ។ ក្រៅពីទម្រង់នៃពាក្យសុំចុះបញ្ជី ក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោម៖

ក. ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ. គោលបំណងនៃការចុះបញ្ជី

គ. មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃ មោឃភាព, ការលុបចោល, ការរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

**+ ឯកសារភ្ជាប់៖**

- សាលក្រម ឬ សាលាដីកាស្ថាពរ ដែលបញ្ជាក់ថាកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ត្រូវបានមោឃៈ លុបចោល ឬ រំលាយ
- លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃសាលក្រម ឬ សាលដីកា
- កិច្ចព្រមព្រៀង ឬ ការជូនដំណឹង ដែលបញ្ជាក់ពីការលុបចោល ឬ រំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

[49] ប្រកាសស្តីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ប្រការ ២២។

- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន។[50]

❖ **សហព័ទ្ធណាម្នាក់ស្លាប់**

ប្រសិនបើសហព័ទ្ធណាម្នាក់ស្លាប់ ប្រសិនបើបុគ្គលដែលនឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានស្លាប់ សហព័ទ្ធ សហព័ទ្ធដែលនៅរស់ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាដែលនៅរស់ ត្រូវដាក់ពាក្យសុំចុះបញ្ជីអំពីការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។ ក្រៅពីទម្រង់នៃពាក្យសុំចុះបញ្ជី ក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោម៖

ក. ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ. គោលបំណងនៃការចុះបញ្ជី

គ. មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃមរណភាព)

**+ ឯកសារភ្ជាប់៖**

- សំបុត្រមរណភាព
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណបណ្ណ ឬ លិខិតឆ្លងដែន។[51]

❖ **ដោយផ្អែកលើសាលាក្រម ឬ សាលាដីកាស្ថាពរ រំលាយអាពាហ៍ពិពាហ៍ និងការបែងចែកទ្រព្យសម្បត្តិ**

ប្រសិនបើមានសេចក្តីសម្រេចអំពីការបែងចែកទ្រព្យសម្បត្តិក្នុងសាលក្រម ឬ សាលដីការំលាយអាពាហ៍ពិពាហ៍ដែលបានចូលជាស្ថាពរ អតីតសហព័ទ្ធណាម្នាក់ ត្រូវដាក់ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។ ក្រៅពីទម្រង់នៃពាក្យសុំចុះបញ្ជី ក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោម៖

ក. ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ. គោលបំណងនៃការចុះបញ្ជី

គ. មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃសាលក្រម ឬ សាលដីកាស្ថាពរ)

[50] ប្រកាសស្តីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ប្រការ ២៣។

[51] ប្រកាសស្តីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ប្រការ ២៤។

**+ ឯកសារភ្ជាប់៖**

- សាលក្រម ឬ សាលដីកាលែងលះអាពាហ៍ពិពាហ៍ និងការបែងចេកទ្រព្យសម្បត្តិដែលបានចូលេជាស្ថាពរ
- លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃសាលក្រម ឬសាលដីកា
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណបណ្ណ ឬ លិខិតឆ្លងដែន។[52]

❖ **តាមសេចក្ដីសម្រេចរបស់តុលាការ ដោយផ្អែកលើបញ្ញត្តិនៃច្បាប់ស្តីពីនីតិវិធិនៃរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង**

ប្រសិនបើតុលាការសម្រេចសេចក្តី អំពីការបែងចែកទ្រព្យសម្បត្តិ ដោយការលែងលះអាពាហ៍ពិពាហ៍ ដោយផ្អែកលើបញ្ញត្តិនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ហើយសេចក្តីសម្រេចនោះបានចូលជាស្ថាពរ អតីតសហព័ទ្ធណាម្នាក់ ត្រូវដាក់ពាក្យសុំលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។ ក្រៅពីទម្រង់នៃពាក្យសុំចុះបញ្ជី ក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោម៖

ក. ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ. គោលបំណងនៃការចុះបញ្ជី

គ. មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃសេចក្តីសម្រេចរបស់តុលាការ)

**+ ឯកសារភ្ជាប់៖**

- ដីកាសម្រេចការបែងចែកទ្រព្យសម្បត្តិដោយការលែងលះអាពាហ៍ពិពាហ៍ ដែលបានចូលជាស្ថាពរ
- លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃដីកាសម្រេច
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន។[53]

[52] ប្រកាសស្តីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ប្រការ ២៥។

[53] ប្រកាសស្តីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ប្រការ ២៦។

❖ **ដោយផ្អែកតាមសាលក្រម ឬ សាលដីកាស្ថាពរ ដែលបានកំណត់ក្នុងច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី មាត្រា ៣០ កថាខណ្ឌទី ៣ ចំណុច ឃ**

នៅពេលមានសាលក្រម ឬ សាលដីកាស្ថាពរដែលកំណត់ក្នុងច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី មាត្រា ៣០ កថាខណ្ឌទី ៣ ចំណុច ឃ ភាគីណាម្នាក់ ត្រូវដាក់ពាក្យសុំលុបការចុះបញ្ជី។ ក្រៅពីទម្រង់នៃពាក្យសុំចុះបញ្ជី ក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោម៖

ក. ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ. គោលបំណងនៃការចុះបញ្ជី

គ. មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃសាលក្រម ឬ សាលដីកាស្ថាពរ)

**+ ឯកសារភ្ជាប់៖**

- សាលក្រម ឬ សាលដីកាស្ថាពរ
- លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃសាលក្រម ឬ សាលដីការ
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន។[54]

**ង. ករណីសុំចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍**

នៅពេលដែលបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា បានរៀបអាពាហ៍ពិពាហ៍ក្រោយពីបានធ្វើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ បុគ្គលនោះត្រូវដាក់ពាក្យសុំចុះបញ្ជីបន្ថែមអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍។ ក្រៅពីទម្រង់នៃពាក្យសុំចុះបញ្ជី ក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោម៖

ក. ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ. គោលបំណងនៃការចុះបញ្ជី

គ. កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍

**+ ឯកសារភ្ជាប់៖**

- សំបុត្រអាពាហ៍ពិពាហ៍
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន។[55]

[54] ប្រកាសស្តីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ប្រការ ២៧។

[55] ប្រកាសស្តីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ប្រការ ២៨។

### ២.២.១.៣. សមត្ថកិច្ចចុះបញ្ជី

- **ស្ថាប័នមានសមត្ថកិច្ចលើការចុះបញ្ជី**

១. នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី នៃក្រសួងយុត្តិធម៌ មានសមត្ថកិច្ចលើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ។

២. មន្ត្រីដែលទទួលបន្ទុកកិច្ចការ ដែលទាក់ទងនឹងការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ (មន្ត្រីចុះបញ្ជី) ត្រូវនៅក្នុងនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ។

៣. ក្រូណូទាក់ទងនឹងការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ត្រូវរក្សាទុកនៅក្នុងនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី។[56]

## ២.២.២. នីតិវិធីនៃការចេញលិខិតបញ្ជាក់

### ក. របៀបដាក់ពាក្យសុំឱ្យចេញលិខិតបញ្ជាក់

១. ពាក្យសុំឱ្យចេញលិខិតបញ្ជាក់ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។

២. ពាក្យសុំឱ្យចេញលិខិតបញ្ជាក់ ត្រូវដាក់នៅនាយកដ្ឋានកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌។

៣. ពាក្យសុំឱ្យចេញលិខិតបញ្ជាក់ ត្រូវសរសេរនូវចំណុច ដូចខាងក្រោម ៖

- គោលបំណងនៃពាក្យសុំ ៖ ការសុំឱ្យចេញលិខិតបញ្ជាក់
- ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំឱ្យចេញលិខិតបញ្ជាក់
- ឈ្មោះរបស់អ្នកតំណាងនីតិបុគ្គលក្នុងករណីដែលអ្នកដាក់ពាក្យសុំឱ្យចេញលិខិតបញ្ជាក់ជានីតិបុគ្គល
- ចំណុចដែលត្រូវធ្វើការបញ្ជាក់
- ចំនួនលិខិតបញ្ជាក់
- កាលបរិច្ឆេទនៃការដាក់ពាក្យសុំ និងហត្ថលេខា ឬ ស្នាមម្រាមដៃ។

៤. អ្នកដាក់ពាក្យសុំឱ្យចេញលិខិតបញ្ជាក់ ត្រូវបង់សោហ៊ុយសេវា ដូចបានកំណត់ តាមបទប្បញ្ញត្តិ ឬ ប្រកាសរួម របស់ក្រសួងយុត្តិធម៌ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[57]

[56] ប្រកាសស្ដីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ប្រការ ៤។
[57] ប្រកាសស្ដីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ប្រការ ៤៨។

**ខ. ការចេញលិខិតបញ្ជាក់**

១. នៅពេលបានទទួលពាក្យសុំឱ្យចេញលិខិតបញ្ជាក់ មន្ត្រីចុះបញ្ជីត្រូវថតចម្លងចេញពីសន្លឹកចុះបញ្ជីក្នុងក្រូណូចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ទៅឱ្យអ្នកដាក់ពាក្យសុំ ដោយត្រូវសរសេរនៅលើឯកសារថតចម្លងថា ៖

- បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
- កាលបរិច្ឆេទ (ថ្ងៃទី...... ខែ..........ឆ្នាំ...........)
- ហត្ថលេខាបំពេញរបស់មន្ត្រីចុះបញ្ជី និងហត្ថលេខា និងប្រថាប់ត្រារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក៏អាចឱ្យរដ្ឋលេខាធិការទទួលបន្ទុកកិច្ចការរដ្ឋប្បវេណី ចុះហត្ថលេខាជំនួសបានដែរ។

២. ក្រោយពីបានទទួលពាក្យសុំឱ្យចេញលិខិតបញ្ជាក់ ក្រសួងយុត្តិធម៌ត្រូវចេញលិខិតបញ្ជាក់ឱ្យអ្នកដាក់ពាក្យសុំនោះ ដោយពុំមានការយឺតយ៉ាវ យ៉ាងយូរបំផុតមិនឱ្យលើសពីរយៈពេល ៣ ថ្ងៃ។[58]

## ២.៣. អនុភាពនៃប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា

តាមរយៈនៃការចុះកិច្ចសន្យាទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធ ដែលជាកត្តាយ៉ាងសំខាន់នៅក្នុងការ ផ្ដល់ឱ្យភាគីទាំងសងខាងនៃកិច្ចសន្យា ទទួលបាននូវភាពច្បាស់លាស់ ទៅលើទំនាក់ទំនងទ្រព្យទាំងមុនពេលរៀបអាពាហ៍ពិពាហ៍ និងក្រោយពេលរៀបអាពាហ៍ពិពាហ៍។ កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធដែលបង្កើតឡើងដោយមានលក្ខណៈពេញលេញ និងគោរពទៅតាមនីតិវិធីច្បាប់ ហើយបង្កើតនូវអានុភាពគតិយុត្តលើផ្នែកសិទ្ធិ និងករណីយកិច្ចរបស់សហព័ទ្ធទាំងសងខាង។ ទន្ទឹមនឹងការផ្ដល់ភាពងាយស្រួល និងអត្ថប្រយោជន៍នៃប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យានេះ វាក៏មានការលេចឡើងនូវភាពអវិជ្ជមាន និងបញ្ហាប្រឈមមួយចំនួនផងដែរ ជាក់ស្ដែងដូចជាបញ្ហាទំនុកចិត្តរបស់សហព័ទ្ធជាដើម។

### ២.៣.១. អនុភាពនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ជាកិច្ចសន្យាមួយដែលជួយសម្រួល និងបង្កើននូវភាពជាក់លាក់ដល់ប្ដីប្រពន្ធដែលបានចុះកិច្ចសន្យានោះ ទាក់ទងទៅនឹងបញ្ហាសំខាន់ៗជាច្រើនរួមមានចំណាត់ថែងនូវសិទ្ធិលើទ្រព្យសម្បត្តិ កាតព្វកិច្ច និងករណីកិច្ចដែលតម្រូវឱ្យសហព័ទ្ធគោរព និងអនុវត្តតាមគោលការណ៍ដែលច្បាប់បានកំណត់។ គួរបញ្ជាក់ផងដែរថា ការចុះបញ្ជីទ្រព្យសម្បត្តិប្ដីប្រពន្ធនេះ ត្រូវបង្កើតឡើងដោយមានការព្រមព្រៀងគ្នា

[58] ប្រកាសស្ដីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធប្រការ ៤៩។

រវាងភាគី និងត្រូវបានធ្វើឡើងនៅចំពោះមុខមន្ត្រីក្រសួងយុត្តិធម៌ ហើយគោរពទៅតាមការកំណត់ និងចង្អុលបង្ហាញរបស់ច្បាប់ដើម្បីធានាឱ្យមានភាពត្រឹមត្រូវនឹងបង្កើតឱ្យមាននូវអានុភាពគតិយុត្ត។

### ២.៣.១.១. អនុភាពនៃការចុះបញ្ជី

ចំពោះប្ដីប្រពន្ធបាន និងបម្រុងបង្កើតនូវចំណងអាពាហ៍ពិពាហ៍ហើយបានទៅចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ក្នុងគោលបំណងកំណត់ និងបែងចែករវាងទ្រព្យរួម និងទ្រព្យដោយឡែក គឺនាំឱ្យមានភាពងាយស្រួលចំពោះសហព័ទ្ធនៅក្នុងការប្រើប្រាស់សិទ្ធិលើទ្រព្យដែលខ្លួនមាន លើសពីនេះទៅទៀតនៅពេលដែលសហព័ទ្ធឈានដល់ការបញ្ចប់ចំណងអាពាហ៍ពិពាហ៍ ហើយមានជម្លោះដែលទាក់ទងទៅនឹងបញ្ហាទ្រព្យសម្បត្តិ នោះកិច្ចសន្យាដែលទាក់ទងនឹងការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធនឹងក្លាយជាកម្មវត្ថុដ៏សំខាន់ នៅក្នុងការបែងចែកទ្រព្យសម្បត្តិ។ យ៉ាងណាមិញនៅក្នុងប្រទេសកម្ពុជាយើងវិញ នៅមានប្រជាពលរដ្ឋមួយចំនួន ដែលឱ្យតម្លៃទៅលើការរៀបអាពាហ៍ពិពាហ៍ ការប្រារព្ធពិធីតាមបែបទំនៀមទម្លាប់ប្រពៃណី ក៏ប៉ុន្តែពួកគាត់បែរជាមិនសូវមានការយកចិត្តទុកដាក់ទៅលើការចុះសំបុត្រអាពាហ៍ពិពាហ៍ទៅតាមនីតិវិធី និងការកំណត់របស់ច្បាប់ទៅវិញ។ ទាំងនេះបញ្ជាក់ឱ្យឃើញថា ប្រជាពលរដ្ឋកម្ពុជាមួយចំនួនពុំទាន់មានការយល់ដឹងច្បាស់លាស់អំពីបញ្ហា ដែលទាក់ទងទៅនឹងបទបញ្ញត្តិច្បាប់នៃការចុះសំបុត្រអាពាហ៍ពិពាហ៍ ព្រមទាំងអានុភាពគតិយុត្តក្រោយពីទទួលបានការចុះបញ្ជីទ្រព្យសម្បត្តិ។ អានុភាពកិច្ចសន្យាប្តីប្រពន្ធមានលក្ខណៈទូលាយ និងមានអានុភាពទាំងចំពោះភាគីនៃកិច្ចសន្យាពោលគឺ ប្តី និងប្រពន្ធ ព្រមទាំងមានអានុភាពសម្រាប់តាំងចំពោះតតិយជនផងដែរ។

### ២.៣.១.២. អនុភាពចំពោះភាគី

ការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធអាចធ្វើឡើង នៅមុនពេលរៀបអាពាហ៍ពិពាហ៍ ឬក្រោយអាពាហ៍ពិពាហ៍ក៏បាន គ្រាន់តែការចុះនោះតម្រូវឱ្យគោរពតាមនីតិវិធីច្បាប់ឱ្យបានគ្រប់ជ្រុងជ្រោយដើម្បីធានាបាននូវអានុភាពនៃកិច្ចសន្យានោះ និងស្របទៅតាមគោលការណ៍គតិយុត្ត។ ការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធនេះនឹងបង្កើតនូវអានុភាពចំពោះភាគីនៃកិច្ចសន្យាដែលបានចុះបញ្ជីនោះ ហើយត្រូវបានកំណត់ដ៏ជាក់លាក់មួយអំពីទំហំនៃទ្រព្យដែលសហព័ទ្ធទាំងសងខាងមាន ព្រមទាំងបង្កើនឱ្យមានភាពច្បាស់លាស់ចំពោះសិទ្ធិក្នុងការប្រើប្រាស់ទ្រព្យ និងកាតព្វកិច្ចដែលភាគីនីមួយៗត្រូវបំពេញ ឬការអនុវត្ត។

### ២.៣.១.៣. អនុភាពចំពោះតតិយជន

ក្រៅពីការបង្កើតឱ្យមានអានុភាពដល់សហព័ទ្ធដែលជាភាគីនៃកិច្ចសន្យា ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ក៏បង្កើតនូវអានុភាពចំពោះតតិយជនផងដែរ។ តតិយជនដែលមានផលប្រយោជន៍ ឬមានបំណងចង់បញ្ជាក់នូវទំហំទ្រព្យសម្បត្តិរបស់ប្តី ឬប្រពន្ធពោលគឺ មានបំណងចង់ដឹងអំពីការកំណត់នូវទ្រព្យសម្បត្តិរបស់ភាគីណាម្ខាងនៃកិច្ចសន្យា ឱ្យបានច្បាស់លាស់ដើម្បីជាមូលចំពោះដ្ឋាននៅក្នុងការសម្រេច ធ្វើកិច្ច

គតិយុត្តណាមួយជាមួយភាគីប្តី ឬប្រពន្ធជៀសវាងការខាតបង់ទ្រព្យរបស់ខ្លួននោះ តតិយជននោះអាចស្នើសុំចេញនូវ លិខិតបញ្ជាក់នៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះបាន។ គួរបញ្ជាក់ផងដែរថា តតិយជនដែលអាចទាមទារឱ្យមានការចេញនូវលិខិតបញ្ជាក់នោះ អាចជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានផលប្រយោជន៍ចំពោះទ្រព្យ ហើយចំពោះការសុំចេញលិខិតបញ្ជាក់នេះត្រូវតែគោរពតាមគោលការណ៍ និងលក្ខខណ្ឌដែលច្បាប់បានកំណត់ ជាពិសេសការបញ្ជាក់ពីគោលបំណង ឬកម្មវត្ថុនៃការសុំនោះជាដើម។[59]

[59] https://thimhorn.wordpress.com/2017/11/09/%E1%9E%94%E1%9F%92%E1%9E%9A%E1%9E%96%E1%9F%90%E1%9E%93%E1%9F%92%E1%9E%92%E1%9E%91%E1%9F%92%E1%9E%9A%E1%9E%96%E1%9F%92%E1%9E%99%E1%9E%9F%E1%9E%98%E1%9F%92%E1%9E%94%E1%9E%8F%E1%9F%92%E1%9E%8F%E1%9E%B7/

# ជំពូកទី៣
# ការបែងចែកទ្រព្យសម្បត្តិ និងភាតព្វកិច្ចរបស់សហព័ន្ធ

# ជំពូកទី៣

# ការបែងចែកទ្រព្យសម្បត្តិ និងកាតព្វកិច្ចរបស់សហព័ន្ធ

នៅក្នុងជីវិតគូរអាពាហ៍ពិពាហ៍ ប្តី ឬប្រពន្ធ រមែងតែងតែជួបបញ្ហារកាំរកូស ការមិនចុះសម្រុងគ្នា ឬសហព័ទ្ធណាបានប្រព្រឹត្តកំហុស ដែលជាមូលហេតុចម្បងដែលធ្វើឱ្យមានជម្លោះកើតឡើង ឈានដល់ការលែងលះគ្នា។ បើយើងសង្កេតមើលទៅលើ ការដោះស្រាយបញ្ហាជម្លោះ ឬវិវាទក្នុងគ្រួសារវិញក្រៅពីការចរចារ សម្រុះសម្រួលគ្នា បទដ្ឋានគតិយុត្តិ និងបទបញ្ញត្តិផ្សេងៗទៀត ត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ អាស្រ័យទៅលើតម្រូវការ និងបរិបទនៃសង្គម ដើម្បីស្វែងរកនូវដំណោះស្រាយដ៏សមស្រប និងប្រកបទៅដោយប្រសិទ្ធភាពណាមួយ។

ដូចដែលយើបានដឹងហើយថា អាពាហ៍ពិពាហ៍ គឺជាការប្តេជ្ញាដ៏ម៉ឹងម៉ាត់ ដែលបង្កើតសិទ្ធិ និងករណីយកិច្ចដ៏សំខាន់សម្រាប់សហព័ទ្ធទាំងពីរនាក់។ ដោយសារ ការសំខាន់នៃគ្រួសារចំពោះសង្គម និងដោយសារការពឹងផ្អែកគ្នាទៅវិញទៅមករវាងប្តី ប្រពន្ធ និងកូន រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការដាក់បញ្ញត្តិច្បាប់ស្តីពីការផ្តាច់ចំណងអាពាហ៍ពិពាហ៍។

ដូច្នេះ ដូចគ្នានឹងករណីមនុស្សពីរនាក់មិនអាចរៀបអាពាហ៍ពិពាហ៍បាន លើកលែងតែគេទាំងពីរបានបំពេញតម្រូវការខ្លះដែលមានចែងក្នុងច្បាប់ មនុស្សពីរនាក់ក៏មិនអាចរំលាយចំណងអាពាហ៍ពិពាហ៍បានដែរ លើកលែងតែគេបានបំពេញតាមតម្រូវការត្រឹមត្រូវតាមច្បាប់។ ដើម្បីរំលាយទំនាក់ទំនងរវាងប្តី និងប្រពន្ធ មូលហេតុជាក់លាក់ត្រូវតែមាន។ ហេតុផលទាំងនេះហៅថា «មូលហេតុ» មានចែងនៅក្នុងច្បាប់។ មានតែតុលាការទេដែលអាចកំណត់ថា តើមាន ឬមិនមានមូលហេតុគ្រប់គ្រាន់ ដើម្បីបញ្ជាក់ហេតុផលនៃការរំលាយកិច្ចសន្យាអាពាហ៍ពិពាហ៍។[60]

នៅពេលរំលាយចំណងអាពាហ៍ពិពាហ៍ មានអានុភាពចំពោះទ្រព្យសម្បត្តិ ដូចជា ទៅដល់ការបែងចែកទ្រព្យសម្បត្តិ និងកាតព្វកិច្ចរបស់សហព័ទ្ធ។ ហើយការបែងចែកសម្បត្តិនៅពេលលែងលះ ត្រូវធ្វើទៅតាមគោលការណ៍នៃការព្រមព្រៀង (មាត្រា ៩៨០ កថខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)។ ផ្ទុយទៅវិញ បើពុំអាចពិភាក្សាគ្នាបានទេគឺ ត្រូវធ្វើការបែងចែកទ្រព្យសម្បត្តិរបស់សហព័ទ្ធ ដោយផ្អែកទៅតាមចំណុចនីមួយៗដែលមានចែងនៅត្រង់មាត្រា ៩៨០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីរួមមាន៖ សហព័ទ្ធទទួលបាននូវទ្រព្យដោយឡែករបស់ខ្លួន និង បន្ថែមលើសនេះត្រូវយកទ្រព្យរួមទៅបែងចែកម្នាក់ៗត្រូវទទួលបាន ១ភាគ២ នៃទ្រព្យរួម។ ការលែងលះអាចមានមូលហេតុហិង្សារវាងប្តីប្រពន្ធ គឺជាអំពើអនីត្យានុកូល អាចទាមទារសំណងការខូចខាតបាន។ បណ្តឹងលែងលះ និងការទាមទារសំណងអាចធ្វើក្នុងបណ្តឹងតែមួយបាន (តាមខ្លឹមសារនៃ មាត្រា ១១ នៃច្បាប់ស្តីពីនីតិវិធី

[60] នីតិគ្រួសា និង អាពាហ៍ពិពាហ៍ ភាគ ១ បោះពុម្ពលើកទី២ ឆ្នាំ២០២១ និពន្ធដោយ ឥន យឿន។

បណ្តឹងទាក់ទងនឹងឋានៈបុគ្គល)។ លើសពីនេះទៀត តុលាការក៏អាចសម្រេចឱ្យសហព័ទ្ធណាម្នាក់សងតម្លៃ នៃទ្រព្យសម្បត្តិដោយឡែកនៃភាគីម្ខាង ដែលបានធ្វើការបំផ្លាញ ក្នុងកំឡុងពេលមានចំណងអាពាហ៍ពិពាហ៍។[61] ដូច្នេះ ដើម្បីសិក្សាឱ្យបានកាន់តែមានភាពស៊ីជម្រៅអំពីការបែងចែកទ្រព្យសម្បត្តិ និងកាតព្វកិច្ចរបស់សហព័ទ្ធនៅពេលលែងលះគ្នា គប្បីធ្វើការស្វែងយល់ឱ្យបានច្បាស់នូវការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះ (ផ្នែកទី១) និងការបែងចែកកាតព្វកិច្ចបំណុលក្រោយពេលលែងលះ (ផ្នែកទី២) ជាមុនសិន។

## ផ្នែកទី១ ការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះ

ការបែងចែកទ្រព្យសម្បត្តិ គឺជាទិដ្ឋភាពមួយក្នុងចំណោមផលវិបាកសំខាន់ៗបំផុតនៃការលែងលះ ព្រោះជាទូទៅសហព័ទ្ធមិនងាយព្រមព្រៀងគ្នាលើរឿងបែងចែក និងសិទ្ធិគ្រប់គ្រងលើទ្រព្យសម្បត្តិទេ។

កាលពីអតីតកាល ប្រទេសជាច្រើនមានការរើសអើងចំពោះស្ត្រីដោយផ្តល់ឱ្យស្ត្រីនូវសិទ្ធិលើទ្រព្យសម្បត្តិតិចជាងបុរស ទាំងនៅក្នុងចំណងអាពាហ៍ពិពាហ៍ ទាំងនៅក្រោយពេលលែងលះគ្នា។ នៅទូទាំងពិភពលោក ច្បាប់របស់ប្រទេសជាច្រើនមិនបានទទួលស្គាល់តួនាទីដ៏សំខាន់ដែលស្ត្រីមាននៅក្នុងសេដ្ឋកិច្ចគ្រួសារទេ។

ប៉ុន្តែ សម្រាប់អរិយធម៌ខ្មែរបានទទួលស្គាល់ជាយូរមកហើយនូវតួនាទីដ៏សំខាន់ដែលស្ត្រីបានធ្វើសម្រាប់សេដ្ឋកិច្ចគ្រួសារ។ សុភាសិតខ្មែរជាច្រើនបញ្ជាក់ពីសារៈសំខាន់របស់ភរិយា ចំពោះភាពចម្រើនរុងរឿងនៃគ្រួសារ។ ឧទាហរណ៍៖ ប្រហែលជាអ្នកអានដឹងពីសុភាសិតខ្មែរថា « ទ្រព្យគង់ត្បិតស្រីចេះសំចៃទុក ផ្ទះធំស្រណុកត្បិតភរិយាជា »សុភាសុតខ្មែរមួយទៀតព្រមានដល់ប្តី « បើមិនស្គាល់យោបល់ស្រី ប្រយ័ត្នគ្មានស្រូវពូជឆ្នាំក្រោយ » ។

ដូច្នេះ គ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលទេ ដែលរដ្ឋធម្មនុញ្ញ និងក្រមរដ្ឋប្បវេណីរបស់ប្រទេសកម្ពុជាសព្វថ្ងៃ បានផ្តល់ឱ្យស្ត្រីនូវសិទ្ធិលើទ្រព្យសម្បត្តិស្មើគ្នានឹងបុរស ទាំងនៅក្នុងពេលអាពាហ៍ពិពាហ៍ ទាំងនៅក្រោយពេលលែងលះ។ សព្វថ្ងៃនេះ ច្បាប់អន្តរជាតិក៏ចែងទទួលស្គាល់ដូចគ្នាច្បាប់កម្ពុជាដែរថា « ស្ត្រី និងបុរសទទួលបានសិទ្ធិលើទ្រព្យសម្បត្តិស្មើគ្នា ទាំងក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ និងទាំងក្រោយពេលលែងលះ »។[62]

ដូចគ្នានឹងច្បាប់ស្តីពីការលែងលះគ្នា នៅប្រទេសដ៏ទៃទៀតដែរ ច្បាប់កម្ពុជាចែងថា ទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ នឹងត្រូវបែងចែកនៅពេលលែងលះគ្នា។ ច្បាប់ខ្មែរផ្តល់ឱ្យវិធី៣ផ្សេងគ្នាសម្រាប់បែងចែកទ្រព្យសម្បត្តិ។ ទី១- ការបែងចែកទៅតាម ខ ចែងនៅក្នុងកិច្ចសន្យាដែលបានចុះកិច្ចព្រមព្រៀងជាមួយគ្នា នៅមុនពេល ឬនៅក្រោយពេលរៀបអាពាហ៍ពិពាហ៍ ទី២- ការបែងចែកទៅតាមការព្រមព្រៀងរបស់ភាគី និង ទី៣- ការបែងចែកទៅតាមសេចក្តីសម្រេចរបស់តុលាការ។

[61] សៀវភៅនីតិរដ្ឋប្បវេណី, ភាគ២ អាពាហ៍ពិពាហ៍ និង គ្រួសារ, ២០២៣, ទំព័រទី២៥, បណ្ឌិត ទេប សុខ។

[62] អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ មាត្រា ១៥(២), ១៦(១)(គ) និង(ជ)។

នៅក្នុងការធ្វើសម្ភាសន៍ជាមួយចៅក្រមខ្មែរ ភាគច្រើនថ្លែងថា គេចូលចិត្តបែងចែកទ្រព្យសម្បត្តិ តាមរយៈការព្រមព្រៀងរបស់ភាគី។ នេះជាចំណុចសំខាន់ណាស់ ដែលយើងនឹងឃើញនៅខាងក្រោមនេះ កាលណាភាគីព្រមព្រៀងគ្នាអំពីការចែកទ្រព្យសម្បត្តិ ការព្រមព្រៀងគ្នានេះ ជួនកាលអាចមិនយុត្តិធម៌ចំពោះភាគីដែលមិនសូវមានអំណាច។ ចូរយើងក្រឡេកមើលវិធីទាំង៣ ដើម្បីបែងចែកទ្រព្យសម្បត្តិ ហើយធ្វើការពិចារណាថា តើវិធីណាអាចសមស្របជាងគេ។[63]

## ១.១. ការបែងចែកទៅតាមការចែងនៅក្នុងកិច្ចសន្យា

ក្រមរដ្ឋប្បវេណីថ្មី បានអនុញ្ញាតឱ្យភាគីអាចចុះកិច្ចសន្យាលើទ្រព្យសម្បត្តិមុនពេល ឬក្រោយពេលរៀបអាពាហ៍បាន ហើយការបែងចែកទ្រព្យសម្បត្តិ គឺផ្អែកតាម ខ ដែលចែងក្នុងកិច្ចសន្យានោះ។

មាត្រា៩៦៩ នៃក្រមរដ្ឋប្បវេណីចែងថា ប្ដីប្រពន្ធអាចចុះកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិនៅមុន ឬក្រោយអាពាហ៍ពិពាហ៍បាន។ ដូច្នេះ ការបែងចែកទ្រព្យសម្បត្តិ ត្រូវបែងចែកទៅតាមកិច្ចសន្យាដែលភាគីបានចុះព្រមព្រៀងគ្នា។

បញ្ហានេះ ប្រហែលជាមានភាពងាយស្រួលក្នុងការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះគ្នា ដោយសារតែភាគីបានព្រមព្រៀងគ្នាចុះកិច្ចសន្យាជាមុនរួចហើយ ហើយពួកគេអាចបែងចែកទ្រព្យសម្បត្តិផ្អែកទៅតាមកិច្ចសន្យាដែលបានចុះជាមួយគ្នានោះ។ ប៉ុន្តែក្នុងករណីមានទំនាស់គ្នាដែលគេមិនអាចបែងចែកបាន ឬខ្លឹមសារនៃកិច្ចសន្យាមិនច្បាស់លាស់ ភាគីនៅតែអាចប្ដឹងទៅតុលាការដើម្បីឱ្យធ្វើអន្តរាគមន៍បែងចែកជំនួសភាគីបាន តែចៅក្រមនឹងដោះស្រាយការបែងចែក ដោយខិតខំស្វែងរកឱ្យឃើញនូវឆន្ទៈពិតរបស់ភាគី ដែលបង្ហាញនៅក្នុងពេលចុះកិច្ចសន្យា ឬស្វែងរកឱ្យឃើញឆន្ទៈពិតរបស់ភាគីដែលមាននៅក្នុងខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិ នៅពេលភាគីបានព្រមព្រៀងចុះកិច្ចសន្យាជាមួយគ្នានោះ។[64]

## ១.២. ការបែងចែកទ្រព្យសម្បត្តិដោយការព្រមព្រៀងគ្នា

ការបែងចែកទ្រព្យសម្បត្តិ តាមការព្រមព្រៀងគ្នារបស់ភាគីនេះមានលក្ខណៈងាយស្រួលសម្រាប់ចៅក្រមក្នុងការសម្រេចសេចក្ដី។

នៅក្នុងករណីខ្លះដែលហាក់ដូចជាមានការព្រមព្រៀង ប៉ុន្តែការព្រមព្រៀងនោះ អាចមិនមែនជាការព្រមព្រៀងដោយស្ម័គ្រចិត្តពិតៗទេ។ ឧទាហរណ៍៖ ប្រសិនបើសហព័ទ្ធណាម្នាក់ត្រូវបានគេបង្ខំឱ្យ «ព្រមព្រៀង»ដោយសារការគំរាមកំហែងឬប្រើអំពើហិង្សា ការព្រមព្រៀងនោះ មិនមែនធ្វើឡើងដោយស្ម័គ្រចិត្តទេ។ ករណីស្រដៀងគ្នានេះដែរ ប្រសិនបើភាគីមួយមិនដឹងរឿងហេតុទាំងអស់ ដូចជាចំនួនទ្រព្យសម្បត្តិ ឬតម្លៃរបស់ទ្រព្យសម្បត្តិ ដែល

[63] នីតិគ្រួសា និង អាពាហ៍ពិពាហ៍, ភាគ២, បោះពុម្ពលើកទី១, ២០១៣, ទំព័រទី១ដល់ទំព័រទី៣, ឥន យឿន។

[64] នីតិគ្រួសា និង អាពាហ៍ពិពាហ៍, ភាគ២, បោះពុម្ពលើកទី១, ២០១៣, ទំព័រទី៣ដល់ទំព័រទី៤, ឥន យឿន។

កើតចេញពីការព្រមព្រៀងគ្នានេះ អាចជាការព្រមព្រៀងដែលមិនមែនជាការស្ម័គ្រចិត្តទេ។ ក្នុងករណីទាំងនេះនិងករណីផ្សេងទៀត អាចមានសំណួរថា តើតុលាការគួរចាត់ទុកថា «ការព្រមព្រៀង»បែបនេះ រវាងភាគីជាការត្រឹមត្រូវដែរឬទេ?

ឧទាហរណ៍៖

ទី១. កញ្ញា ធារី និង លោក វ៉ាត បានរៀបអាពាហ៍ពិពាហ៍នឹងគ្នា។ លោក វ៉ាត បានវាយដំ ធារី អស់រយៈពេលពីរឆ្នាំកមហើយ។ គេទាំងពីរនាក់មានម៉ូតូ មានសម្ភារៈល្អៗដាក់ក្នុងផ្ទះ និងមានប្រាក់ ៥០០០០ ដុល្លារ ដែលគេសន្សំបាន។ ទ្រព្យទាំងនេះជាទ្រព្យរួម។ លោក វ៉ាត បានប្រាប់ ធារី ថាគេនឹង វាយរឹតតែខ្លាំងទៀត បើនាងទាមទារយកប្រាក់ ៥០០០០ ដុល្លារ ហើយទាមទារយករបស់ផ្សេងៗទៀត។ ធារី បានប្រាប់តុលាការថានាងព្រមព្រៀងតាមការទាមទារបែងចែកទ្រព្យសម្បត្តិរបស់ វ៉ាត។ តើតុលាការត្រូវធ្វើដូចម្តេច?

ទី២. កញ្ញា បូផា និងលោក សុជាតិ បានរៀបអាពាហ៍ពិពាហ៍នឹងគ្នា។ កញ្ញា បូផា សុំលែងលះគ្នា។ សុជាតិ បើកបានប្រាក់បន្ថែម ១០០០០០ ដុល្លារ។ គេសម្រេចចិត្តនៅស្ងៀមហើយមិនប្រាប់ បូផា អំពីប្រាក់នេះទេ ដើម្បីកេងប្រាក់នោះទុក។ គេបែងចែងអ្វីផ្សេងៗសព្វបែបយ៉ាងដែលគេមានស្មើគ្នា។ នៅតុលាការ ក្នុងថ្ងៃបើកសវនាការលែងលះ បូផា បានដឹងអំពីប្រាក់ ១០០០០០ ដុល្លារនោះ។ បូផា បានប្តឹងតវ៉ា។ សុជាតិ និយាយថា គេបានព្រមព្រៀងគ្នារួចទៅហើយ ហើយគេត្រូវទុកប្រាក់ ១០០០០០ ដុល្លារនោះ។ តើតុលាការត្រូវធ្វើដូចម្តេច?

ក្រមរដ្ឋប្បវេណីថ្មី មិនបានចែងពីអ្វីដែលនឹងកើតមានឡើង កាលណាការព្រមព្រៀងមួយ មិនបានធ្វើឡើងដោយស្ម័គ្រចិត្ត ដោយមានការបង្ខិតបង្ខំ ឬការគំរាមកំហែង។ យ៉ាងហោចមានមធ្យោបាយ បី ដែលតុលាការអាចសម្រេចករណីខាងលើ។ ទី១-តុលាការអាចធ្វើមិនដឹងមិនឮពីបញ្ហាដែលកើតឡើងនោះ ហើយទទួលយកការព្រមព្រៀងនោះសូម្បីតែការព្រមព្រៀងផ្អែកលើការប្រើអំពើហិង្សា ឬ ការមិនដឹងរបស់មនុស្សម្នាក់ក៏ដោយ ឬ ទី២-តុលាការបដិសេធមិនយល់ព្រមលើការព្រមព្រៀងនោះ ហើយឱ្យភាគីទាំងសងខាងព្យាយាមជជែកគ្នា ដើម្បីដោះស្រាយឱ្យបានការព្រមព្រៀងដោយយុត្តិធម៌ត្រឹមត្រូវ ទី៣-តុលាការបដិសេធមិនយល់ព្រមតាមការព្រមព្រៀងនោះ ហើយតម្រូវឱ្យមានការស៊ើបអង្កេតនិងធ្វើការជំនុំជម្រះដោយត្រឹមត្រូវ។

នៅប្រទេសជាច្រើន រួមទាំងប្រទេសបារាំងនិងសហរដ្ឋអាមេរិកផង ប្រសិនបើសហព័ទ្ធមួយបានបង្ខំឱ្យសហព័ទ្ធម្ខាងទៀតព្រមព្រៀងបែងចែកទ្រព្យសម្បត្តិដោយមិនយុត្តិធម៌ តុលាការនឹងមិនទទួលយកការព្រមព្រៀងរបស់ភាគីទាំងនោះទេ។[65]

[65] នីតិគ្រួសា និង អាពាហ៍ពិពាហ៍, ភាគ១, បោះពុម្ពលើកទី២, ២០១៣, ទំព័រទី៥៨ដល់ទំព័រទី៧, ឥន យឿន។

## ១.៣. ការបែងចែកទ្រព្យសម្បត្តិដោយតុលាការ

### ១.៣.១. តួនាទីនៅក្នុងបណ្ដឹងសុំលែងលះ

នៅក្នុងរឿងលែងលះ ភាគច្រើនតែងមានបណ្ដឹងសុំបែងចែកទ្រព្យសម្បត្តិជាមួយនឹង បណ្ដឹងសុំលែងលះផងដែរ (មាត្រា៩៨០នៃក្រមរដ្ឋប្បវេណី)។ ក្នុងករណីនេះ តុលាការត្រូវសម្រេចពីការបែងចែកទ្រព្យឱ្យភាគី ប៉ុន្តែ ត្រូវពិនិត្យឱ្យបានច្បាស់ថា ភាគីបានដាក់ពាក្យសុំបែងចែកទ្រព្យដែរឬទេ ពីព្រោះបើគ្មានពាក្យសុំ តុលាការមិនអាច វិនិច្ឆ័យអំពីការបែងចែកទ្រព្យបានឡើយ។ មាន ករណីខ្លះ គូភាគីប្ដឹងសុំបែងចែកទ្រព្យក្រោយពេលលែងលះ ហើយអនុវត្តនីតិវិធីនៃរឿងក្ដីមិនមែនជាបណ្ដឹង។

នៅក្នុងសាលក្រម តុលាការអាចបង្គាប់ឱ្យផ្ដល់តាវកាលិកជាប្រាក់ ការបណ្ដេញចេញហើយ ឱ្យប្រគល់អចលនវត្ថុ ការចុះបញ្ជីផ្ទេរកម្មសិទ្ធិ ជាដើម។[66]

### ១.៣.២. គោលការណ៍សមាមាត្រនៃចំណែក និង ករណីពិសេស

ការបែងចែកទ្រព្យនៅពេលមានបណ្ដឹងសុំលែងលះ ត្រូវផ្អែកលើមាត្រា ៩៨០។ ការងារគេហកិច្ច ចាត់ទុកថា មានតម្លៃស្មើនឹងការងារដែលធ្វើក្រៅផ្ទះដែរ ។ មាត្រានេះ បានបង្ហាញឱ្យអនុវត្តតាមវិធីដូចខាងក្រោម៖

១. ការបែងចែកទ្រព្យសម្បត្តិ ដោយផ្អែកតាមការពិភាក្សារបស់ភាគីទាំងសងខាង ។

២. ក្នុងករណីដែលមិនអាចពិភាក្សាគ្នារវាងប្ដីប្រពន្ធបានទេត្រូវបែងចែកទ្រព្យសម្បត្តិ ដូចខាងក្រោម៖

- សហព័ទ្ធនីមួយៗ ត្រូវទទួលបាននូវទ្រព្យសម្បត្តិដោយឡែករបស់ខ្លួន ដូចបានកំណត់នៅក្នុងមាត្រា ៩៧២។
- ជាគោលការណ៍ ទ្រព្យសម្បត្តិរួម ត្រូវបែងចែកជាពីរចំណែកស្មើគ្នា ។
- ក្នុងករណីពិសេស និង មានការទាមទាររបស់ប្ដី ឬ ប្រពន្ធណាមួយ តុលាការ ក៏អាចបែងចែកទ្រព្យសម្បត្តិរួម ដោយពិចារណាទៅលើស្ថានភាពផ្សេងៗដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ចំពោះលទ្ធកម្មនៃ ទ្រព្យសម្បត្តិ ការថែរក្សា ឬ ការបង្កើនទ្រព្យ អំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅ នៅក្នុងពេលមាន ចំណងអាពាហពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្តនិងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគី នីមួយៗ និង ផលប្រយោជន៍របស់កូន ជាអាទិ៍។[67]

ក្នុងករណីសហព័ទ្ធមិនអាចសម្រេចលើការព្រមព្រៀងគ្នា ក្នុងការបែងចែកទ្រព្យសម្បត្តិទេ ច្បាប់បានផ្ដល់អំណាចដល់តុលាការ ដើម្បីសម្រេចបែងចែកទ្រព្យសម្បត្តិនោះ ជំនួសការព្រមព្រៀងរបស់ភាគី។

[66] សេចក្ដីពន្យល់អំពី ក្រមរដ្ឋប្បវេណី, ភាគ៣, ទំព័រទី២២

[67] សេចក្ដីពន្យល់អំពី ក្រមរដ្ឋប្បវេណី, ភាគ៣, ទំព័រទី២២

មាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី បានផ្តល់អំណាចដល់តុលាការដើម្បីសម្រេចបែងចែកទ្រព្យសម្បត្តិតាមវិធី ៣ យ៉ាងដូចតទៅ ៖

ទី១-សហព័ទ្ធទីមួយៗត្រូវទទួលបាននូវទ្រព្យសម្បត្តិដោយឡែកៈ ទ្រព្យសម្បត្តិដោយឡែក មានដូចជា៖

- ទ្រព្យសម្បត្តិដែលសហព័ទ្ធមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍។
- ទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបាន ដោយប្រទានកម្មសន្តតិកម្ម អច្ច័យទាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។
- ទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធនៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍។

ទី២-មានសិទ្ធិទទួលយកពាក់កណ្តាលនៃទ្រព្យសម្បត្តិរួមៈ បន្ថែមពីលើទ្រព្យសម្បត្តិដោយឡែក សហព័ទ្ធនីមួយៗមានសិទ្ធិទទួលយក១ ភាគ២ នៃទ្រព្យសម្បត្តិរួមដែលសហព័ទ្ធបានរកស៊ីជាមួយគ្នា។

ទី៣-ការបែងចែកទ្រព្យសម្បត្តិរួមដោយករណីពិសេសៈ ក្នុងករណីពិសេសនិងតាមសំណើររបស់សហព័ទ្ធណាមួយ តុលាការអាចសម្រេចបែងចែកទ្រព្យសម្បត្តិរួមផ្សេងពីគោលការណ៍ខាងលើបាន ដោយពិចារណាទៅលើស្ថានភាពផ្សេងៗ ដូចជាទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬ ការបង្កើនទ្រព្យក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅ នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ស្ថានភាពអាយុ ស្ថានភាពផ្លូវចិត្តនិងផ្លូវកាយ វិជ្ជាជីវៈ ស្ថានភាពប្រាក់ចំណូល លទ្ធភាពអាចធ្វើការងាររបស់សហព័ទ្ធនីមួយៗ និងផលប្រយោជន៍របស់កូនជាដើម។ ការបែងចែកក្នុងករណីពិសេសនេះ តុលាការ អាចបែងចែកទ្រព្យសម្បត្តិរួមរបស់ភាគីជូនទៅភាគីម្ខាងទៀតក្នុងបរិមាណច្រើនជាង ដោយពិចារណាទៅលើស្ថានភាពផ្សេងៗ ដែលយើងនឹងសិក្សាលម្អិតនៅខាងក្រោមនេះ។

រដ្ឋធម្មនុញ្ញបានចែងថា«ការងារនៃគេហកិច្ចត្រូវចាត់ថាមាន តម្លៃស្មើនឹងការងារក្រៅផ្ទះដែរ»។

វិធីបែងចែកទ្រព្យសម្បត្តិជាមូលដ្ឋានគេហៅថា វិធាន ឬ នីតិវិធី «ទ្រព្យសម្បត្តិរួម» វិធានឬនីតិវិធីស្តីពីទ្រព្យសម្បត្តិរួមរបស់កម្ពុជាប្រហែលជាមានមែកធាងពីច្បាប់របស់ប្រទេសបារាំង និង ច្បាប់របស់ប្រទេសជប៉ុន។ វិធានស្តីពីទ្រព្យសម្បត្តិរួម មានមូលដ្ឋានលើគំនិតដែលថា អាពាហ៍ពិពាហ៍ជាការរួមដៃគូរគ្នាទាំងប្តី ទាំងប្រពន្ធ ត្រូវធ្វើវិភាគទានស្មើគ្នា។ ដូច្នេះ នៅពេលលែងលះ ប្រពន្ធមានសិទ្ធិទទួលបានចំណែកនៃទ្រព្យសម្បត្តិរួមស្មើនឹងចំណែករបស់ប្តី។ ផ្ទុយទៅវិញនៅប្រទេសកម្ពុជាកាលពីអតីតកាល ស្ត្រីទទួលបានតែចំនួនមួយភាគបីនៃទ្រព្យសម្បត្តិរួមប៉ុណ្ណោះនៅពេលលែងលះគ្នា ហើយបុរសទទួលបានពីរភាគបី។[68]

[68] នីតិគ្រួសា និង អាពាហ៍ពិពាហ៍, ភាគ២, ទំព័រទី១០ដល់ទំព័រទី១២, បោះពុម្ពលើកទី១, ២០១៣, គន យឿន។

### ១.៣.៣. នីតិវិធីសម្រាប់ដំណើរការបែងចែកទ្រព្យសម្បត្តិដោយតុលាការ

សំណួរស្មុកស្មាញជាច្រើន អាចកើតឡើងទាក់ទងនឹងនីតិវិធីសម្រាប់បែងចែកទ្រព្យសម្បត្តិដោយតុលាការ។ ក៏ប៉ុន្តែ យើងអាចឱ្យដំណើរការចែកទ្រព្យសម្បត្តិទៅជាងាយស្រួលជាងនោះ ដោយធ្វើទៅតាមដំណាក់កាលជាមូលដ្ឋាន៥យ៉ាង ដែលយើងនឹងរៀបរាប់លម្អិតដូចខាងក្រោមនេះ ៖

- ការសម្គាល់ប្រភេទនៃទ្រព្យសម្បត្តិនីមួយៗ
- ការចាត់ថ្នាក់ទ្រព្យសម្បត្តិដោយឡែកឬជាទ្រព្យសម្បត្តិរួម
- វាយតម្លៃទ្រព្យសម្បត្តិនីមួយៗ
- ទុកដោយឡែកនូវទ្រព្យសម្បត្តិផ្ទាល់របស់ភាគីនីមួយៗ
- ការចាត់ប្រភេទនៃទ្រព្យប្ដីប្រពន្ធ

នៅខាងក្រោមនៃអត្ថបទនេះ មានបែបបទខ្លះដែលអ្នកអាចប្រើក្នុងការធ្វើវិភាគអំពីការបែងចែកទ្រព្យសម្បត្តិ។

#### ក. ការសម្គាល់ប្រភេទនៃទ្រព្យសម្បត្តិនីមួយៗ

ដើម្បីយល់អំពីគោលការណ៍នៃការបែងចែកទ្រព្យសម្បត្តិ គេគួរយល់នូវនិយមន័យនៃពាក្យ "ទ្រព្យ" ឬ "ទ្រព្យសម្បត្តិ"ជាមុនសិន។ ពាក្យថា "ទ្រព្យ" ឬ "ទ្រព្យសម្បត្តិ" ត្រូវបានច្បាប់នានាក្នុងប្រទេសកម្ពុជាបានឱ្យនិយមន័យផ្សេងៗគ្នាដូចខាងក្រោមនេះ ៖

**ទ្រព្យ** សំដៅដល់ កម្មសិទ្ធិដែលមានជាអាទិ៍ ភាគហ៊ុន ឬភាគទុនក្នុងក្រុមហ៊ុនដទៃ ប័ណ្ណបំណុល ប៉ាតង់របស់ក្រុមហ៊ុនអាជីវកម្ម ទំនិញដែលជាទ្រព្យរូបីនិងអរូបី ដែលជាកម្មសិទ្ធិពិតប្រាកដនិងផ្ទាល់របស់ពាណិជ្ជករ (និយមន័យតាមច្បាប់ស្ដីពីកិច្ចសន្យាពាណិជ្ជកម្ម)។

**ទ្រព្យរូបី** សំដៅដល់ ទ្រព្យទាំងឡាយណាដែលមានរូបរាងច្បាស់លាស់ (និយមន័យតាមច្បាប់ស្ដីពីកិច្ចសន្យាពាណិជ្ជកម្ម)។

**ទ្រព្យអរូបី** សំដៅដល់ ទ្រព្យដែលត្រូវបានបង្កើតឡើងដោយសិទ្ធិ (និយមន័យតាមច្បាប់ស្ដីពីកិច្ចសន្យាពាណិជ្ជកម្ម)។

**អចលនទ្រព្យ** សំដៅដល់ ១- ដីធ្លីនិងវត្ថុជាប់នៅនឹងដី ហើយមិនអាចផ្លាស់ប្ដូរទីកន្លែងបាន ដូចជា អគារ សំណង់ ដំណាំ រុក្ខជាតិ។ល។ ២- សិទ្ធិប្រត្យក្ស ឬសិទ្ធិភណ្ឌិកលើអចលនវត្ថុ និងចលនវត្ថុទាំងឡាយដែលច្បាប់បានកំណត់ថាជាអចលនវត្ថុ (និយមន័យតាមក្រមរដ្ឋប្បវេណី)។

**ទ្រព្យសម្បត្តិ** សំដៅដល់ ទ្រព្យគ្រប់ប្រភេទ ទោះជាចលនវត្ថុ ឬជាអចលនវត្ថុ រូបិយ ឬអរូបិយ និងឯកសារគតិយុត្ត ឬលិខិតូបករណ៍ដែលបញ្ជាក់ពីកម្មសិទ្ធិ ឬផលប្រយោជន៍នៅក្នុងទ្រព្យសម្បត្តិនោះ (និយមន័យតាមច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ)។

**ទ្រព្យសម្បត្តិ** សំដៅដល់ ទ្រព្យគ្រប់ប្រភេទ ចលនទ្រព្យឬអចលនទ្រព្យ រូបិយឬអរូបិយ និងឯកសារ ឬឧបករណ៍គតិយុត្តដែលជាភស្តុតាងនៃកម្មសិទ្ធិ ឬអត្ថប្រយោជន៍លើទ្រព្យទាំងនេះ (និយមន័យតាមច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម)។

**ទ្រព្យសម្បត្តិ** ក្នុងន័យទូទៅ គឺសំដៅទៅលើគ្រឿងម៉ាស៊ីន យានយន្ត ឧបករណ៍ គ្រឿងសង្ហារិម សម្ភារៈការិយាល័យ លិខិតស្នាម ឯកសារ និងដីសាធារណៈ អចលនទ្រព្យសាធារណៈ សំណង់សាធារណៈ ឬហេដ្ឋារចនាសម្ពន្ធ័សាធារណៈ ដូចជាស្ពាន អគារ ព្រែក ផ្លូវ ឬវត្ថុប្រហាក់ប្រហែលគ្នានេះ (និយមន័យតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

ផ្អែកតាមនិយមន័យទាំងអស់នេះ គេអាចពិចារណានិងងាយស្រួលសម្រាប់ធ្វើចំណាត់ថ្នាក់ទ្រព្យសម្បត្តិរបស់សហព័ទ្ធ ដើម្បីបងចែកនិងជៀសវាងការភាន់ច្រលំ ឬភ្លេចការគណនាទ្រព្យសម្បត្តិ។

ដំណាក់កាលទីមួយនៃតំណើការចែកទ្រព្យសម្បត្តិ គឺត្រូវកត់សម្គាល់វត្ថុណាខ្លះនៃទ្រព្យសម្បត្តិដែលត្រូវបែងចែក។ ក្នុងករណីភាគច្រើន ការសម្គាល់ទ្រព្យសម្បត្តិអាចជាការងាយស្រួល។ មនុស្សភាគច្រើនមានរបស់របរច្រើនក្នុងគ្រួសារ។ គេអាចមានរថយន្ត និង ម៉ូតូ កង់ បំណុលដែលគេជំពាក់ជាដើម។ គ្រួសារអាចមានប្រាក់បន្តិចបន្តួច ឬមានផ្ទះ ឬមានដី។ ទាំងអស់នេះ គឺជារបស់ដែលចាំបាច់ត្រូវចែកគ្នារវាងសហព័ទ្ធនៅពេលលែងលះគ្នា។

ក្នុងករណីដ៏ទៃ ទៀត ការសម្គាល់ទ្រព្យសម្បត្តិដែលត្រូវបែងចែកគ្នា មានការពិបាកខ្លាំង។ ជួនកាលគេពិបាកនឹងកំណត់ថា អ្វីមួយជា «ទ្រព្យសម្បត្តិ» និយមន័យនៃពាក្យ «ទ្រព្យសម្បត្តិ» អាចខុសគ្នានៅក្នុងប្រទេសផ្សេងគ្នា។ លើសពីនេះទៅទៀត និយមន័យអាចផ្លាស់ប្តូរទៅតាមពេលវេលា។ ឧទាហរណ៍៖ នៅក្នុងប្រទេសមួយដែលមិនអនុញ្ញាតឱ្យបុគ្គលឯកជនមានកម្មសិទ្ធិលើដីធ្លី នោះគេគ្មានបញ្ហាត្រូវបែងចែកដីគ្នាយ៉ាងណាៗទេ នៅពេលលែងលះគ្នា។ ក្រោយមកទៀតបើប្រទេសនោះអនុញ្ញាតឱ្យមនុស្សមានកម្មសិទ្ធិលើដីធ្លី ហើយគូស្វាមីភរិយាថែមទាំងមានដីខ្លះទៀតផងនោះ ដីនោះក្លាយទៅជាចំណែកមួយនៃទ្រព្យសម្បត្តិ ដែលត្រូវបែងចែកគ្នានៅពេលលែងលះ។

ឧទាហរណ៍៖ដ៏ទៃ ទៀតកើតមាន កាលណាសេដ្ឋកិច្ចរបស់ប្រទេសមួយរឹតតែស្មុកស្មាញ។ សិទ្ធិខាងសេដ្ឋកិច្ចប្រភេទថ្មីៗ ក្រោយមកក្លាយទៅជា «ទ្រព្យសម្បត្តិ»។ ឧទាហរណ៍៖ នៅក្នុងប្រទេសចំនួនកាន់តែច្រើនឡើង បើមនុស្សម្នាក់ធ្វើការអស់ពេលច្រើនឆ្នាំឱ្យរដ្ឋាភិបាល ឬយោធា រដ្ឋាភិបាលអាចព្រមចេញប្រាក់ឱ្យមនុស្ស

នោះមួយ ចំនួនក្នុងមួយខែៗ ជារង្វាន់សម្រាប់សេវាកម្មរបស់គេ បន្ទាប់ពីគេចូលនិវត្តន៍។ ប្រាក់ចំណាយប្រចាំខែអាចមានរហូតដល់ពេលមនុស្សនោះស្លាប់ សូម្បីតែគេលែងធ្វើការឱ្យរដ្ឋាភិបាល ឬយោធាទៀតក៏ដោយ។ ប្រាក់ចំណាយនេះហៅថា «របបសោធននិវត្តន៍»។ ប្រាក់នេះចាប់ផ្តើមបើកឱ្យបន្ទាប់ពីមនុស្សនោះបានបញ្ចប់ការងាររបស់គេបន្ទាប់ពីបានបម្រើការងារអស់រយៈពេលច្រើនឆ្នាំ។ នៅប្រទេសកម្ពុជាត្រូវបម្រើការងារយ៉ាងតិច ២០ឆ្នាំឡើងទៅ ទើបទទួលបានរបបសោធននិវត្តន៍។ ប៉ុន្តែបើរយៈពេលបម្រើការងារតិចជាងនេះ រដ្ឋបើករបបសោធននិវត្តន៍ផ្តាច់ តែម្តងគត់ស្មើនឹងចំនួនឆ្នាំដែលបានបម្រើការងារ។ ក្នុងប្រទេសជាច្រើន រួមទាំងសហរដ្ឋអាមេរិកផងសិទ្ធិត្រូវទទួលបានជាប្រាក់ខែនេះ ដែលហៅថា របបសោធននិវត្តន៍ គឺជាប្រភេទថ្មីមួយនៃទ្រព្យសម្បត្តិ។ នៅពេលលែងលះគ្នា សិទ្ធិដែលត្រូវទទួលបានប្រាក់សោធននិវត្តន៍ប្រចាំខែនេះ ត្រូវតែបែងចែករវាងសហព័ទ្ធ។

ដោយគោលគំនិតអំពីទ្រព្យសម្បត្តិមានការផ្លាស់ប្តូរ ការសម្គាល់ទ្រព្យសម្បត្តិ សម្រាប់គោលបំណងនៃការលែងលះគ្នាក៏ផ្លាស់ប្តូរដែរ។

### ខ. ការចាត់ថ្នាក់ទ្រព្យសម្បត្តិដោយឡែកឬជាទ្រព្យសម្បត្តិរួម

ដំណាក់កាលទី២នៅក្នុងដំណើរការចែកទ្រព្យសម្បត្តិ គឺត្រូវចាត់ថ្នាក់ប្រភេទនៃទ្រព្យសម្បត្តិនីមួយៗ។ ប្រភេទទ្រព្យនីមួយៗត្រូវតែចាត់ប្រភេទជា«ទ្រព្យសម្បត្តិរួម» ឬ «ទ្រព្យសម្បត្តិដោយឡែក»។ នៅផ្នែកខាងដើមនៃមេរៀននេះ យើងបានបញ្ជាក់ថា ការចាត់ប្រភេទទ្រព្យសម្បត្តិ ជាទ្រព្យសម្បត្តិរួមឬទ្រព្យសម្បត្តិដោយឡែក ក្នុងកំឡុងពេលអាពាហ៍ពិពាហ៍ត្រូវប្តឹងដើម្បីលែងលះគ្នាមានពេលខ្លះពិបាកណាស់។ នៅក្នុងកំឡុងពេលអាពាហ៍ពិពាហ៍ បញ្ហាទាំងនេះមិនចោទខ្លាំងប៉ុន្មានទេ។ ក៏ប៉ុន្តែនៅពេលលែងលះគ្នា ការចាត់ប្រភេទទ្រព្យសម្បត្តិថា ជាទ្រព្យសម្បត្តិរួមឬទ្រព្យសម្បត្តិដោយឡែក នឹងមានផលប៉ះពាល់ដល់សហព័ទ្ធនីមួយៗត្រូវទទួលទ្រព្យសម្បត្តិប៉ុន្មាន ដើម្បីដោះស្រាយបញ្ហាទ្រព្យសម្បត្តិ។ ដូច្នេះ ការចាត់ប្រភេទទ្រព្យសម្បត្តិមានសារៈសំខាន់ណាស់។ ដើម្បីចាត់ថ្នាក់ប្រភេទទ្រព្យសម្បត្តិ យើងត្រូវរំលឹកឡើងវិញនូវនិយមន័យនៃទ្រព្យសម្បត្តិដោយឡែក និង ទ្រព្យសម្បត្តិរួមដែលយើងបានសិក្សាក្នុងជំពូកទី ៤ នៃសៀវភៅនីតិគ្រួសារ និងអាពាហ៍ពិពាហ៍ភាគ១។ ចូរចងចាំថា ទ្រព្យសម្បត្តិផ្ទាល់ខ្លួន គឺជាទ្រព្យសម្បត្តិណាដែលមានមុនពេលរៀបអាពាហ៍ពិពាហ៍ ឬទ្រព្យសម្បត្តិដែលសហព័ទ្ធណាម្នាក់បានទទួលជាអំណោយ ជាមរតក ឬជាអច្ច័យទាននៅកំឡុងពេលអាពាហ៍ពិពាហ៍។ ប្រសិនបើប្តីយកប្រាក់ខែទៅទិញម៉ូតូ តាមច្បាប់ខ្មែរប្តី និងប្រពន្ធជាម្ចាស់ពាក់កណ្តាលម្នាក់លើម៉ូតូនោះ សូម្បីតែម៉ូតូនោះយកប្រាក់ខែរបស់ប្តីទៅទិញក៏ដោយ។

បញ្ហាធំបំផុតក្នុងការចាត់ថ្នាក់ប្រភេទទ្រព្យសម្បត្តិ ជាទ្រព្យសម្បត្តិរួម ឬទ្រព្យសម្បត្តិដោយឡែក កើតឡើងនៅពេលដែលគូស្វាមីភរិយាបានបញ្ចូលធនធានរបស់គេជាមួយគ្នា។

ចូរពិចារណាឧទាហរណ៍៖ ដូចតទៅនេះ មុនពេលរៀបអាពាហ៍ពិពាហ៍ ប្ដីមានផ្ទះបែកបាក់មួយដែលមានតម្លៃមិនថ្លៃប៉ុន្មានទេ នៅកំឡុងពេលអាពាហ៍ពិពាហ៍ ប្ដីនិងប្រពន្ធធ្វើការយ៉ាងលំបាក ហើយប្រើប្រាស់ប្រាក់ខែរបស់គេដែលសន្សំបានមកបីឆ្នាំ ដើម្បីជួសជុលផ្ទះ ហើយរួមដៃគ្នាជួសជុលកែលម្អ ធ្វើឱ្យផ្ទះនោះកើនតម្លៃ៥ដង។ តើផ្ទះនោះនៅតែជាទ្រព្យសម្បត្តិដោយឡែក ឬក្លាយទៅជាទ្រព្យសម្បត្តិរួម?

មានវិធានបីអាចធ្វើបាន ហើយតុលាការអាចអនុវត្តបាន។ ក្នុងស្ថានការណ៍ខ្លះ តុលាការអាចចាត់ទុកតម្លៃដើមរបស់ទ្រព្យសម្បត្តិនិងកំណើនតម្លៃរបស់ទ្រព្យសម្បត្តិជាទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ប្ដី ព្រោះទ្រព្យសម្បត្តិនោះ ជារបស់ប្ដីដោយឡែកគ្រប់ពេលទាំងអស់។ក្នុងស្ថានការណ៍ដ៏ទៃទៀត តុលាការអាចចាត់ទុកទាំងតម្លៃដើមទាំងកំណើនតម្លៃនៃទ្រព្យសម្បត្តិជាទ្រព្យសម្បត្តិរួម ព្រោះប្រាក់ខែដែលបង្កើនតម្លៃផ្ទះជាទ្រព្យសម្បត្តិរួម ហើយកិច្ចប្រឹងប្រែងរួមជាវិភាគទានដ៏សមស្របដល់តម្លៃផ្ទះ ។ ទីបញ្ចប់ តុលាការអាចចាត់ទុកតម្លៃរបស់ទ្រព្យសម្បត្តិមុនពេលជួសជុល «ជាទ្រព្យសម្បត្តិដោយឡែករបស់ប្ដី» ហើយតម្លៃដែលប្ដីប្រពន្ធបន្ថែមដោយកិច្ចប្រឹងប្រែងរួមគ្នារបស់គេ «ជាទ្រព្យសម្បត្តិរួម»។ ក្នុងការអនុវត្តវិធាននេះ តុលាការដកទុកដោយឡែកឱ្យប្ដីនូវតម្លៃផ្ទះដែលជាទ្រព្យសម្បត្តិដោយឡែករបស់ប្ដី ហើយបន្ទាប់មកយកតម្លៃផ្ទះដែលកើនឡើង ដែលជាទ្រព្យសម្បត្តិរួមរបស់គេ មកបែងចែកគ្នារវាងប្ដីនិងប្រពន្ធក្នុងចំណែកពាក់កណ្ដាលម្នាក់។

**សំណួរសម្រាប់ពិភាក្សា**

ចូរយើងពិនិត្យមើលលទ្ធផលខុសៗគ្នា ដែលចេញមកពីការអនុវត្តវិធានខុសៗគ្នាទាំងនេះ។ ឧបមាថាផ្ទះមួយនោះមានតម្លៃ ១០,០០០ដុល្លារ មុនពេលជួសជុលកែលម្អ។ បន្ទាប់ពីជួសជុលរួចមកផ្ទះនោះមានតម្លៃ ៥០, ០០០ដុល្លារ។

តាមវិធានទី១-តម្លៃរបស់ផ្ទះទាំងមូលដែលជួសជុលហើយជាទ្រព្យសម្បត្តិដោយឡែក។ ដូច្នេះ តាមវិធាននេះ កាលណាទ្រព្យសម្បត្តិនេះយកទៅបែងចែកគ្នា ប្ដីនឹងទទួលផ្ទះតម្លៃ ៥០ ០០០ដុល្លាររបស់ខ្លួន។ ប្រពន្ធមិនបានទទួលអ្វីទាំងអស់។

តាមវិធានទី២-ផ្ទះនោះក្លាយទៅជាទ្រព្យសម្បត្តិរួម។ ដូច្នេះ តាមវិធាននេះ កាលណាយកផ្ទះទៅបែងចែកគ្នា សហព័ទ្ធនីមួយៗនឹងទទួលបាន ២៥ ០០០ដុល្លារម្នាក់ គឺពាក់កណ្ដាល ៥០ ០០០ដុល្លារ។

តាមវិធានទី៣-តម្លៃដែលបន្ថែមលើផ្ទះ(៤០ ០០០ដុល្លារ) ត្រូវចាត់ទុកថាជាទ្រព្យសម្បត្តិរួម។ តម្លៃដើមរបស់ផ្ទះ (១០ ០០០ដុល្លារ) ត្រូវចាត់ទុកថាជាទ្រព្យសម្បត្តិដោយឡែករបស់ប្ដី។ កាលណាផ្ទះនោះយកទៅបែងចែកគ្នា ប្ដីនឹងរក្សាទុកទ្រព្យសម្បត្តិផ្ទាល់ខ្លួន ១០ ០០០ដុល្លារ ហើយសហព័ទ្ធទាំងពីរត្រូវបែងចែកតម្លៃ ៤០០០០ ដុល្លារ ដែលបន្ថែមទៅលើផ្ទះ។ ដូច្នេះ តាមវិធានទី៣-ប្ដីទទួល ៣០០០០ដុល្លារ (១០ ០០០ដុល្លារបូក២០ ០០០ ដុល្លារ)ហើយប្រពន្ធនឹងទទួល២០ ០០០ដុល្លារ។

នៅក្នុងប្រទេសជាច្រើនទ្រព្យសម្បត្តិមួយចំណែក មានវិភាគទានរួម និងដោយឡែកលើទ្រព្យសម្បត្តិនោះ (ដូចជាផ្ទះចាស់រខេករខោក ក្នុងឧទាហរណ៍ខាងលើ ដែលទាំងប្តី ទាំងប្រពន្ធប្រឹងប្រែងធ្វើការដើម្បីជួសជុល)។ ជាការសំខាន់ណាស់ ត្រូវញែកឱ្យដាច់ពីគ្នានូវផ្នែកដែលជារបស់ផ្ទាល់ខ្លួន និងផ្នែកដែលជារបស់រួម ហើយកំណត់តម្លៃរបស់ផ្នែកនីមួយៗ។

ក្រមរដ្ឋប្បវេណីថ្មី ដែលផ្អែកលើក្រមរដ្ឋប្បវេណីប្រទេសជប៉ុន និងច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារខ្មែរចាស់ ចែងមិនច្បាស់លាស់ប៉ុន្មានទេ ត្រង់ចំណុចនេះ។ ច្បាប់នេះមិនមានវិធានច្បាស់លាស់ដើម្បីសម្រេចករណីដូចឧទាហរណ៍ខាងលើទេ។ ចៅក្រមផ្សេងៗ ប្រហែលជានឹងសម្រេចករណីទាំងនេះតាមរបៀបខុសៗគ្នា។

### គ. ការវាយតម្លៃទ្រព្យសម្បត្តិ

ដំណាក់កាលទី៣ នៃដំណើរការបែងចែកទ្រព្យសម្បត្តិ គឺវាយតម្លៃជាប្រាក់សម្រាប់ប្រភេទ នៃទ្រព្យសម្បត្តិនីមួយៗ។ «ការវាយតម្លៃ» ប្រភេទនៃទ្រព្យនីមួយៗមានន័យថា កំណត់តម្លៃសេដ្ឋកិច្ចរបស់វា។ ចាំបាច់យើងត្រូវដឹងថា ទ្រព្យសម្បត្តិមានតម្លៃប៉ុន្មានតាមតម្លៃទីផ្សារ។ បើអ្នកមិនវាយតម្លៃទ្រព្យសម្បត្តិទេ អ្នកមិនអាចបែងចែកទ្រព្យសម្បត្តិឱ្យស្មើគ្នាបានទេ។

ឧទាហរណ៍៖ បើគ្រួសារមួយមានក្របី២ និងមាន់២ វាមិនយុត្តិធម៌ទេ បើឱ្យក្របីទាំង២ទៅភាគីមួយ ហើយឱ្យមាន់២ទៅភាគីមួយទៀត។ ព្រោះសត្វក្របីវាមានតម្លៃច្រើនជាងសត្វមាន់២ក្បាល។

តម្លៃទំនិញតាមទីផ្សារត្រូវបានគណនាតាមវិធីផ្សេងៗ អាស្រ័យលើប្រភេទទ្រព្យសម្បត្តិដែលយើងចាំបាច់ត្រូវធ្វើការវាយតម្លៃ។ តម្លៃសេដ្ឋកិច្ចមិនមែនជារបស់ដូចគ្នានឹងតម្លៃសង្គម ឬតម្លៃផ្លូវចិត្ត ឬតម្លៃមនោសញ្ចេតនាទេ។ តម្លៃសេដ្ឋកិច្ច គឺចំនួនទឹកប្រាក់ ឬតម្លៃដែលអ្នកនឹងទទួលបាន បើអ្នកលក់ទ្រព្យសម្បត្តិមួយផ្នែកនោះនៅទីផ្សារ។

ឧទាហរណ៍៖ បើឪពុកឱ្យម៉ូតូថ្មីមួយទៅកូនជារង្វាន់សម្រាប់ឆ្នាំថ្មី តម្លៃសេដ្ឋកិច្ច គឺជាចំនួនទឹកប្រាក់ដែលឪពុកចេញថ្លៃទិញម៉ូតូ។ បើកូនប្រើម៉ូតូបីឆ្នាំ ហើយមិនបានថែទាំវាឱ្យល្អ នៅពេលកូននោះលក់ម៉ូតូ អ្នកទិញនឹងឱ្យតម្លៃវាទាបជាងនៅពេលទើបតែទិញថ្មី ពីព្រោះម៉ូតូចាស់ ហើយមានសភាពលក្ខណៈមិនល្អផង។ នៅពេលកូនលក់ម៉ូតូ តម្លៃរបស់វាជាចំនួនប្រាក់ដែលអ្នកទិញហ៊ានទិញតាមតម្លៃលើទីផ្សារ។[៦៩]

[៦៩] នីតិគ្រួសា និង អាពាហ៍ពិពាហ៍, ភាគ២, ទំព័រទី២០ដល់ទំព័រទី២២, បោះពុម្ពលើកទី១, ២០១៣, ឥន យឿន។

**ឃ. ការចាត់ទុកដោយឡែកនូវទ្រព្យសម្បត្តិផ្ទាល់របស់ភាគីនីមួយៗ**

ដំណាក់កាលទី៤ នៅក្នុងដំណើរការបែងចែកទ្រព្យសម្បត្តិ គឺឱ្យភាគីនីមួយៗនូវទ្រព្យសម្បត្តិផ្ទាល់ខ្លួន ឬ គេហៅថាទ្រព្យសម្បត្តិដោយឡែក។ មាត្រា៩៧២ និង មាត្រា៩៨០ នៃក្រមរដ្ឋប្បវេណីចែងថា ភាគីនីមួយៗ ត្រូវទទួលបាននូវទ្រព្យសម្បត្តិដោយឡែករៀងៗខ្លួន ដែលមានដូចជា ទ្រព្យសម្បត្តិដែលសហព័ទ្ធមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍ ទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបានដោយប្រទានកម្មសន្តតិកម្ម អច្ច័យទាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធក្នុងពេលមានចំណងអាពាហ៍ពិពាហ៍។

បន្ថែមពីលើទ្រព្យសម្បត្តិដោយឡែកនេះ ភាគីនីមួយៗត្រូវទទួលបាននូវទ្រព្យសម្បត្តិរួមពាក់កណ្តាលម្នាក់បន្ថែមទៀត។

ក្រមរដ្ឋប្បវេណីនិងច្បាប់នៃប្រទេសភាគច្រើន តម្រូវឱ្យយកទ្រព្យសម្បត្តិផ្ទាល់ខ្លួនទៅបែងចែកឱ្យភាគីនីមួយៗនៅក្នុងករណី ឬស្ថានភាពពិសេស ដែលនឹងសិក្សានៅផ្នែកខាងក្រោម។ ក្នុងករណីភាគច្រើនមិនពិបាកសម្រេចអ្វីជាទ្រព្យសម្បត្តិផ្ទាល់ខ្លួន ហើយទ្រព្យសម្បត្តិនោះជារបស់អ្នកណាទេ។ ប៉ុន្តែ ដូចដែលយើងបានពិភាក្សាខាងលើរួចមកហើយថា ជួនកាលការបែងចែកប្រភេទទ្រព្យសម្បត្តិក្លាយជាការពិបាកនិងមិនច្បាស់ថាទ្រព្យសម្បត្តិណាមួយជាទ្រព្យសម្បត្តិផ្ទាល់ខ្លួន និងទ្រព្យណាមួយជាទ្រព្យសម្បត្តិរួម ឬមានការច្របូកច្របល់ចូលគ្នាទាំងពីរ។

**ង. គោលការណ៍នៃការបែងចែកទ្រព្យសម្បត្តិរួម**

ដំណាក់កាលចុងក្រោយបំផុត នៅក្នុងដំណើរការបែងចែកទ្រព្យសម្បត្តិ គឺការបែងចែកទ្រព្យសម្បត្តិរួម។

ក្រមរដ្ឋប្បវេណីនិងច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ ចែងដូចគ្នាថាទ្រព្យសម្បត្តិរួមត្រូវចែកឱ្យស្មើលើកលែងតែក្នុងកាលៈទេសៈពិសេស។ ជាទូទៅ នីតិវិធីសម្រាប់ការបែងចែកទ្រព្យសម្បត្តិរួមគេអាចធ្វើការបែងចែកតាមវិធី ៣ យ៉ាង ដូចខាងក្រោម៖

- ការបែងចែកវត្ថុជាក់ស្តែង : ជាវិធីយកទ្រព្យសម្បត្តិមកបែងចែកគ្នាតាមការជាក់ស្តែង។
- ការបែងចែកជាតម្លៃថ្នូរ : ជាវិធីបែងចែកដោយប្រគល់វត្ថុឱ្យភាគីម្ខាងទៀតគ្រប់គ្រង ហើយតម្រូវឱ្យភាគីម្ខាងទៀតទទួលលទ្ធកម្មនោះដោយបង់ជាតម្លៃតបស្នង ដែលស្មើនឹងចំណែកដែលភាគីម្ខាងទៀតត្រូវទទួលបានមកវិញ។

- ការបែងចែកដោយប្តូរថាប្រាក់ : ជាវិធីបែងចែកប្រាក់ដែលបានមកពីការលក់ដោយបង្ខំ ហើយយកសាច់ប្រាក់សុទ្ធមកបែងចែកគ្នា។[70]

ការបែងចែកទ្រព្យសម្បត្តិឱ្យស្មើគ្នា មិនតម្រូវឱ្យមនុស្សម្នាក់ៗបានរបស់ពាក់កណ្តាលម្នាក់ទេ។ ការបែងចែកទ្រព្យសម្បត្តិឱ្យស្មើគ្នាតម្រូវឱ្យម្នាក់ៗបានតម្លៃសរុបនៃទ្រព្យសម្បត្តិពាក់កណ្តាលម្នាក់។

ឧទាហរណ៍៖ អ្នកមិនអាចពុះផ្ទះឬម៉ូតូពាក់កណ្តាលម្នាក់ទេ។ បើមានមាន់ ១០ក្បាល ប្រាក់ ២ ០០០ ដុល្លារ ហើយក្របី២ ភាគីអាចបែងចែកអ្វីៗពាក់កណ្តាលម្នាក់ ឬសហព័ទ្ធមួយអាចយកក្របី ហើយសហព័ទ្ធមួយទៀតយកប្រាក់និងមាន់ បើទ្រព្យសម្បត្តិទាំងអស់នេះមានតម្លៃស្មើគ្នា។

ផ្ទះឬដីដែលគេលក់ទាំងមូល វាមានតម្លៃខុសគ្នាពីផ្ទះឬដីដែលគេបានពុះផ្ទះឬដីពាក់កណ្តាលដើម្បីចែកគ្នា ហើយម៉ូតូក៏ដូចគ្នាផងដែរ។

### ច. ការបែងចែកទ្រព្យសម្បត្តិរួមដោយករណីពិសេស

ក្រមរដ្ឋប្បវេណីចែងថា តាមកាលៈទេសៈពិសេស ទ្រព្យសម្បត្តិអាចបែងចែកមិនបាច់ស្មើគ្នាទេ។ ត្រង់ចំណុច ២ . ខ នៃមាត្រា៩០៨ ចែងថា «តាមសំណើរបស់សហព័ទ្ធណាមួយតុលាការអាចសម្រេចបែងចែកទ្រព្យសម្បត្តិរួម ផ្សេងពីគោលការណ៍ខាងលើបាន ដោយពិចារណាទៅលើស្ថានភាពផ្សេងៗដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬការបង្កើនទ្រព្យក្នុងអំឡុងពេលអាពាហ៍ពិពាហ៍កម្រិតជីវភាពរស់នៅនៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្ត និងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់សហព័ទ្ធនីមួយៗ និងផលប្រយោជន៍របស់កូនជាដើម»។

ដើម្បីសុភមង្គលគ្រួសារ ភាគីខ្លះបានលះបង់អ្វីៗគ្រប់បែបយ៉ាងដូចជាការងារ ឋានៈតួនាទី និងឱកាសរកទ្រព្យសម្បត្តិផ្សេងៗ ដែលចៅក្រមត្រូវពិចារណានូវគោលការណ៍បែងចែកទ្រព្យសម្បត្តិ មិនត្រូវស្មើគ្នាជាមួយភាគីដែលគ្មានការលះបង់សម្រាប់គ្រួសារទេ។

ក្នុងករណីខ្លះទៀត ដើម្បីលទ្ធកម្មនៃកំណើនទ្រព្យសម្បត្តិ ភាគីបានសុខចិត្តលក់ទ្រព្យសម្បត្តិដែលជាកេរមរតកដែលឪពុកម្តាយចែកឱ្យ ដើម្បីធ្វើឱ្យមានកំណើនសេដ្ឋកិច្ចគ្រួសារ និង ទ្រព្យសម្បត្តិបន្ថែមទៀត ដូចជាការយកទៅរកស៊ី ការចូលភាគហ៊ុន ឬការបំបែកទិញអចលនទ្រព្យសម្រាប់លក់យកផលចំណេញជាដើម។ កត្តាទាំងនេះដែលតុលាការត្រូវពិចារណា អំពីគោលការណ៍បែងចែកមិនស្មើគ្នានៃទ្រព្យសម្បត្តិរួម។

[70] សេចក្តីពន្យល់អំពី ក្រមរដ្ឋប្បវេណី, ភាគ៣, ទំព័រទី២៣

ដើម្បីផលប្រយោជន៍របស់កូន អាចពិចារណាឱ្យឪពុកម្តាយដែលបានចំណែកទ្រព្យសម្បត្តិលើសពីពាក់កណ្តាល។ ជាពិសេសករណីកូនត្រូវរស់នៅជាមួយម្តាយ ហើយម្តាយមិនអាចរកការងារធ្វើបាន ឬគ្មានលទ្ធភាពដើម្បីទ្រទ្រង់ជីវភាព។

ឧទាហរណ៍៖ បើកូននៅជាមួយសហព័ទ្ធម្នាក់ មនុស្សនោះអាចត្រូវការផ្ទះដែលភាគីទាំងអស់កំពុងរស់នៅ។ បើយកកូនចេញពីផ្ទះ កូនទាំងនោះនឹងជួបប្រទះការពិបាក ជីវភាពរស់នៅ និងការថែទាំ។ នៅក្នុងបទសម្ភាសន៍ជាមួយចៅក្រមនិងស្ត្រីនានាបានឱ្យឃើញថា ជួនកាលតុលាការសុំឱ្យសហព័ទ្ធដែលយកផ្ទះ ចេញថ្លៃឱ្យសហព័ទ្ធម្នាក់ទៀត ពាក់កណ្តាលនៃតម្លៃផ្ទះ។ បើសហព័ទ្ធមិនមានប្រាក់គ្រប់គ្រាន់ដើម្បីចេញឱ្យទេ ផ្ទះនោះត្រូវតែលក់ ហើយប្រាក់ដែលបានមកពីការលក់ ត្រូវតុលាការបែងចែកឱ្យប្តីប្រពន្ធនោះ។

ការងារនៅក្រៅផ្ទះរបស់សហព័ទ្ធម្ខាង ក៏បើកឱ្យភាគីមួយទៀតដែលនៅតែផ្ទះដើម្បីថែរក្សាកូន បានទទួលទ្រព្យសម្បត្តិរួមពាក់កណ្តាលដែរ។ ឧទាហរណ៍៖ បើប្រពន្ធបានចិញ្ចឹមកូនហើយធ្វើការនៅក្នុងផ្ទះអស់ពេលជាច្រើនឆ្នាំ ចំណែកប្តីទៅធ្វើការខាងក្រៅផ្ទះ បានប្រាក់ខែ ប្រហែលជាស្ត្រីមានការពិបាកដើររកការងារធ្វើ ដែលអាចរកប្រាក់គ្រប់គ្រាន់សម្រាប់គាំទ្រខ្លួនឯងនិងចិញ្ចឹមកូន។ បើប្រពន្ធ បានទទួលទ្រព្យសម្បត្តិខ្លះច្រើនជាងប្តីប្រហែលជាមានយុត្តិធម៌ផងដែរ។

ក្រមរដ្ឋប្បវេណី បើកលទ្ធភាពឱ្យធ្វើការបែងចែកទ្រព្យសម្បត្តិរួម ដោយមានការបត់បែនផងដែរ។ ឧទាហរណ៍៖ ករណីចៅក្រមអាចបែងចែកទ្រព្យសម្បត្តិឱ្យភាគីម្ខាងទទួលបានចំណែក១/៣ ប្រសិនបើប្តីប្រពន្ធនោះទើបនឹងរៀបអាពាហ៍ពិពាហ៍រយៈពេលខ្លី ឬប្រសិនបើសហព័ទ្ធម្ខាងទៀតនោះ មិនបានចូលរួមបរិច្ចាគច្រើនចំពោះជីវភាពរស់នៅប្រចាំថ្ងៃ ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍។

ឧទាហរណ៍៖ ករណីខ្លះទៀត ចៅក្រមអាចបែងចែកទ្រព្យសម្បត្តិឱ្យភាគីម្ខាងទទួលបានចំណែក២/៣ ឬ៣/៤ ប្រសិនបើសហព័ទ្ធនោះចាស់ ឬមានពិការភាពលើរាងកាយឬស្មារតីជាដើម។

ក្រមរដ្ឋប្បវេណីថ្មី និងច្បាប់នានាមិនមានចែងថា មានកត្តាផ្សេងទៀតក្រៅពីកូន លទ្ធភាពធ្វើវិជ្ជាជីវៈស្ថានភាពពិការភាព ការលះបង់ និងផលិតកម្មដែលធ្វើឱ្យការបែងចែកទ្រព្យសម្បត្តិមិនស្មើគ្នា អាចក្លាយទៅជាការត្រឹមត្រូវនិងយុត្តិធម៌ទេ។

ឧទាហរណ៍៖ ច្បាប់មិនបានចែងថា បើសហព័ទ្ធម្នាក់ដែលបានប្រព្រឹត្តឱ្យមានកំហុស ត្រូវទទួលទ្រព្យសម្បត្តិតិចជាងពាក់កណ្តាលនោះទេ។

ចៅក្រមជាច្រើនដែលគេបានធ្វើបទសម្ភាសន៍និយាយថា គេមិនគិតដល់កំហុសទេ ក្នុងការបែងចែកទ្រព្យសម្បត្តិ ហើយនៅក្នុងក្រមរដ្ឋប្បវេណី ក៏មិនបានចែងអំពីករណីដែលសហព័ទ្ធណាម្នាក់មានកំហុសទេ។ ការមានកំហុសនេះដូចជា ការចុះចោលសហព័ទ្ធដោយគ្មានមូលហេតុត្រឹមត្រូវ ការប្រព្រឹត្តអំពើជិតទៅលើសហព័ទ្ធ

ការប្រើអំពើហិង្សាលើសហព័ទ្ធឬលើគ្រួសារជាដើម។ យោងតាមអ្នកសិក្សាខ្លះ និងតាមច្បាប់ខ្មែរមុនឆ្នាំ១៩៧៥ កំហុសជាកត្តាទាក់ទងដែលត្រូវគិតដល់ក្នុងការបែងចែកទ្រព្យសម្បត្តិ។ ឧទាហរណ៍៖ មនុស្សប្រុសដែលរត់ចោលប្រពន្ធខ្លួន បានបាត់បង់សិទ្ធិដើម្បីទទួលបានទ្រព្យសម្បត្តិរួម ឯស្ត្រីដែលផិតក្បត់ប្ដី ក៏បាត់បង់សិទ្ធិទទួលបានទ្រព្យសម្បត្តិរួមដូចគ្នាដែរ។[71]

### ១.៣.៤. អានុភាពនៃការលែងលះចំពោះទ្រព្យសម្បត្តិ

ចំពោះការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះ គឺត្រូវតែធ្វើទៅតាម គោលការណ៍នៃការព្រមព្រៀងរបស់ភាគីទាំងសងខាង ដោយយោងតាមមាត្រា ៩៨០ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី។ ផ្ទុយទៅវិញ បើពុំអាចពិភាក្សាគ្នាបានទេ គឺត្រូវតែធ្វើការបែងចែកទ្រព្យសម្បត្តិរបស់សហព័ទ្ធដោយផ្អែកទៅតាមចំណុចនីមួយៗដែលមានចែងនៅត្រង់មាត្រា៩៨០ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី ដែលរួមមាន ៖

- សហព័ទ្ធម្នាក់ៗត្រូវទទួលបាននូវទ្រព្យដោយឡែករបស់ខ្លួន។
- បន្ថែមពីលើទ្រព្យដោយឡែក សហព័ទ្ធម្នាក់ៗត្រូវទទួលបាន ១ ភាគ ២ នៃទ្រព្យសម្បត្តិរួម។

ឧទាហរណ៍៖ លោក ចិន្ដា និងលោកស្រី សុភាព បានរៀបអាពាហ៍ ពិពាហ៍ជាមួយគ្នានៅឆ្នាំ ២០០៥។ ប៉ុន្តែ នៅមុនពេលរៀបអាពាហ៍ពិពាហ៍ លោក ចិន្ដា បានទិញរថយន្តមួយគ្រឿង សម្រាប់ប្រកបរបររត់តាក់ស៊ី។ យ៉ាងណា មិញ ក្រោយពេលរៀបអាពាហ៍ពិពាហ៍ លោក ចិន្ដា នៅតែប្រើប្រាស់រថយន្តនេះ ដដែល ដើម្បីបម្រើជីវភាពគ្រួសារ ដោយទទួលបាននូវប្រាក់ចំណូលច្រើនគួរសម ចំណែកឯលោកស្រី សុភាព ជាប្រពន្ធវិញ ជាអ្នកធ្វើកិច្ចការក្នុងផ្ទះ និងមើលថែទាំកូន។ លើសពីនេះ តាមរយៈប្រាក់ចំណូលដូចខាងលើ លោក ចិន្ដា បានទិញដីក្នុងភូមិមួយកន្លែងនៅឆ្នាំ ២០០៨។ បន្ទាប់មក នៅឆ្នាំ ២០១៣ លោក ចិន្ដា និង លោកសី សុភាព បានលែងលះគ្នា។ ដូច្នេះ លោក ចិន្ដា មានសិទ្ធិយករថយន្ត ដែលជាទ្រព្យសម្បត្តិដោយឡែករបស់គាត់បាន ចំណែកឯដីនៅក្នុងភូមិវិញ ដែលជាទ្រព្យសម្បត្តិរួម គឺត្រូវបែងចែកស្មើគ្នារវាងលោក ចិន្ដា និងលោកស្រី សុភាព។

ក៏ប៉ុន្តែ បើមានករណីពិសេស និងមានការទាមទាររបស់ប្តី ឬប្រពន្ធណាម្ខាង តុលាការក៏អាចធ្វើការបែងចែកទ្រព្យសម្បត្តិរួម ដោយធ្វើការពិចារណាទៅលើស្ថានភាពផ្សេងៗដូចជា ៖ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬការបង្កើនទ្រព្យអំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅក្នុងពេលមានចំណង អាពាហ៍ពិពាហ៍ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និងផលប្រយោជន៍របស់កូន ជាអាទិ៍ (មាត្រា ៩៨០ កថាខណ្ឌទី ២ ចំណុច ខ. វាក្យ ខណ្ឌទី ២ នៃ ក្រមរដ្ឋប្បវេណី)។

[71] នីតិគ្រួសា និង អាពាហ៍ពិពាហ៍, ភាគ២, ទំព័រទី១២ដល់ទំព័រទី២៨, បោះពុម្ពលើកទី១, ២០១៣, ឥន ឧឃឿន។

ចំពោះករណីពិសេសនីមួយៗ ដែលជាមូលដ្ឋាននាំឱ្យតុលាការអាចធ្វើ ការសម្រេចសេចក្ដីធ្វើការបែងចែកទ្រព្យសម្បត្តិរួម ខុសពីការបែងចែកចំនួនពាក់កណ្ដាលម្នាក់ រួមមានដូចតទៅ ៖

- ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ

ឧទាហរណ៍៖ នារីជាប្រពន្ធធ្វើការងារទទួលបានប្រាក់ផង និង ធ្វើការងារគេហកិច្ចផង ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ ចំណែកឯបុរសជាប្ដីវិញ មិនមានការងារធ្វើទេ ហើយថែមទាំងដើរលេងល្បែងស៊ីសងយកទ្រព្យសម្បត្តិទៅចាយ វាយ ខ្ជះខ្ជាយ។ ឧបមាថា ក្រោយរៀបការរួច អ្នកទាំងពីរបានទិញម៉ូតូមួយគឿង កង់មួយគ្រឿង។ ដូច្នេះ ម៉ូតូ និង កង់នោះ គឺជាទ្រព្យសម្បត្តិរួម។ ក្នុងករណីបែបនេះ ឃើញថា នារីជាប្រពន្ធបានបរិច្ចាគច្រើនជាងបុរសជាប្ដី ក្នុងការបង្កើតឱ្យ មានទ្រព្យសម្បត្តិរួម ហេតុនេះ នារីជាប្រពន្ធគួរតែទទួលបានទព្យសម្បត្តិរួមច្រើន ជាងបុរសជាប្ដី ដូចជា ៖ ឱ្យនារីជាប្រពន្ធទទួលបានម៉ូតូ ហើយចំណែកឯបុរសជាប្ដីទទួលបានកង់។

- ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្ម (ការទទួលបាន) នូវទ្រព្យសម្បត្តិ

ឧទាហរណ៍៖ បុរសជាប្ដីបានយកទ្រព្យសម្បត្តិដោយឡែករបស់គាត់ខ្លះ រួមជាមួយនឹងប្រាក់ដែលរកបាននៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ដើម្បីទិញដីមួយកន្លែង។ ដូច្នេះ សម្រាប់ការបែងចែកដីខាងលើនេះរវាងប្ដី និង ប្រពន្ធ នៅក្នុងពេលលែងលះ តុលាការអាចឱ្យបុរសជាប្ដីទទួលបានច្រើនជាងនារីជាប្រពន្ធ។

- ការថែរក្សា ឬ ការបង្កើនទ្រព្យ

ឧទាហរណ៍៖ បុរសជាប្ដីមានសិប្បកម្មឈើមួយកន្លែង ហើយគាត់បាន ខិតខំប្រឹងប្រែងធ្វើការងារយ៉ាងខ្លាំង ដើម្បីឱ្យសិប្បកម្មនោះមានដំណើរការ ចំណែក ឯនារីជាប្រពន្ធវិញជួយលក់ដូរម្ដាយរបស់នាង ដោយមិនបានទទួលកម្រៃណា មួយឡើយ ។ នៅក្នុងករណីនេះ បុរសជាប្ដីគួរតែទទួលបានចំណែកនៃទ្រព្យសម្បត្តិរួម ច្រើនជាងប្រពន្ធ ចំពោះការបែងចែកសិប្បកម្មឈើ ដែលជាទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ។

- អំឡុងពេលអាពាហ៍ពិពាហ៍

ឧទាហរណ៍៖ បុរសជាប្ដីបានរៀបចំបើកភោជនីយដ្ឋានមួយកន្លែង មុនពេលរៀបការទៅទៀត ។ យ៉ាងណាមិញ ក្រោយពីបានរៀបការរួចហើយ ទើបភោជនីយដ្ឋាននោះចាប់ផ្ដើមដំណើរការ។ ដូច្នេះ ភោជនីយដ្ឋានគឺជាទ្រព្យសម្បត្តិរួម ហើយប្រាក់ចំណូលដែលបានមកពីអាជីវកម្មលើភោជនីយដ្ឋាននោះ ក៏ជាទ្រព្យសម្បត្តិរួមដែរ។ ឧបមាថា ក្រោយពីបានរៀបការត្រឹមតែរយៈពេល ៦ខែ អ្នកទាំងពីរក៏លែងលះគ្នាទៅវិញ ក្នុងករណីយ៉ាងនេះ នារីជាប្រពន្ធមិនគួរទទួលបាន ចំណែកស្មើនឹងបុរសជាប្ដីទេ សម្រាប់ការបែងចែកអាជីវកម្មភោជនីយដ្ឋាន និង ប្រាក់ចំណូលដូចខាងលើ។

- កម្រិតជីវភាពរស់នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍

ឧទាហរណ៍៖ នារីជាប្រពន្ធមិនមានទ្រព្យសម្បត្តិដោយឡែកទេ ហើយក៏មិនមានការងារធ្វើដែរ រីឯបុរសជាប្ដីមានទ្រព្យសម្បត្តិដោយឡែកច្រើន និងមានប្រាក់ចំណូលខ្ពស់ ដែលជាហេតុនាំឱ្យនារីជាប្រពន្ធរស់នៅក្នុងជីវភាពសំបូរបែប។ ឧបមាថា ក្រោយមក អ្នកទាំងពីរបានលែងលះពីគ្នា ដែលជាហេតុធ្វើឱ្យជីវភាព រស់នៅរបស់នារីជាប្រពន្ធ និងមានការប្រែប្រួលយ៉ាងខ្លាំង ក្នុងស្ថានភាពយ៉ាងនេះ តុលាការអាចយកកត្តានេះមកពិនិត្យពិចារណា ដើម្បីធ្វើការបែងចែកទ្រព្យ សម្បត្តិរួមឱ្យទៅនារីជាប្រពន្ធបានច្រើនជាងធម្មតា។

- អាយុ ស្ថានភាពផ្លូវចិត្ត និងផ្លូវកាយ

ឧទាហរណ៍៖ នារីជាប្រពន្ធមានវ័យចំណាស់ ហើយមានសុខភាពទន់ខ្សោយទៀត។ ហេតុនេះ នៅពេលលែងលះគ្នា តុលាការក៏អាចធ្វើការពិនិត្យ ពិចារណា ដើម្បីធ្វើការបែងចែកទ្រព្យសម្បត្តិរបស់សហព័ទ្ធទៅឱ្យនារីជាប្រពន្ធ បានច្រើនជាងធម្មតា។

- វិជ្ជាជីវៈ

ឧទាហរណ៍៖ បុរសជាប្ដី គឺជាវិចិត្រករដែលប្រើប្រាស់ឧបករណ៍គូរគំនូរ ដែលមានតម្លៃថ្លៃ។ ក្រៅពីនេះ ប្ដីប្រពន្ធទាំងពីរនាក់មិនមានទ្រព្យសម្បត្តិអ្វីផ្សេងច្រើនទេ។ យោងតាមស្ថានភាពនេះ តុលាការអាចពិចារណាធ្វើការបែងចែកឧបករណ៍គូរគំនូរឱ្យទៅប្ដី ហើយទ្រព្យសម្បត្តិផ្សេងទៀតឱ្យទៅប្រពន្ធ ដែលនៅត្រង់ចំណុចនេះនឹងនាំឱ្យប្ដីនិងទទួលបានចំណែកច្រើនជាងប្រពន្ធ។

- ប្រាក់ចំណូល

ឧទាហរណ៍៖ នារីជាប្រពន្ធមានមុខរបរជាអ្នកលក់ដូរបន្តិចបន្តួចនៅក្បែរផ្ទះ ទទួលបានប្រាក់ចំណូលតិចតួចប្រមាណ ២០ ម៉ឺនរៀល ក្នុងមួយខែ ចំណែកឯបុរសជាប្ដីវិញមានប្រាក់ខែ រហូតដល់ទៅ ២០០០ ដុល្លារក្នុងមួយថ្ងៃ។ ក្នុងករណីយ៉ាងនេះ តុលាការអាចពិចារណាធ្វើការបែងចែកទ្រព្យសម្បត្តិរួមឱ្យនារីជាប្រពន្ធ បានច្រើនជាងបុរសជាប្ដី។

- លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ

ឧទាហរណ៍៖ នារីជាប្រពន្ធបានធ្លាក់ខ្លួនពិការ ដោយសារតែគ្រោះថ្នាក់ចរាចរណ៍ និងមិនអាចរកការងារធ្វើបានឡើយ នៅក្រោយពេលលែងលះគ្នា ប្រឈមនឹងស្ថានភាពបែបនេះ តុលាការអាចពិចារណាសម្រេចធ្វើការបែងចែកទ្រព្យសម្បត្តិរួមឱ្យទៅនារីជាប្រពន្ធច្រើនជាងបុរសជាប្ដីបាន។

- ផលប្រយោជន៍របស់កូន

ឧទាហរណ៍៖ លោកស្រី កញ្ញា និងលោក សារឿន គឺជាប្ដីប្រពន្ធនឹងគ្នា ហើយបានសម្រេចចិត្តលែងលះពីគ្នា នៅឆ្នាំ២០១៣ ។ ជាក់ស្ដែង នៅក្នុងចំណាង អាពាហ៍ពិពាហ៍ ទ្រព្យសម្បត្តិរួមរបស់អ្នកទាំងពីរមាន ៖ ម៉ូតូមួយគ្រឿង (តម្លៃ ប្រហែល ៣លានរៀល) ដែលលោក សារឿន យកទៅប្រើប្រាស់ដើម្បីរត់ម៉ូតូឌុប មានគោមួយ

ក្បាល (តម្លៃ ២លានរៀល) និង ប្រាក់ចំនួន ៣លានរៀល។ ព្រមជាមួយគ្នានេះ អ្នកទាំងពីរមានកូនចំនួនពីរនាក់ជាអនីតិជន (មិនទាន់មានអាយុគ្រប់ ១៨ឆ្នាំ នៅឡើយ)។ ឧបមាថា អ្នកទាំងពីរបានព្រមព្រៀងគ្នាថា ឱ្យលោកស្រី កញ្ញា ជាម្តាយជាអ្នកចិញ្ចឹមបីបាច់ថែរក្សាកូនទាំងពីរនាក់ ក្រោយពេលលែងលះ។ នៅក្នុងករណីនេះ ដោយគិតអំពីផលប្រយោជន៍របស់កូន តុលាការអាចពិនិត្យពិចារណាសម្រេចប្រគល់ម៉ូតូមួយគ្រឿងតម្លៃប្រហែល ៣លានរៀល ឱ្យទៅលោក សារឿន និងគោមួយក្បាលតែម្លៃ ២លាន រៀល និងប្រាក់ ៣លានរៀល ឱ្យទៅ លោកស្រី កញ្ញា ជាប្រពន្ធ។ ក្នុងសម្មតិកម្មនេះ ឃើញថា ទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធត្រូវបានបែងចែកទៅឱ្យលោកស្រី កញ្ញា ដែលជាប្រពន្ធ ច្រើនជាងលោក សារឿន ជាប្តី ដោយខុសពីគោលការណ៍ដែលថា ទ្រព្យសម្បត្តិរួមត្រូវបែងចែកពាក់កណ្តាលម្នាក់រវាងសហព័ទ្ធ ។ ជាក់ស្តែង តាមស្មារតីនៃក្រមរដ្ឋប្បវេណីបាន អនុញ្ញាតឱ្យធ្វើការបែងចែកបែបនេះ ដើម្បីជាផលប្រយោជន៍របស់កូន។

ក្រៅពីករណីដូចដែលបានរៀបរាប់ខាងលើនេះ អាចនៅមានមូលហេតុផ្សេងៗទៀតដែលតុលាការអាចលើកយកមកពិចារណាបានដែរ ដើម្បីធ្វើការ បែងចែកទ្រព្យសម្បត្តិរួមខុសពីគោលការណ៍ ១ភាគ២ ដោយហេតុថា ក្រមរដ្ឋប្បវេណីបានប្រើពាក្យ "ជាអាទិ៍" ដែលពាក្យនេះសបញ្ជាក់ឱ្យឃើញថា អាចនៅមានស្ថានភាពផ្សេងៗទៀត ដែលក្រមរដ្ឋប្បវេណីមិនបានរៀបរាប់ដល់។ ជាងនេះ ទៅទៀត ចំពោះស្ថានភាពបែបណានោះ គឺយុត្តិសាស្ត្ររបស់តុលាការនាពេល អនាគតនឹងកំណត់ទៅតាមរឿងក្តីនីមួយៗ។

សូមធ្វើការកត់សម្គាល់ថា ការលែងលះអាចមានមូលហេតុបណ្តាលមក ពីការប្រើអំពើហិង្សាផ្សេងៗ។ តាមច្បាប់ ការប្រើអំពើហិង្សារវាងប្តីប្រពន្ធគឺ អំពើអនីត្យានុកូល ដែលឈានទៅដល់ការសម្រេចអំពីសំណងនៃការខូចខាតផងដែរ ។ ក្នុងអត្ថន័យនេះ ការទាមទារលែងលះ និង ការទាមទារពីសំណងនៃការខូចខាតដូចខាងលើនេះ អាចធ្វើនៅក្នុងបណ្តឹងតែមួយក៏បានដែរ ស្របតាមខ្លឹមសារ នៃមាត្រា ១១ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។

ផ្សេងពីនេះទៀត តុលាការក៏អាចសម្រេចឱ្យសហព័ទ្ធណាម្នាក់សងតម្លៃ នៃទ្រព្យសម្បត្តិដោយឡែកដែលភាគីម្ខាងបានធ្វើការបំផ្លាញ ក្នុងអំឡុងពេលមាន ចំណងអាពាហ៍ពិពាហ៍បានដែរ ។

ឧទាហរណ៍៖ ឈ្មោះ ក. និងឈ្មោះ ខ. ជាប្តីប្រពន្ធ។ ឈ្មោះ ក. បានយក ខ្សែដៃមាសរបស់ឈ្មោះ ខ. ជាប្រពន្ធ (ខ្សែដៃដែលម្តាយរបស់ឈ្មោះ ខ. បានធ្វើអំណោយឱ្យឈ្មោះ ខ.) ទៅលក់ដើម្បីយកប្រាក់ទៅលេងល្បែងដោយមិនឱ្យឈ្មោះ ខ. ដឹងឡើយ។ នៅពេលលែងលះ តុលាការអាចសម្រេចឱ្យឈ្មោះ ក. សងតម្លៃនៃ ខ្សែរដៃឱ្យឈ្មោះ ខ. វិញ ព្រោះថាខ្សែដៃនោះជាទ្រព្យដោយឡែករបស់ឈ្មោះ ខ.។[72]

[72] នីតិព្រហ្មទណ្ឌ និង គ្រួសារ, រុន ពណ្ណារិទ្ធ, ចាំង ស៊ីណាត, ២០១៧, ទំព័រទី ៣៨៩ដល់៣៩៥។

## ផ្នែកទី២ ការបែងចែកកាតព្វកិច្ចបំណុលក្រោយពេលលែងលះគ្នា

ក្រមរដ្ឋប្បវេណីបានចែងអំពីការទទួលខុសត្រូវដោយសាមគ្គីភាពចំពោះកាតព្វកិច្ច ដែលភាគីបានធ្វើក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ដោយប្តីប្រពន្ធត្រូវទទួលខុសត្រូវដោយសាមគ្គីភាព ចំពោះកាតព្វកិច្ច និងករណីយកិច្ចផ្សេងៗទៀត ដែលប្តីឬប្រពន្ធទាំងសងខាងបានព្រមព្រៀងតាមលិខិតជាលាយលក្ខណ៍អក្សរជាមួយម្ចាស់បំណុលនៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ឬ កាតព្វកិច្ច និងករណីយកិច្ចផ្សេងៗទៀត ដែលប្តី ឬ ប្រពន្ធណាម្ខាងបានទទួលបន្ទុក ដោយមានការយល់ព្រមតាមលិខិតជាលាយលក្ខណ៍អក្សរ ពីប្រពន្ធឬប្តីម្ខាងទៀតនៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។[73]

តែទោះយ៉ាងណាក្តី ត្រូវតែមានសេចក្តីសម្រេចខ្លះទាក់ទងនឹងអ្នកណាជាអ្នកសងបំណុលនៅពេលមានការលែងលះគ្នា។ ភាគច្រើនភាគីនីមួយៗមិនចង់ទទួលយកកាតព្វកិច្ចចំពោះការសងបំណុលទេ តែសិទ្ធិធ្វើជាម្ចាស់បំណុល ប្រហែលជាដណ្តើមគ្នាចង់បាន។

គោលការណ៍ទូទៅ ការបែងចែកការទទួលខុសត្រូវលើបំណុលដូចគ្នានឹងការបែងចែកទ្រព្យសម្បត្តិដែរ គឺអាចធ្វើដោយការព្រមព្រៀងរបស់ភាគី ឬតាមសាលក្រមរបស់តុលាការ។ ការបែងចែកបំណុល អាចធ្វើឡើងតាមពីររបៀប គឺ ទី១-ការព្រមពៀងរបស់ភាគី ឬទី២-ដោយសាលក្រមរបស់តុលាការ។

នីតិវិធី និង ដំណាក់កាលសម្រាប់បែងចែកការទទួលខុសត្រូវ ចំពោះការសងបំណុលរបស់ភាគីបន្ទាប់ពីការលែងលះគ្នា គឺស្រដៀងគ្នានឹងដំណាក់កាលក្នុងការបែងចែកទ្រព្យសម្បត្តិរបស់ភាគី នៅក្នុងពេលលែងលះគ្នាដែរ។ ដំណាក់កាលទាំងនោះគឺ ទី១-ការសម្គាល់បំណុល ទី២-ការចាត់ប្រភេទបំណុល ទី៣-ការចែករំលែកកាតព្វកិច្ចលើបំណុល។

### ២.១. ការសម្គាល់បំណុល

ដំណាក់កាលទី១ គឺត្រូវសម្គាល់បំណុល។ ជាការសំខាន់ត្រូវរកឱ្យឃើញចំពោះករណីដូចតទៅ៖ ទី១-អ្នកណាជាអ្នកជំពាក់បំណុល ទី២-គោលបំណងនៃការជំពាក់បំណុល ទី៣-បំណុលនោះជំពាក់ពីពេលណា ទី៤-ទឹកប្រាក់បំណុលដំបូងនិងទឹកប្រាក់ដែលនៅជំពាក់នៅឡើយ ទី៥-ឯកសារភស្តុតាងដែលបញ្ជាក់ពីបំណុល និង ទី៦-ប្រភពនៃមូលនិធិសម្រាប់ការសងបំណុលទៅវិញមួយភាគ ដែលបានកើតឡើងក្នុងពេលមានចំណងអាពាហ៍ពិពាហ៍។ ក្រោយពីបានដឹងរឿងហេតុសម្រាប់សម្គាល់អំពីមូលហេតុនៃការជំពាក់បំណុលគ្រប់សព្វហើយ ដំណាក់កាលតទៅ គឺត្រូវចាត់ប្រភេទបំណុល។[74]

---

[73] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៧៥។

[74] នីតិគ្រួសា និង អាពាហ៍ពិពាហ៍, ភាគ ២, ទំព័ទី២៩ដល់ទំព័ទី៣០, បោះពុម្ពលើកទី២, ២០១៣, ឥន យឿន។

## ២.២. ការចាត់ប្រភេទបំណុល

### ក. បំណុលផ្ទាល់ខ្លួន

បំណុលដែលសហព័ទ្ធម្នាក់បានជាប់ជំពាក់មុនពេលរៀបអាពាហ៍ពិពាហ៍ ជាទូទៅជាបំណុលផ្ទាល់របស់សហព័ទ្ធនោះទេ។ ប៉ុន្តែក្នុងករណីខ្លះទៀត ទោះបីនៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ក្តី ប៉ុន្តែសហព័ទ្ធម្ខាងបានជំពាក់បំណុលគេតែម្នាក់ឯង ដោយមិនឱ្យសហព័ទ្ធម្ខាងទៀតដឹង ឬការខ្ចីបំណុលនោះដើម្បីតែផលប្រយោជន៍ផ្ទាល់ខ្លួន ឬការខ្ចីដើម្បីលេងល្បែងស៊ីសង ដូច្នេះបំណុលនោះក៏ជាបំណុលផ្ទាល់ខ្លួន មិនពាក់ព័ន្ធដល់ការទទួលខុសត្រូវរបស់សហព័ទ្ធម្ខាងទៀតទេ។

### ខ. បំណុលរួម

ប្រសិនបើបំណុលមួយជាប់ជំពាក់គេ នៅពេលមានចំណងអាពាហ៍ពិពាហ៍ បំណុលនោះជាកាតព្វកិច្ចរួមៈ ទី១-សហព័ទ្ធទាំងពីរព្រមព្រៀងទាំងអស់គ្នាចំពោះបំណុលនោះ ឬ ទី២-សហព័ទ្ធមួយព្រមព្រៀងជាមួយម្ចាស់បំណុល ដោយមានការយល់ព្រមពីសហព័ទ្ធមួយទៀត ដោយមានលិខិតជាលាយលក្ខណ៍អក្សរ។ ក្នុងករណីនីមួយៗសហព័ទ្ធទាំងពីរមានការទទួលខុសត្រូវរួមគ្នាដើម្បីសងបំណុល។

គេមិនដឹងច្បាស់ថា តើតុលាការនឹងសម្រេចយ៉ាងណានៅពេលដឹងថា សហព័ទ្ធមួយបាន«យល់ព្រម» ឬ «មិនយល់ព្រម» ដែលមិនបានសរសេរជាលាយលក្ខណ៍អក្សរ ពីព្រោះតាមមាត្រា ៩៧៥ ត្រង់ចំណុច ខ នៃក្រមរដ្ឋប្បវេណីចែងតម្រូវថា ការយល់ព្រមលើបំណុលពីភាគីម្ខាងទៀត ត្រូវមានភស្តុតាងជាលាយលក្ខណ៍អក្សរ។ ក្នុងការរស់នៅជាក់ស្តែងភាគច្រើនសហព័ទ្ធម្ខាង ផ្តល់ការយល់ព្រមមិនមានធ្វើជាលិខិតជាលាយលក្ខណ៍អក្សរ។

ស្ថានការណ៍ពិបាកមួយកើតមានឡើងក្នុងករណីខ្លះ នៅពេលដែលភាគីបានបំបែកលំនៅ ហើយរងចាំអស់រយៈពេលច្រើនខែឆ្នាំ ដើម្បីតុលាការសម្រេចឱ្យលែងលះគ្នា។ សហព័ទ្ធមួយអាចជំពាក់បំណុលគេក្នុងអំឡុងពេលដែលសហព័ទ្ធមួយទៀតអវត្តមាន។ ក្នុងករណីនោះសហព័ទ្ធដែលអវត្តមានអាចបដិសេធថា បំណុលមិនមែនជាកាតព្វកិច្ចរួមទេ។ ក្រមរដ្ឋប្បវេណីមិនបាននិយាយថា អ្វីត្រូវកើតឡើងក្នុងករណីបែបនេះទេ ប៉ុន្តែយោងតាមការពិសោធន៍ក្នុងប្រទេសដ៏ទៃទៀត វាទំនងជាតុលាការនិយាយថា បំណុលនោះជាបំណុលរួម បើគេយកវាមកប្រើប្រាស់សម្រាប់គ្រួសារ ក៏ដូចជាសម្រាប់ថែទាំកូន ឬជួសជុលផ្ទះ ឬការទិញសម្ភារៈដាក់ផ្ទះ។ ប៉ុន្តែតុលាការនឹងសម្រេចថាជាបំណុលផ្ទាល់ខ្លួន ប្រសិនបើប្រាក់នោះយកមកប្រើប្រាស់ប្រយោជន៍ផ្ទាល់ខ្លួនរបស់សហព័ទ្ធម្ខាង។[75]

---

[75] នីតិគ្រួសា និង អាពាហ៍ពិពាហ៍, ភាគ ២, ទំព័រទី៣០ដល់ទំព័រទី៣៣, បោះពុម្ពលើកទី២, ២០១៣, ឥន យឿន។

### ២.៣. ការសងបំណុលមុនសម្រេចបែងចែកទ្រព្យសម្បត្តិ

បន្ទាប់ពីតុលាការបានសម្គាល់ និង ធ្វើការចាត់ថ្នាក់ប្រភេទបំណុលរួម ឬ បំណុលផ្ទាល់ខ្លួនហើយ តុលាការអាចសម្រេចឱ្យសងបំណុលទៅម្ចាស់បំណុលជាមុនសិន រួចហើយទើបសម្រេចបែងចែកទ្រព្យសម្បត្តិដែលនៅសេសសល់ជាក្រោយ ដោយធ្វើការបែងចែកគ្នាតាមក្រោយតាមគោលការណ៍ ដូចដែលបានរៀបរាប់ខាងលើអំពីការបែងចែកទ្រព្យសម្បត្តិ។

### ២.៤. ការចែករំលែកភាតព្វកិច្ចលើបំណុល

ក្នុងករណីខ្លះ គេមិនអាចបែងចែកបំណុលបាន នៅមុនពេលសម្រេចឱ្យមានការលែងលះគ្នាបានទេ គឺបែងចែកការទទួលខុសត្រូវលើបំណុលទៅឱ្យប្តីប្រពន្ធនៅក្រោយពេលលែងលះគ្នា។ បន្ទាប់ពីបានសម្គាល់និងចាត់ថ្នាក់ប្រភេទបំណុលរួម ឬ បំណុលផ្ទាល់ខ្លួនរួចមកហើយតុលាការ (ឬភាគីតាមការព្រមព្រៀងរបស់ភាគី) ត្រូវសម្រេចថា អ្នកណាជាអ្នកទទួលខុសត្រូវចំពោះការសងបំណុល។ ដូចគ្នាទៅនឹងករណី ដែលភាគីនីមួយៗមានសិទ្ធិទទួលទ្រព្យសម្បត្តិផ្ទាល់ខ្លួនដែរសហព័ទ្ធនីមួយៗ ទំនងហាក់ដូចជាមានកាតព្វកិច្ចត្រូវសងបំណុលផ្ទាល់ខ្លួនរបស់ខ្លួន។ គូរស្វាមីភរិយាទំនងជាត្រូវបែងចែកបំណុលរួមឱ្យស្មើគ្នា ដូចគ្នានឹងគោលការណ៍នៃការបែងចែកទ្រព្យសម្បត្តិរួម។

ក៏ប៉ុន្តែក្នុងករណីខ្លះ កាលៈទេសៈពិសេសដែលចាត់ទុកការបែងចែកទ្រព្យសម្បត្តិរួមមិនស្មើគ្នា ជាការត្រឹមត្រូវតាមមាត្រា ៩៧៦ នៃក្រមរដ្ឋប្បវេណី ហើយក៏ដូចគ្នាផងដែរនឹងការចាត់ទុកការបែកចែកបំណុលរួមមិនស្មើគ្នា ជាការត្រឹមត្រូវដែរដោយពិចារណាទៅលើស្ថានភាពផ្សេងៗទៀត។[76]

[76] នីតិគ្រួសា និង អាពាហ៍ពិពាហ៍, ភាគ ២, ទំព័ទី៣៤ដល់ទំព័ទី៣៥, បោះពុម្ពលើកទី២, ២០១៣, ឥន យឿន។

# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សាស្រាវជ្រាវប្រធានបទខាងលើមក យើងខ្ញុំអាចធ្វើការសន្និដ្ឋានបានថា ប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធពិតជាមានសារៈសំខាន់ខ្លាំងណាស់។ ក្នុងការលើកយកមកសិក្សា និងចែករំលែកដើម្បីអាចឱ្យប្រជពលរដ្ឋទូទៅមានការយល់ដឹងកាន់តែច្បាស់អំពីការការកំណត់អំពី សិទ្ធិក្នុងចាត់ចែង គ្រងទ្រព្យសម្បត្តិ អំពីសិទ្ធិ និងការទូទលខុសត្រូវរបស់សហព័ទ្ធ និងផលប្រយោជន៍នៃប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធ ព្រោះវាជាកិច្ចចម្បងមួយ ដែលប្ដីប្រពន្ធគប្បីគួរតែស្វែងយល់ដឹងនៅពេលពួកគេរៀបអាពាហ៍ពិពាហ៍។ ប្រសិនបើជីវិតអាពាហ៍ពិពាហ៍មួយដែលមិនសមតាមបំណងប្រាថ្នាចង់បាន ឬមានការខ្វែងគំនិតគ្នា ទៅលើរឿងអ្វីមួយ អាចឈានទៅរកនូវការលែងលះគ្នា។ នេះជាដំណាក់កាលដែលពិបាកស្មុគស្មាញរបស់ជីវិតប្ដីប្រពន្ធ ក្នុងការបែងចែកទ្រព្យសម្បត្តិប្ដីប្រពន្ធ បើសិនមិនមានភាពច្បាស់លាស់ការក្នុងគ្រប់គ្រងទ្រព្យសម្បត្តិ រវាងដៃគូប្ដីប្រពន្ធទេ គឺតែងតែមានបញ្ហាទំនាស់ជារឿយៗ ព្រោះថាការរួមរស់នៅជាមួយគ្នា កាន់តែយូរទ្រព្យសម្បត្តិដែលសហព័ទ្ធទាំងពីរមាន មិនថាមានមុន ឬក្រោយអាពាហ៍ពិពាហ៍នោះទេ គឺមានភាពច្របូកច្របល់ចូលគ្នា និងពិបាកប្រាប់ថាទ្រព្យណាជាទ្រព្យរបស់សហព័ទ្ធ ហើយទ្រព្យណាជាទ្រព្យផ្ទាល់ខ្លួនរបស់ប្ដី ឬ ជាទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ប្រពន្ធ។ ហេតុនេះហើយទើបគេឃើញនៅក្នុងក្រមរដ្ឋប្បវេណី ក៏ដូចគ្នានៅក្នុងច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ បានកំណត់ប្រភេទនៃទ្រព្យសម្បត្តិរបស់សហព័ទ្ធបានយ៉ាងច្បាស់លាស់ដោយទ្រព្យសម្បត្តិនោះ បានបែងចែកជាពីរ គឺទ្រព្យសម្បត្តិរួម និង ទ្រព្យដោយឡែក។ គេបានកំណត់ថាទ្រព្យសម្បត្តិដោយឡែក ជាទ្រព្យសម្បត្តិដែលសហព័ទ្ធទាំងពីរមានមុនពេលរៀបអាពាហ៍ពិពាហ៍និងទ្រព្យដែលសហព័ទ្ធទទួលបានពីប្រទានកម្ម សន្តតិកម្ម ឬ អច្ច័យទាន នៅក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ ព្រមទាំងទ្រព្យសម្បត្តិដែលជាតម្លៃតប ដែលកើតចេញពីការចាត់ចែងទ្រព្យសម្បត្តិដោយឡែករៀងៗខ្លួនរបស់សហព័ទ្ធ។ រីឯទ្រព្យសម្បត្តិរួមវិញ ជាទ្រព្យសម្បត្តិទាំងឡាយដែលសហព័ទ្ធទាំងពីរ ឬក៏តែម្ខាងរកបាន និងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ លើកលែងតែទ្រព្យដែលមានកំណត់នៅក្នុងទ្រព្យសម្បត្តិដោយឡែក។ ទាំងនេះហើយដែលជាការកំណត់ឱ្យបានជាក់លាក់ច្បាស់លាស់នៃទ្រព្យសម្បត្តិរវាងសហព័ទ្ធឱ្យមានភាពត្រឹមត្រូវ និងគ្មានការឈ្លោះទាស់ទែងគ្នា នៅពេលចំណងអាពាហ៍ពិពាហ៍ត្រូវបានរំលាយផងដែរ។

នៅពេលដែលប្ដីប្រពន្ធបាធ្វើការកំណត់អំពីប្រភេទនៃទ្រព្យសម្បត្តិរួចហើយ ថាទ្រព្យសម្បត្តិណាជាទ្រព្យរួមរបស់សហព័ទ្ធ និងទ្រព្យសម្បត្តិណាជាទ្រព្យផ្ទាល់ខ្លួនរបស់ហព័ទ្ធម្នាក់ៗ។ ជាក់ស្ដែង នៅពេលមានការទាមទារឱ្យមាននូវការបែងចែកទ្រព្យសម្បត្តិ ខ្ញុំសង្កេតឃើញថាប្ដីប្រពន្ធមានផលវិបាកនៅក្នុងការបែងចែកទ្រព្យសម្បត្តិរួមឱ្យមានភាពត្រឹមត្រូវ និងយុត្តិធម៌។ ដូចនេះនៅក្នុងក្រមរដ្ឋប្បវេណីក៏បានកំណត់ពីការចាត់ចែង ឬបែងចែកទ្រព្យនោះដូចគ្នាដោយបានធ្វើការកំណត់ច្បាស់លាស់ថា ប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធអាចធ្វើការបែងចែកតាមការកំណត់របស់ច្បាប់ ឬ តាមកិច្ចសន្យាប្ដីប្រពន្ធ។ ជាមួយគ្នានេះដែរ ប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធតាមកិច្ចសន្យានេះ គេធ្វើឡើងក្នុងគោលបំណងដើម្បីការពារសិទ្ធិរបស់ភាគីដែលជាសហព័ទ្ធ និងទប់ស្កាត់ជាមុនមិនឱ្យមានការកែប្រែផ្លូវច្បាប់ និងស្ថានភាពជាក់ស្ដែង ព្រមទាំងកំណត់ឱ្យបានច្បាស់លាស់អំពីទំនាក់ទំនងទ្រព្យ

សម្បត្តិប្តីប្រពន្ធ និងចងភ្ជាប់នូវចំណងកាតព្វកិច្ចប្តីប្រពន្ធក្នុងតម្រូវការគ្រួសារ និងបង្ការនៅភាពស្មុគស្មាញក្នុងការធ្វើបំណែងចែកទ្រព្យសម្បត្តិ នៅពេលដែលសហព័ទ្ធបញ្ចប់កិច្ចសន្យាអាពាហ៍ពាពិពាហ៍ផងដែរ។ ចំពោះសារៈសំខាន់ផ្សេងៗ ទៀតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះ មានដូចជា ការពារផលប្រយោជន៍របស់សហព័ទ្ធ កំណត់លើទំនាក់ទំនងកាតព្វកិច្ច និងសិទ្ធិលើបំណុល កំណត់ពីសិទ្ធិគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិ សម្រួលនីតិវិធីដោះស្រាយរបស់តុលាការ។ នៅក្នុងទំនាក់ទំនងជាក់ស្តែងរបស់ប្តីប្រពន្ធមានលក្ខណៈច្រើនបែបច្រើនយ៉ាង ហើយប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យានេះ បានផ្តល់លទ្ធភាពឱ្យប្តីប្រពន្ធនូវ ជម្រើសដែលមានលក្ខណៈបត់បែនសមស្របទៅតាមភាពចាំបាច់របស់ប្តីប្រពន្ធជាក់លាក់។ ដូច្នេះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះ ក៏មានអានុភាពសម្របសម្រួលការពិភាក្សាអំពីអនាគតរបស់ប្តីប្រពន្ធផងដែរ។ ជាងនេះទៅទៀត កិច្ចសន្យាទ្រព្យសម្បត្តិតាមកិច្ចសន្យា មានលក្ខណៈពិសេស ពីព្រោះអានុភាពនៃកិច្ចសន្យានេះអាច យកមកតតាំងជាមួយតតិយជនបាន។ ម្យ៉ាងវិញទៀត ដើម្បីបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះ គឺត្រូវគោរពតាមលក្ខខណ្ឌពីរ គឺ លក្ខខណ្ឌគ្រឹះ និង លក្ខខណ្ឌទម្រង់។ ចំពោះលក្ខខណ្ឌគ្រឹះ ឃើញថាមានបួនចំណុចសំខាន់ៗទៀតដែលសហព័ទ្ធត្រូវមាន ទីមួយ កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ទីពីរ ការព្រមព្រៀងក្នុងការបង្ហាញឆន្ទៈ ទីបី សមត្ថភាពរបស់ភាគី(សហព័ទ្ធ) និងទីបួន កម្មវត្ថុនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។ រីឯលក្ខខណ្ឌទម្រង់វិញ គឺជា លក្ខខណ្ឌចាំបាច់នៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះ ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយសារតែកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះនាំឱ្យមានឥទ្ធិពលយ៉ាងខ្លាំងទៅលើទំនាក់ទំនងសិទ្ធិ និងករណីយកិច្ចលើទ្រព្យសម្បត្តិរវាងប្តីប្រពន្ធ។ ហើយដើម្បីឱ្យកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធមានអនុភាពបាន លុះត្រាតែកិច្ចសន្យានេះ ត្រូវទៅចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ នៅនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី នៃក្រសួងយុត្តិធម៌ ដែលជាស្ថាប័នមានសមត្ថកិច្ចលើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។ មិនតែប៉ុណ្ណោះ កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះ អាចធ្វើការកែប្រែ ផ្លាស់ប្តូរ និងលុបចោលបានទៅតាមការព្រមព្រៀងគ្នារវាងសហព័ទ្ធទាំងពីរ ឬដោយមូលហេតុផ្សេងៗដូចមានចែងនៅក្នុងប្រកាសរបស់ក្រសួងយុត្តិធម៌ ប្រកាសស្តីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។ រីឯប្តីប្រពន្ធអនីតិសង្វាស មិនអាចចុះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដែលមានចែងក្នុងក្រមរដ្ឋប្បវេណីបានទេ ដោយសារតែប្តីប្រពន្ធអនីតិសង្វាស មិនបានបំពេញលក្ខខណ្ឌជាប្តីប្រពន្ធស្របច្បាប់ (មិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នា)។ ប្តីប្រពន្ធអនីតិសង្វាសអាចធ្វើកិច្ចសន្យាចំពោះទ្រព្យសម្បត្តិរបស់ពួកគេបាន ប៉ុន្តែកិច្ចសន្យានេះមិន មែនជាកិច្ចសន្យាដែលមានចែងក្នុងក្រមរដ្ឋប្បវេណីឡើយ។

នៅពេលរំលាយចំណងអាពាហ៍ពិពាហ៍ មានអានុភាពចំពោះទ្រព្យសម្បត្តិ ដូចជា ទៅដល់ការបែងចែកទ្រព្យសម្បត្តិ និងកាតព្វកិច្ចរបស់សហព័ទ្ធ។ ការបែងចែកទ្រព្យសម្បត្តិ គឺជាទិដ្ឋភាពមួយក្នុងចំណោមផលវិបាកសំខានៗបំផុតនៃការលែងលះ ព្រោះជាទូទៅសហព័ទ្ធមិនងាយព្រមព្រៀងគ្នាលើរឿងបែងចែក និងសិទ្ធិគ្រប់គ្រងលើទ្រព្យសម្បត្តិទេ។ ច្បាប់កម្ពុជាចែងថា ទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធនឹងត្រូវបែងចែកនៅពេលលែងលះគ្នា។ ច្បាប់ខ្មែរផ្តល់ឱ្យ វិធី៣ ផ្សេងគ្នាសម្រាប់បែងចែកទ្រព្យសម្បត្តិ។ ទី១- ការបែងចែកទៅតាម ខ ចែងនៅក្នុងកិច្ចសន្យាដែលបានចុះកិច្ចព្រមព្រៀងជាមួយគ្នា នៅមុនពេលឬនៅក្រោយពេលរៀបអាពាហ៍ពិពាហ៍ ទី២- ការបែង

ចែកទៅតាមការព្រមព្រៀងរបស់ភាគី និង ទី៣- ការបែងចែកទៅតាមសេចក្ដីសម្រេចរបស់តុលាការ។ ការបែងចែកទៅតាមការចែងនៅក្នុងកិច្ចសន្យា បានន័យថាជា ការបែងចែកទ្រព្យសម្បត្តិ ទៅតាមកិច្ចសន្យាដែលភាគីបានចុះព្រមព្រៀងគ្នា។ ការបែងចែកទ្រព្យសម្បត្តិដោយការព្រមព្រៀងគ្នារបស់ភាគីនេះ មានលក្ខណៈងាយស្រួលសម្រាប់ចៅក្រមក្នុងការសម្រេចសេចក្ដី។ ប៉ុន្តែប្រសិនបើការព្រមព្រៀងនោះ មិនមែនជាការព្រមព្រៀងដោយស្ម័គ្រចិត្តពិតប្រាកដទេ តុលាការអាចសម្រេច ទី១-តុលាការអាចធ្វើមិនដឹងមិនឮពីបញ្ហាដែលកើតឡើងនោះ ហើយទទួលយកការព្រមព្រៀងនោះសូម្បីតែការព្រមព្រៀងផ្អែកលើការប្រើអំពើហិង្សា ឬ ការមិនដឹងរបស់មនុស្សម្នាក់ក៏ដោយ ឬ ទី២-តុលាការបដិសេធមិនយល់ព្រមលើការព្រមព្រៀងនោះ ហើយឱ្យភាគីទាំងសងខាងព្យាយាមជជែកគ្នា ដើម្បីដោះស្រាយឱ្យបានការព្រមព្រៀងដោយយុត្តិធម៌ត្រឹមត្រូវ ទី៣-តុលាការបដិសេធមិនយល់ព្រមតាមការព្រមព្រៀងនោះ ហើយតម្រូវឱ្យមានការស៊ើបអង្កេតនិងធ្វើការជំនុំជម្រះដោយត្រឹមត្រូវ។ ការបែងចែកទ្រព្យនៅពេលមានបណ្ដឹងសុំលែងលះ ត្រូវអនុវត្តតាមវិធីដូជា ការបែងចែកទ្រព្យសម្បត្តិ ដោយផ្អែកតាមការពិភាក្សារបស់ភាគីទាំងសងខាង ។ ហើយក្នុងករណីដែលមិនអាចពិភាក្សាគ្នារវាងប្ដីប្រពន្ធបានទេត្រូវបែងចែកទ្រព្យសម្បត្តិ ដោយសហព័ទ្ធនីមួយៗ ត្រូវទទួលបាននូវទ្រព្យសម្បត្តិដោយឡែករបស់ខ្លួន។ ជាគោលការណ៍ទ្រព្យសម្បត្តិរួម ត្រូវបែងចែកជាពីរចំណែកស្មើគ្នា ។ ប៉ុន្តែក្នុងករណីពិសេស និង មានការទាមទាររបស់ប្ដី ឬ ប្រពន្ធណាមួយ តុលាការ ក៏អាចបែងចែកទ្រព្យសម្បត្តិរួម ដោយពិចារណាទៅលើស្ថានភាពផ្សេងៗ ដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬការបង្កើនទ្រព្យ អំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅ នៅក្នុងពេលមានចំណងអាពាហពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្ត និងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគី នីមួយៗ និង ផលប្រយោជន៍របស់កូន ជាអាទិ៍។ ក្នុងករណីសហព័ទ្ធមិនអាចសម្រេចលើការព្រមព្រៀងគ្នា ក្នុងការបែងចែកទ្រព្យសម្បត្តិទេ ច្បាប់បានផ្ដល់អំណាចដល់តុលាការ ដើម្បីសម្រេចបែងចែកទ្រព្យសម្បត្តិនោះ ជំនួសការព្រមព្រៀងរបស់ភាគី។ ចំពោះការបែងចែកកាតព្វកិច្ចលើបំណុលក្រោយពេលលែងលះ ជាគោលការណ៍គេអាចធ្វើឡើងតាមពីររបៀបគឺ តាមការព្រមព្រៀងរបស់ភាគី និងដោយសាលក្រមរបស់តុលាការ។ រីឯនីតិវិធី និង ដំណាក់កាលសម្រាប់បែងចែកការទទួលខុសត្រូវចំពោះការសងបំណុលរបស់ភាគីបន្ទាប់ពីការលែងលះគ្នា គឺស្រដៀងគ្នានឹងដំណាក់កាលក្នុងការបែងចែកទ្រព្យសម្បត្តិរបស់ភាគី នៅក្នុងពេលលែងលះគ្នាដែរ។ ដំណាក់កាលទាំងនោះគឺ ទី១-ការសម្គាល់បំណុល ទី២-ការចាត់ប្រភេទបំណុល ទី៣-ការចែករំលែកកាតព្វកិច្ចលើបំណុល។

សរុបសេចក្ដីមក នៅក្នុងពេលរៀប អាពាហ៍ពិពាហ៍ ប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធដែលរួមមានប្រព័ន្ធទ្រព្យសម្បត្តិរួម និងប្រព័ន្ធទ្រព្យសម្បត្តិដោយឡែក ប៉ុន្តែប្រព័ន្ធទ្រព្យសម្បត្តិរួមត្រូវបានកំណត់និងធ្វើការ ចាត់ចែងប្រើប្រាស់ និងគ្រប់គ្រងនៅក្នុងកម្រិតនៃការសាមគ្គីភាព ការសហការគ្នា និងជួយសង្គ្រោះគ្នាទៅវិញទៅមក និងក្រោយពេលលែងលះ មានការកំណត់អំពីការបែងចែកទ្រព្យសម្បត្តិនៅក្នុងប្រព័ន្ធទ្រព្យសម្បត្តិរួម តាមច្បាប់ ឬតាមកិច្ចសន្យា ទៅឲ្យសហព័ទ្ធទាំងសងខាងទៅតាមសមាមាត្រនៃចំណែករបស់ខ្លួននៅក្នុងកិច្ចសន្យា ឬតាមច្បាប់រៀងខ្លួន។

# ឧបសម្ព័ន្ធ

# អនុសាសន៍

បន្ទាប់ពីបានសិក្សាស្រាវជ្រាវយ៉ាងលម្អិត អំពីប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធកន្លងមកយើងខ្ញុំ យល់ឃើញថា ច្បាប់បានតាក់តែងនូវកម្រងបញ្ញត្តិខាងលើ មានការគិតគូរច្បាស់លាស់អំពី សិទ្ធិ និងកាតព្វកិច្ចរបស់សហព័ទ្ធ ដើម្បីបំពេញក្នុងនាមជាប្តី ឬប្រពន្ធ និងបង្ការនូវហានិភ័យដែលអាចកើតមានឡើងនៅពេលមានបញ្ហាណាមួយ ដើម្បីបំពេញក្នុងនាមជាប្តី ឬប្រពន្ធ។ ដើម្បីឱ្យទំនាក់ទំនងទ្រព្យសម្បត្តិប្តីប្រពន្ធមានភាពត្រឹមត្រូវ គឺទាមទារឱ្យសហព័ទ្ធគោរពឱ្យបានត្រឹមត្រូវតាមនីតិវិធីច្បាប់ដែលបានបញ្ញត្តិរួចជាស្រេចទៅតាមក្រមរដ្ឋប្បវេណី។ ក៏ប៉ុន្តែ បើទោះបីច្បាប់ មានការកំណត់នូវចំណុច របស់ប្តីប្រពន្ធយ៉ាងលម្អិតបែបនេះក៏ដោយ ក៏មានប្រជាជនមួយចំនួនធំនៅតែមិនទាន់មានការយល់ដឹងអំពីច្បាប់នៅឡើយ។ យ៉ាងផ្ទុយមកវិញដើម្បីគោរពទៅតាមលក្ខខណ្ឌឱ្យបានត្រឹមត្រូវ នៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ សហព័ទ្ធក៏ត្រូវមានអាពាហ៍ពិពាហ៍ស្របតាមច្បាប់ដែរ ប្រសិនបើមិនគោរពតាមលក្ខខណ្ឌ ឬ គោលការណ៍ច្បាប់នោះទេ ទៅថ្ងៃក្រោយនាំឱ្យមានភាពស្មុគស្មាញនិងឈានដល់មានវិវាទជាក់ជាមិនខាន។ បន្ទាប់ពីបានសិក្សាឱ្យកាន់តែស៊ីជម្រៅហើយមក យើងខ្ញុំមើលឃើញនូវកង្វះខាតមួយចំនួន ដែលមាននៅក្នុងការគ្រប់គ្រង និងបែងចែកទ្រព្យសម្បត្តិប្តីប្រពន្ធនូវពុំទាន់មានវិសាលភាពធំទូលាយនៅឡើយ។ ជាក់ស្តែង ប្រជាពលរដ្ឋនៅពុំទាន់យល់ដឹង និងប្រើប្រាស់ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធនេះទេ ហើយនៅពេលដែលពួកគេមិនបានស្វែងយល់អំពីច្បាប់ លិខិតបទដ្ឋានផ្សេងៗ ដែលទាក់ទងនិងនីតិវិធីនៃការចុះបញ្ជីទ្រព្យសម្បត្តិ វានឹងមិនមានជាបញ្ហាចោទទេនៅពេលដែលពួកគេរួមរស់នៅជាមួយគ្នាយ៉ាងសុខុដុមរមនា។ ប៉ុន្តែវានឹងមានវិវាទកើតឡើងនៅពេលដែលមានសហព័ទ្ធណាម្ខាងបានបំពានលើសហព័ទ្ធម្ខាងទៀត នៅក្នុងករណីដែលផ្ទុយពីច្បាប់។ នៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន ប្រជាជនមួយភាគធំបានធ្វេសប្រហែសក្នុងការពិនិត្យ និងសិក្សាលើច្បាប់ដែលពាក់ព័ន្ធ នៅពេលដែលគេរៀបអាពាហ៍ពិពាហ៍ ឧទាហរណ៍ ការមិនចេញថ្លៃសោហ៊ុយសម្រាប់អាពាហ៍ពិពាហ៍ ការមិនមើលថែក្រុមគ្រួសារដូចជាការផ្គត់ផ្គង់នូវសម្ភារៈ ក៏ដូចជាផ្តល់ក្តីស្រឡាញ់ដល់សហព័ទ្ធរបស់ខ្លួន និងមានបញ្ហាមួយចំនួនទៀត តួយ៉ាងដូចការបែងចែកមិនស្មើភាពគ្នា ឬមិនអាចពិភាក្សាគ្នាបាន លើទ្រព្យសម្បត្តិរួម នៅពេលលែងលះ។ ហេតុដូចនេះហើយ ទើបច្បាប់ខិតខំតាក់តែងនូវចំណុចទាំងឡាយដើម្បីជៀសវាងនូវបញ្ហានានា ដែលបានរៀបរាប់ខាងលើ ប៉ុន្តែក្នុងនោះដែរក៏មានចន្លោះខ្វះខាតពីអ្នកអនុវត្តច្បាប់ក្នុងការផ្សព្វផ្សាយឱ្យមាន ភាពទូលំទូលាយជាងនេះ ដល់ប្រជាពលរដ្ឋដែលបានដឹងអំពីបញ្ញត្តិទាំងនេះ ក៏ដូចជាពុំមានលទ្ធភាពក្នុងការដឹងនូវច្បាប់ដែលពាក់ព័ន្ធទាំងនេះផងដែរ។

សម្រាប់ការលើកឡើងរបស់យើងខ្ញុំទាំងពីរ យល់ ឃើញថាគួរតែជម្រុញលើប្រព័ន្ធគ្រប់គ្រង និងបែងចែកឱ្យស្របតាមស្មារតីច្បាប់ដែលបានកំណត់ និងព្រមព្រៀងដោយស្មើភាពគ្នាទៅលើប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធគប្បីកាត់បន្ថយនូវភាពស្មុគស្មាញក្នុងសង្គម។ ជាការពិតណាស់យើងខ្ញុំសូមលើកទឹកចិត្តចំពោះគូស្វាមីភរិយា

ដែលទើបនិងរៀបអាពាហ៍ពិពាហ៍ ស្របច្បាប់ទាំងអស់ គួរតែចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ នឹងគួរតែគិតពីផលអវិជ្ជមានទៅថ្ងៃខាងមុខដែលអាចកើតមានក្នុងជីវិតអាពាហ៍ពិពាហ៍ ព្រមទាំងបានធ្វើឱ្យទំនុកចិត្តប្តីប្រពន្ធគឺមិនប៉ះពាល់ចំពោះទំនាក់ទំនងល្អរបស់ប្តី និងប្រពន្ធឡើយ។ តាមការសង្កេតឃើញជាក់ស្តែងប្តីប្រពន្ធ មួយភាគធំបានធ្វេសប្រហែសមិនអើពើនូវក្នុងការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ ពីព្រោះសហព័ទ្ធទាំងនោះ គិតថាពួកគេបានរស់នៅជាមួយគ្នាមានភាពសុខដុមរមនាហើយ ដោយមិនបានគិតថាអាចកើតមានវិវាទ កើតឡើងនៅពេលសហព័ទ្ធម្ខាងបំពានសិទ្ធិ។ ដូច្នេះហើយ យើងខ្ញុំសុំលើកយកនូវសំណូមពរដល់ រាជរដ្ឋាភិបាលនូវចំណុចដូចខាងក្រោមះ

- នាយកដ្ឋានកិច្ចការច្បាប់រដ្ឋប្បវេណី និងអគ្គវិស័យននៃក្រសួងយុត្តិធម៌ គប្បីមានយន្តការនៃការផ្សព្វផ្សាយឱ្យមានភាពទូលំទូលាយដូចជា ការផលិតវីដេអូអប់រំ ការផ្សព្វផ្សាយតាមបណ្តាញទំនាក់ទំនងសង្គម ដើម្បីអាចឱ្យប្រជាពលរដ្ឋបានឃើញបានយល់ដឹងពីភាពចាំបាច់នៃប្រព័ន្ធទ្រព្យសម្បត្តិនេះ។
- តម្រូវឱ្យមានអង្គភាពរៀបចំគ្រប់គ្រងលើប្រព័ន្ធទ្រព្យសម្បត្តិ ដែលរួមមានការចុះបញ្ជីឱ្យបានត្រឹមត្រូវឆាប់រហ័ស មិនយឺតយ៉ាវ។ ការរៀបចំលិខិតបទដ្ឋានផ្សេងៗ ដើម្បីធានាដល់ការគ្រប់គ្រង ប្រព័ន្ធទ្រព្យសម្បត្តិនេះ ជៀសវាងឱ្យមានវិវាទកើតឡើងមិនឈប់ឈរ ដោយសារតែប្រជាពលរដ្ឋ នៅពុំទាន់ប្រើប្រាស់ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធនេះនៅឡើយ។
- បង្កើតឱកាសដល់ប្រជាជន ក្នុងការយល់ដឹងបន្ថែមអំពីច្បាប់ ដែលទាក់ទងនឹងប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធខាងលើនេះតាមគ្រប់មធ្យោបាយ ដើម្បីផ្សព្វផ្សាយដល់ប្រជាជននៅតាមសមាគមន៍ មូលដ្ឋាន និងនៅតំបន់ដាច់ស្រយាល)។
- ជំរុញឱ្យមន្ត្រីអត្រានុកូលដ្ឋាន និងមន្ត្រីដែលពាក់ព័ន្ធ ព្យាយាមឱ្យយោបល់ និងណែនាំអំពីច្បាប់ដល់សហព័ទ្ធដែលទៅចុះសំបុត្រអាពាហ៍ពិពាហ៍ ពីព្រោះពួកគេអាចនឹងមិនដឹង ឬកម្រិតនៃការយល់ដឹងនៅមានកំណត់ដែលអាចបង្ករឱ្យមានវិវាទនានានៅពេលក្រោយ។
- បង្ការការផ្តល់ព័ត៌មានខុស ឬ ការឱ្យប្រឹក្សា ពិគ្រោះយោបល់ខុសពីសំណាក់មន្ត្រីមានសមត្ថកិច្ចទៅកាន់ប្រជាពលរដ្ឋ គប្បីរដ្ឋាភិបាលមានវិធានការនានាដើម្បីទប់ស្កាត់នូវបញ្ហានេះ ដែលអាចកើតមានឡើងជាយថាហេតុ។
- រដ្ឋាភិបាលគួតែពង្រីក ទីកន្លែងចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធឱ្យមាននៅតាមបណ្តាថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីឱ្យប្រជាពលរដ្ឋងាយស្រួលក្នុងការចុះបញ្ជី និង មិនពិបាកក្នុងការឡើងមកចុះបញ្ជីនៅក្រសួងយុត្តិធម៌ដោយចំណាយពេលវេលា និងថវិការច្រើនសម្រាប់អ្នកនៅខេត្តឆ្ងាយៗ។

- លើកទឹកចិត្តឱ្យប្រជាជនមានសាមគ្គីភាព ជួយសង្គ្រោះគ្នា ចេះយោគយល់អធ្យាស្រ័យគ្នា ទៅវិញទៅមកដែលស្របទៅនឹងគោលបំណងអាពាហ៍ពិពាហ៍ ដែលពួកគេគប្បីចេះពិភាក្សាគ្នាជាមុន មុនពេលសម្រេចលើកិច្ចការអ្វីមួយ។

ជាចុងក្រោយ យើងខ្ញុំទាំងពីរនាក់ដែល ជានិស្សិតជំនាញផ្នែកនីតិសាស្ត្រ យើងខ្ញុំសូមសន្យាថានឹងចែករំលែកនូវចំណេះដឹង ព្រមទាំងផ្តល់ជាប្រឹក្សា ឬ ផ្តល់ជាគំនិតជូនពួកគាត់ដែលពុំទាន់យល់ដឹងអំពីព័ត៌មាននេះ ដើម្បីឱ្យពួកគាត់កាន់តែយល់ច្បាស់ និងដោះស្រាយជាមួយដៃគូរបស់ពួកគាត់ប្រកបទៅដោយភាពត្រឹមត្រូវតាមផ្លូវច្បាប់ឥតលម្អៀង។

# ឯកសារយោង

# ឯកសារយោង


១. រដ្ឋធម្មនុញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣

២. ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧

៣. ច្បាប់ស្តីពី ការអនុវត្តក្រមរដ្ឋវេណី ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១១

៤. ច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និងគ្រួសារ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨៩

៥. ប្រកាសស្តីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ប្រកាសក្រសួង លេខ ៨១កយ/ប្រក/១៣ ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៣

៦. ប្រកាសអន្តរក្រសួង លេខ ៥៥១ សហវ.ប្រក ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០២០

៧. សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី រៀបចំដោយក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី ក្រសួងយុត្តិធម៌ ឆ្នាំ ២០១០

៨. សេចក្តីពន្យល់អំពី ក្រមរដ្ឋប្បវេណី ភាគ១-៣ ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣

៩. គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការប្រចាំក្រសួងយុត្តិធម៌(JICA) ជំនាញការផ្នែកច្បាប់៖ អ៊ីសូអ៊ីមីហា

១០. កម្រងមេរៀនដែលស្តីពីការបកស្រាយប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ របស់លោកសាស្ត្រាចារ្យច្បាប់ជប៉ុន Masayuki Tanamura

១១. ការបកស្រាយប្រព័ន្ធទ្រព្យរួមប្តីប្រពន្ធ ដោយសាស្ត្រាចារ្យហ៊ីង គីមឡេង និងឆឹង ស៊ីនៀង កាលបរិច្ឆេទ ថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ២០១៦

១២. សៀវភៅជំនួយស្មារតី នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ ដោយសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងចាំង ស៊ីណាត ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ២០១៧

១៣. សៀវភៅ នីតិគ្រួសារ និង អាពាហ៍ពិពាហ៍ (ភាគ ២ ឆ្នាំ ២០១៣ និង ភាគ ១ ឆ្នាំ២០២១) ដោយបណ្ឌិត ឥន យឿន

១៤. សៀវភៅ នីតិរដ្ឋប្បវេណី (ភាគ ២ អាពាហ៍ពិពាហ៍ និង គ្រួសារ) ដោយបណ្ឌិត ទេព សុខ ឆ្នាំ ២០២៣

១៥. លោកជំទាវ ចាន់ សុទ្ធាវី (រដ្ឋលេខាធិការក្រសួងយុត្តិធម៌), https://youtu.be/fLCbqZyfNbw

១៦. https://thimhorn.wordpress.com/2017/11/09/%E1%9E%94%E1%9F%92%E1%9E%9A%E1%9E%96%E1%9F%90%E1%9E%93%E1%9F%92%E1%9E%92%E1%9E%91%E1%9F%92%E1%9E%9A%E1%9E%96%E1%9F%92%E1%9E%99%E1%9E%9F%E1%9E%98%E1%9F%92%E1%9E%94%E1%9E%8F%E1%9F%92%E1%9E%8F%E1%9E%B7/

# ឧបសម្ព័ន្ធ

## បញ្ជីរាយនាមឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី០១៖ ទម្រង់ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ឧបសម្ព័ន្ធទី០២៖ ទម្រង់លិខិតអាពាហ៍ពិពាហ៍

ឧបសម្ព័ន្ធទី០៣៖ ទម្រង់ពាក្យសុំលែងលះដោយមានការព្រមព្រៀង

ឧបសម្ព័ន្ធទី០៤៖ ទម្រង់ពាក្យបណ្តឹងលែងលះដោយមិនមានការព្រមព្រៀង

# ឧបសម្ព័ន្ធទី០១

## ទម្រង់ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រពសម្បត្តិប្តីប្រពន្ធ

# ប្រកាស

# ស្តីពី

# នីតិវិធីនៃការចុះបញ្ជី

# កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

រៀបចំដោយ
ក្រុមការងារក្រសួងយុត្តិធម៌
និង
ទីប្រឹក្សាផ្នែកច្បាប់របស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន ( JICA)
ប្រចាំក្រសួងយុត្តិធម៌

ក្រសួងយុត្តិធម៌
បោះពុម្ពលើកទីមួយ ចំនួន ៥០០ ក្បាល
នៅរាជធានីភ្នំពេញ ខែ កុម្ភៈ ឆ្នាំ ២០១៤

# ប្រកាស

# ស្តីពី

# នីតិវិធីនៃការចុះបញ្ជី

# កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

រៀបចំដោយ
ក្រុមការងារក្រសួងយុត្តិធម៌
និង
ទីប្រឹក្សាផ្នែកច្បាប់របស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)
ប្រចាំក្រសួងយុត្តិធម៌

p

ក្រសួងយុត្តិធម៌
បោះពុម្ពលើកទីមួយ ចំនួន ៥០០ ក្បាល
នៅរាជធានីភ្នំពេញ ខែ កុម្ភៈ ឆ្នាំ ២០១៤

ប្រកាស ស្តីពី
នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ត្រូវបានបោះពុម្ព នៅរាជធានីភ្នំពេញ
ដោយគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ (ដំណាក់កាលទី ៤)
នៅក្រសួងយុត្តិធម៌ នៃព្រះរាជាណាចក្រកម្ពុជា នៅឆ្នាំ ២០១៤

គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ
គឺជាគម្រោងសហប្រតិបត្តិការបច្ចេកទេស
រវាង
ក្រសួងយុត្តិធម៌
និង
ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ចំណាប់អារម្មណ៍របស់
## ឯកឧត្តម អង្គ វង្សវឌ្ឍនា
## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំង និងមោទនភាពខ្ពស់ដោយក្រសួងយុត្តិធម៌ ក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សម្រេចបាននូវសមិទ្ធផលជាច្រើនជាបន្តបន្ទាប់រួមមានៈ បញ្ញត្តិមូលដ្ឋាន បញ្ញត្តិបន្ទាប់បន្សំ និងបញ្ញត្តិពិសេស ដែលបទប្បញ្ញត្តិទាំងនោះ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធ ទៅនឹងការរស់នៅក្នុងសង្គម និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ។

ជាមួយគ្នានេះដែរ នៅក្នុងទំនាក់ទំនងរវាង បុគ្គល និងបុគ្គល ដែលបានរៀបអាពាហ៍ពិពាហ៍ និងបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ដែលមាននូវធនធានទ្រព្យសម្បត្តិជាចលនវត្ថុក្តី ជាអចលនវត្ថុក្តី គប្បីបញ្ជាក់ឲ្យបានច្បាស់អំពីសិទ្ធិទៅលើទ្រព្យសម្បត្តិនោះ ថាតើធនធានទ្រព្យសម្បត្តិណាខ្លះជាសិទ្ធិរួម ? ហើយធនធានទ្រព្យសម្បត្តិណាខ្លះ ជាសិទ្ធិផ្តាច់មុខរបស់ភាគីណាមួយ ?

ករណីនេះ នៅប្រទេសជឿនលឿនមួយចំនួន ដើម្បីបើកឱកាសឲ្យភាគីអាចកំណត់ឲ្យបានច្បាស់លាស់នូវទំនាក់ទំនងទ្រព្យសម្បត្តិទាំងនោះ និងងាយស្រួលដល់ការដោះស្រាយវិវាទទៅលើទំនាក់ទំនងទ្រព្យសម្បត្តិ គេបានរៀបចំឲ្យមានបទប្បញ្ញត្តិ ដែលទាក់ទងទៅនឹង ការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ ។

ទស្សនៈនៃគោលគំនិត ក្នុងការកំណត់នូវទំនាក់ទំនងនៃទ្រព្យសម្បត្តិនេះ ក៏ត្រូវបានយកមកបញ្ចូលនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តកាលពីថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ហើយបានអនុវត្តកាលពីថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ កន្លងមកនេះ ។

នៅក្នុងមាត្រា ៩៦៩ នៃក្រមរដ្ឋប្បវេណីបានចែងថា ប្តីប្រពន្ធអាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិនៅមុន ឬ ក្រោយរៀបអាពាហ៍ពិពាហ៍បាន ឲ្យតែមិនផ្ទុយនឹងសិទ្ធិទាមទារអាហារកាតព្វកិច្ច និងភាគបម្រុង ។ បើប្តីប្រពន្ធមិនបានធ្វើកិច្ចសន្យាពិសេស ចំពោះទ្រព្យសម្បត្តិនោះទេ នោះត្រូវអនុលោមតាមប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ ។ p

រីឯមាត្រា ២៦ និងមាត្រា ២៧ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី បានប្រគល់សមត្ថកិច្ចឲ្យក្រសួងយុត្តិធម៌ មានសមត្ថកិច្ចលើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយក្រសួងត្រូវរៀបចំកំណត់អំពី បែបបទ និងទម្រង់ នៃការចុះបញ្ជីតាមរយៈប្រកាសរបស់ក្រសួង ។

ផ្អែកតាមបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណី និងច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី ក្រសួងយុត្តិធម៌បានបង្កើតក្រុមការងារមួយ ដោយសហការ ជាមួយជំនាញការជប៉ុននៃអង្គការ JICA ប្រចាំក្រសួងយុត្តិធម៌ ដើម្បីរៀបចំ បែបបទ និងទម្រង់ នៃការចុះបញ្ជីទ្រព្យសម្បត្តិប្ដីប្រពន្ធ ដោយប្រើប្រព័ន្ធចុះបញ្ជីដែលរៀបចំឡើងដោយប្រើក្រដាសដាក់ក្នុងក្រណ្ឌ ។

ជាមួយនឹងការអបអរសាទរនៃភាពជោគជ័យ របស់ក្រុមការងារក្នុងការរៀបចំប្រកាសនេះ ខ្ញុំក៏សូមធ្វើការវាយតម្លៃខ្ពស់ កោតសរសើរ និងសូមថ្លែងអំណរគុណ ដោយស្មោះអស់ពីចិត្ត ចំពោះស្មារតីទទួលខុសត្រូវខ្ពស់បំផុត និងការខិតខំប្រឹងប្រែង ការព្យាយាម យកអស់ពីកំលាំងកាយ និងបញ្ញាស្មារតី របស់ក្រុមការងារ និងជំនាញការជប៉ុននៃអង្គការ JICA ប្រចាំក្រសួងយុត្តិធម៌ ។ ជាពិសេស ក្រុមការងារសាស្ត្រាចារ្យជប៉ុន ដែលបានចូលរួម ផ្ដល់យោបល់ នៅក្នុងការរៀបចំ បទប្បញ្ញត្តិគតិយុត្តដ៏មានសារៈសំខាន់នេះ ហើយក៏ជាផ្នែកមួយនៃការអភិវឌ្ឍវិស័យច្បាប់ ស្របតាមគោលនយោបាយ ស្ដីពីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្ដេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ។

ជំហានបន្ទាប់ ក្រសួងយុត្តិធម៌ក៏បានកំណត់ទិសដៅឲ្យ ក្រុមការងារដែលបានរៀបចំប្រកាសនេះ ត្រូវធ្វើការបណ្ដុះបណ្ដាល និង ផ្សព្វផ្សាយប្រកាសនេះ ឲ្យបានទូលំទូលាយទៅដល់មន្ត្រីអនុវត្តច្បាប់និងប្រជាពលរដ្ឋទូទៅ ។

ក្រសួងយុត្តិធម៌មានជំនឿយ៉ាងមុតមាំថា ប្រកាសនេះនឹងក្លាយជាឧបករណ៍គតិយុត្តដ៏សំខាន់ ដែលផ្ដល់សិទ្ធិ និងបើកឱកាស ឲ្យប្ដីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ដែលមានបំណងចង់ធ្វើការចុះបញ្ជី អាចធ្វើការចុះបញ្ជី អំពីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធបាន ហើយឈានទៅដល់ការបង្កើតទំនាក់ទំនងរវាង បុរស និងស្ត្រី ឲ្យមានភាពច្បាស់លាស់ និងតម្លាភាព ពាក់ព័ន្ធនឹងបញ្ហាទ្រព្យសម្បត្តិ និងចូលរួមចំណែកក្នុងការពង្រឹងគោលការណ៍សមភាពយេនឌ័រនៅក្នុងសង្គម ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៣

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

p

**អង្គ វង្សវឌ្ឍនា**

## ប្រធានក្រុមការងារតាក់តែងច្បាប់

| | | |
|---|---|---|
| ឯកឧត្តម | **អង្គ វង្សវឌ្ឍនា** | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ |

## សមាសភាពក្រុមការងារក្រសួងយុត្តិធម៌ដែលទទួលបន្ទុកតាក់តែងប្រកាសស្តីពី "ការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ"

| | | |
|---|---|---|
| លោកជំទាវ | **ចាន់ សុធាវី** | រដ្ឋលេខាធិការនៃក្រសួងយុត្តិធម៌ (ប្រធាន) |
| ឯកឧត្តម | **យាន ស៊ីណា** | អតីតអនុរដ្ឋលេខាធិការនៃក្រសួងយុត្តិធម៌ |
| លោក | **ទិត្យ ឫទ្ធី** | ចៅក្រមនៃក្រសួងយុត្តិធម៌ |
| កញ្ញា | **ម៉ៅ តិរុណា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេសនៃក្រសួងយុត្តិធម៌ |
| លោកស្រី | **សូរ ដានី** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងយុត្តិធម៌ |
| លោក | **ទូច ថារិទ្ធ** | ប្រធាននាយកដ្ឋានកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ |
| លោក | **កែវ សេដ្ឋា** | អតីតអនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ |
| លោក | **ហុក ច័ន្ទសុវណ្ណារ៉ា** | អនុប្រធានការិយាល័យកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ |
| លោក | **អុល ធីរៈ** | អនុប្រធានការិយាល័យកិច្ចការអេយ្យការនៃក្រសួងយុត្តិធម៌ |
| កញ្ញា | **ឡាយ លីនណា** | អនុប្រធានការិយាល័យបច្ចេកទេសនៃក្រសួងយុត្តិធម៌ |
| កញ្ញា | **សួន ណារី** | មន្ត្រីគ្រប់គ្រងរដ្ឋបាលនៃក្រសួងយុត្តិធម៌ |

## ជំនាញការរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ប្រចាំក្រសួងយុត្តិធម៌

| | | |
|---|---|---|
| លោក | Issei SAKANO | អតីតទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | Hiroshi KIYOHARA | អតីតទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | Masayoshi HARADA | អតីតទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោកស្រី | Emiko KANETAKE | អតីតទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោកស្រី | Ayako TAMIYA | អតីតទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោកស្រី | Miha ISOI | ទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |

## សមាសភាពសាស្ត្រាចារ្យជប៉ុនដែលបានប្រឹក្សាយោបល់ក្នុងការរៀបចំប្រកាស

| | | |
|---|---|---|
| លោក | Akio MORISHIMA | សាស្ត្រាចារ្យកិត្តិយសនៃសាកលវិទ្យាល័យ Nagoya (ប្រធាន) |
| លោក | Ikufumi NIIMI | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Meiji |
| លោក | Michitaro URAKAWA | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Waseda |
| លោក | Kaoru KAMATA | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Waseda |
| លោក | Yutaka YAMAMOTO | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Kyoto |
| លោក | Tsuneo MATSUMOTO | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Hitotsubashi |
| លោក | Yoshihisa NOMI | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Gakushuin |

| | | |
|---|---|---|
| លោក | Toshifumi MINAMI | អតីតចៅក្រមសាលាឧទ្ធរណ៍នៃទីក្រុងតូក្យូ |
| លោក | Toyohiro NOMURA | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Gakushu-in |
| លោក | Masayuki TANAMURA | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Waseda |
| លោក | Keita SATO | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Chuo |
| លោក | Atsushi MOTOYAMA | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Ritsumeikan |
| លោក | Hiroshi MATSUO | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Keio |
| លោក | Hisaya HATANAKA | ជំនួយការសាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Fukuoka |
| លោក | Keisuke ENDO | មន្ត្រីនៃការិយាល័យកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ |
| លោក | Kazuo UESAKA | សាស្ត្រាចារ្យនៃនាយកដ្ឋានកិច្ចសហប្រតិបត្តិការអន្តរជាតិនៃក្រសួងយុត្តិធម៌ |

## សមាសភាពលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាយោបល់

| | | |
|---|---|---|
| លោក | Atsuhito YOSHIMOTO | អ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលច្បាប់រដ្ឋប្បវេណី និងពាណិជ្ជកម្មអន្តរជាតិ |
| លោក | Hisashi NAGAYA | អ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលច្បាប់រដ្ឋប្បវេណី និងពាណិជ្ជកម្មអន្តរជាតិ |

## អ្នកបកប្រែ :

| | | |
|---|---|---|
| លោក | **គឹម ពេជ្រដា** | អតីតជំនួយការ នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | **កែវ ពិសី** | អតីតជំនួយការ នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | **កែវ ម៉ានី** | អតីតមន្ត្រីច្បាប់ជាន់ខ្ពស់ នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | **ឡៀប សុខសិរីយស** | អតីតជំនួយការផ្នែកច្បាប់ នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | **ង៉ែត ណារ័ត្ន** | មន្ត្រីច្បាប់ នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | **សោម រតនា** | ជំនួយការផ្នែកច្បាប់ នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| កញ្ញា | **ស៊ី ច័ន្ទដឺម៉ា** | ជំនួយការរដ្ឋបាល នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ : ៨២.ក.យ.ប្រក/១៣

# ប្រកាស

## ស្តីពី

## នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី



មហាវិថីសម្តេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322 023 2 7 841

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ឧបសម្ព័ន្ធទី ១
ប្រការ ១៩

# ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

ឈ្មោះ........................ភេទ ប្រុស អាយុ.................ថ្ងៃ ខែ ឆ្នាំកំណើត............ ជាប្ដី ☐ ឬ ជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ................ ផ្លូវលេខ...........ភូមិ......... ឃុំ សង្កាត់...............ក្រុង ស្រុក ខណ្ឌ...............រាជធានី ខេត្ត............ ។

ឈ្មោះ.......................ភេទ ស្រី អាយុ.............ថ្ងៃ ខែ ឆ្នាំកំណើត......... ជាប្រពន្ធ ☐ ឬ ជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............... ផ្លូវលេខ...........ភូមិ......... ឃុំ សង្កាត់..............ក្រុង ស្រុក ខណ្ឌ.................រាជធានី ខេត្ត............ ។

ឈ្មោះរបស់អ្នកតំណាង........................ភេទ.......អាយុ........ថ្ងៃខែឆ្នាំកំណើត................ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ...........ផ្លូវលេខ.........ភូមិ.......... ឃុំ សង្កាត់............. ក្រុង ស្រុក ខណ្ឌ...................... រាជធានី ខេត្ត...................... ។

**សូមគោរពជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

កម្មវត្ថុ ៖ សំណើសុំចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ។

- គោលបំណងនៃការចុះបញ្ជី:....................(ចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ)...... ។
- មូលហេតុ:.....................(កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ព្រមទាំងកាលបរិច្ឆេទ)......... ។
- ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ:.......(សរសេរខ្លឹមសារកិច្ចសន្យាទាំងអស់).........
..........................................................................................................................
..........................................................................................................................
..........................................................................................................................។

អាស្រ័យហេតុនេះ សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតឲ្យចុះបញ្ជីតាមសំណើខាងលើ ដោយក្ដីអនុគ្រោះ។

ធ្វើនៅ..................ថ្ងៃទី.......ខែ.........ឆ្នាំ ២០.........

p **ស្នាមម្រាមដៃ**

**ប្ដីឈ្មោះ** **ប្រពន្ធឈ្មោះ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

| ឧបសម្ព័ន្ធទី ២ |
| --- |
| ប្រការ ២០ |

# ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ឈ្មោះ......................ភេទ ប្រុស អាយុ...............ថ្ងៃ ខែ ឆ្នាំកំណើត............ ជាប្តី □ ឬជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា □ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ................ ផ្លូវលេខ...........ភូមិ......... ឃុំ សង្កាត់...............ក្រុង ស្រុក ខណ្ឌ.................រាជធានី ខេត្ត............ ។

ឈ្មោះ......................ភេទ ស្រី អាយុ..............ថ្ងៃ ខែ ឆ្នាំកំណើត.......... ជាប្រពន្ធ □ ឬជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា □ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ................ ផ្លូវលេខ...........ភូមិ......... ឃុំ សង្កាត់...............ក្រុង ស្រុក ខណ្ឌ.................រាជធានី ខេត្ត............ ។

ឈ្មោះរបស់អ្នកតំណាង.........................ភេទ.......អាយុ........ថ្ងៃខែឆ្នាំកំណើត............... អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............ផ្លូវលេខ.........ភូមិ.......... ឃុំ សង្កាត់............. ក្រុង ស្រុក ខណ្ឌ...................... រាជធានី ខេត្ត...................... ។

**សូមគោរពជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

កម្មវត្ថុ ៖ សំណើសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

- គោលបំណងនៃការចុះបញ្ជីៈ.........(ចុះបញ្ជីផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ)...... ។
- មូលហេតុៈ...........(ការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ព្រមទាំងកាលបរិច្ឆេទ)... ។
- ចំណុចដែលត្រូវផ្លាស់ប្តូរៈ.......(សរសេរទាំងអស់នូវខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ក្រោយពីការផ្លាស់ប្តូររួច).......................................................................
..........................................................................................................
..........................................................................................................
..........................................................................................................។

អាស្រ័យហេតុនេះ សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតឲ្យចុះបញ្ជីតាមសំណើខាងលើ ដោយក្តីអនុគ្រោះ។

ធ្វើនៅ.................ថ្ងៃទី.......ខែ.........ឆ្នាំ ២០.........
**ស្នាមម្រាមដៃ**

**ប្តីឈ្មោះ** **ប្រពន្ធឈ្មោះ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ឧបសម្ព័ន្ធទី ៣
ប្រការ ២០

# ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរឈ្មោះ ឬ អាសយដ្ឋាន

ឈ្មោះ........................ភេទ ....... អាយុ................ថ្ងៃ ខែ ឆ្នាំកំណើត............ ជាប្តី ឬ ប្រពន្ធ ឬ ជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............... ផ្លូវលេខ...........ភូមិ......... ឃុំ សង្កាត់...............ក្រុង ស្រុក ខណ្ឌ.................រាជធានី ខេត្ត............ ។

ឈ្មោះរបស់អ្នកតំណាង..........................ភេទ.......អាយុ........ថ្ងៃខែឆ្នាំកំណើត................ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............ផ្លូវលេខ.........ភូមិ.......... ឃុំ សង្កាត់............. ក្រុង ស្រុក ខណ្ឌ....................... រាជធានី ខេត្ត...................... ។

**សូមគោរពជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

កម្មវត្ថុ ៖ សំណើសុំចុះបញ្ជីអំពីការផ្លាស់ប្តូរឈ្មោះ ឬ អាសយដ្ឋាន។

- គោលបំណងនៃការចុះបញ្ជី:.....................(ចុះបញ្ជីផ្លាស់ប្តូរឈ្មោះ ឬ អាសយដ្ឋាន)...... ។
- មូលហេតុ:.......................(ការផ្លាស់ប្តូរឈ្មោះ ឬ អាសយដ្ឋាន ព្រមទាំងកាលបរិច្ឆេទ)... ។
- ចំណុចដែលត្រូវផ្លាស់ប្តូរ:.......(ឈ្មោះថ្មី ឬ អាសយដ្ឋានថ្មី)..........................................
..........................................................................................................
..........................................................................................................
..........................................................................................................។

អាស្រ័យហេតុនេះ សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតឲ្យចុះបញ្ជីតាមសំណើខាងលើ ដោយក្តីអនុគ្រោះ។

ធ្វើនៅ.................ថ្ងៃទី.......ខែ.........ឆ្នាំ ២០.........

**ស្នាមម្រាមដៃ**

ឈ្មោះ

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី ៤
ប្រកាស ២១

# ពាក្យសុំចុះបញ្ជីអំពីការកែតម្រូវការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

ឈ្មោះ......................ភេទ ប្រុស អាយុ...............ថ្ងៃ ខែ ឆ្នាំកំណើត............ ជាប្ដី ☐ ឬ ជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............... ផ្លូវលេខ.........ភូមិ......... ឃុំ សង្កាត់...............ក្រុង ស្រុក ខណ្ឌ................រាជធានី ខេត្ត........... ។

ឈ្មោះ........................ភេទ ស្រី អាយុ..............ថ្ងៃ ខែ ឆ្នាំកំណើត.......... ជាប្រពន្ធ☐ ឬ ជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ................ ផ្លូវលេខ...........ភូមិ......... ឃុំ សង្កាត់...............ក្រុង ស្រុក ខណ្ឌ.................រាជធានី ខេត្ត............ ។

ឈ្មោះរបស់អ្នកតំណាង.........................ភេទ.......អាយុ........ថ្ងៃខែឆ្នាំកំណើត............... អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............ផ្លូវលេខ.........ភូមិ.......... ឃុំ សង្កាត់............. ក្រុង ស្រុក ខណ្ឌ....................... រាជធានី ខេត្ត....................... ។

## សូមគោរពជូន
## ឯកឧត្ដម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

កម្មវត្ថុ ៖ សំណើសុំចុះបញ្ជីអំពីការការកែតម្រូវការចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ។

- គោលបំណងនៃការចុះបញ្ជីៈ...........(កែតម្រូវកំហុស ឬ ការខកខានមិនបានចុះបញ្ជី).... ។
- មូលហេតុៈ.......................(មានកំហុស ឬ ការខកខានមិនបានចុះបញ្ជី)...................... ។
- ចំណុចដែលត្រូវកែតម្រូវៈ
    - ឈ្មោះ..........................................................................................
    - អាសយដ្ឋាន....................................................................................
    - ថ្ងៃខែឆ្នាំកំណើត...............................................................................
    - ខ្លឹមសារនៃទ្រព្យសម្បត្តិប្ដីប្រពន្ធ..............................................................

អាស្រ័យហេតុនេះ សូមឯកឧត្ដមរដ្ឋមន្ត្រី មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតឲ្យចុះបញ្ជីតាមសំណើខាងលើ ដោយក្ដីអនុគ្រោះ។

ធ្វើនៅ..................ថ្ងៃទី.......ខែ.........ឆ្នាំ ២០.........

ស្នាមម្រាមដៃ

ប្ដីឈ្មោះ ប្រពន្ធឈ្មោះ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

| ឧបសម្ព័ន្ធទី ៥ |
|---|
| ប្រការ ២២ - ២៧ |

## ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ [1]

ឈ្មោះ........................ភេទ ប្រុស អាយុ................ថ្ងៃ ខែ ឆ្នាំកំណើត............ ជាប្តី ☐ ឬ ជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ................ ផ្លូវលេខ...........ភូមិ......... ឃុំ សង្កាត់...............ក្រុង ស្រុក ខណ្ឌ.................រាជធានី ខេត្ត........... ។

ឈ្មោះ........................ភេទ ស្រី អាយុ..............ថ្ងៃ ខែ ឆ្នាំកំណើត.......... ជាប្រពន្ធ ☐ ឬ ជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ................ ផ្លូវលេខ...........ភូមិ......... ឃុំ សង្កាត់..............ក្រុង ស្រុក ខណ្ឌ................រាជធានី ខេត្ត........... ។

ឈ្មោះរបស់អ្នកតំណាង..........................ភេទ.......អាយុ........ថ្ងៃខែឆ្នាំកំណើត................ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............ផ្លូវលេខ.........ភូមិ.......... ឃុំ សង្កាត់............. ក្រុង ស្រុក ខណ្ឌ...................... រាជធានី ខេត្ត..................... ។

**សូមគោរពជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

កម្មវត្ថុ ៖ សំណើសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

- គោលបំណងនៃការចុះបញ្ជី:...........(លុបការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ)................ ។
- មូលហេតុ:.......................(ការរំលាយអាពាហ៍ពិពាហ៍ ព្រមទាំងកាលបរិច្ឆេទ ឬ រំលាយកំជាប់ពាក្យ ព្រមទាំងកាលបរិច្ឆេទ).......................................................................។

អាស្រ័យហេតុនេះ សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតឲ្យចុះបញ្ជីតាមសំណើខាងលើ ដោយក្តីអនុគ្រោះ។

ធ្វើនៅ.................ថ្ងៃទី.......ខែ.........ឆ្នាំ ២០.........

**ស្នាមម្រាមដៃ**

p

**ប្តីឈ្មោះ** **ប្រពន្ធឈ្មោះ**

---

[1] ក្នុងករណីមោឃភាព ការលុបចោល ឬការរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ឬ រំលាយអាពាហ៍ពិពាហ៍ ឬកំជាប់ពាក្យ ដោយផ្អែកលើសេចក្តីសម្រេចរបស់តុលាការ អ្នកដាក់ពាក្យសុំអាចដាក់ពាក្យសុំតែម្នាក់ឯងបាន។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

| ឧបសម្ព័ន្ធទី ៦ |
|---|
| ប្រការ ២៨ |

## ពាក្យសុំចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍

ឈ្មោះ........................ភេទ ប្រុស អាយុ................ថ្ងៃ ខែ ឆ្នាំកំណើត............ ជាប្តី ឬជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............... ផ្លូវលេខ...........ភូមិ......... ឃុំ សង្កាត់..............ក្រុង ស្រុក ខណ្ឌ.................រាជធានី ខេត្ត........... ។

ឈ្មោះ........................ភេទ ស្រី អាយុ.............ថ្ងៃ ខែ ឆ្នាំកំណើត......... ជាប្រពន្ធ ឬជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............... ផ្លូវលេខ...........ភូមិ......... ឃុំ សង្កាត់..............ក្រុង ស្រុក ខណ្ឌ.................រាជធានី ខេត្ត........... ។

ឈ្មោះរបស់អ្នកតំណាង.........................ភេទ.......អាយុ........ថ្ងៃខែឆ្នាំកំណើត................ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............ផ្លូវលេខ.........ភូមិ.......... ឃុំ សង្កាត់............. ក្រុង ស្រុក ខណ្ឌ....................... រាជធានី ខេត្ត..................... ។

**សូមគោរពជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

កម្មវត្ថុ ៖ សំណើសុំចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍។

- គោលបំណងនៃការចុះបញ្ជី ៖ ការចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ ។
- មូលហេតុៈ ការរៀបអាពាហ៍ពិពាហ៍ ។
